**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

UNIVERSITÉ ROYALE DE DROIT ET DES SCIENCES ÉCONOMIQUES

ROYAL UNIVERSITY OF LAW AND ECONOMICS

# សារណាបញ្ចប់ការសិក្សា

# ក្រុមហ៊ុនសហកម្មសិទ្ធិនៅប្រទេសកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: **លោក តាំង ខួនស្រ៊ុន**

**កញ្ញា ហេង សុខចេង**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **បណ្ឌិត ព្រុំ រិទ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ហេង សុខចេង** និង ខ្ញុំបាទឈ្មោះ **តាំង ខួនស្រ៊ុន** ជានិស្សិតថ្នាក់បរិញ្ញាបត្រ នីតិសាស្រ្ត ជំនាន់ទី ២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២០-២០២៤។

## សូមថ្លែងអំណរគុណ និងសម្ដែងនូវកតញ្ញូតាធម៌ជូនចំពោះ

**លោកឪពុក និងអ្នកម្ដាយ** ជាអ្នកមានគុណយ៉ាងធំធេង ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ ទំនុកបម្រុងកូនតាំងពីតូច រហូតដល់កូនអាចបន្តការសិក្សាថ្នាក់បរិញ្ញាបត្រមកដល់សព្វថ្ងៃនេះ។ បើគ្មានការយកចិត្តទុកដាក់ ថ្នាក់ថ្នម ស្រលាញ់ពីអ្នកមានគុណទេ ម្ល៉េះកូនមិនអាចក្លាយខ្លួនជា កូនល្អ សិស្សល្អ និងពលរដ្ឋល្អនៅក្នុងសង្គមបានឡើយ។

**ឯកឧត្តម បណ្ឌិត លុយ ចន្ធ្នា** ជាសាកលវិទ្យាធិការ ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រី សាស្រ្តាចារ្យទាំងអស់ដែលបានបំពេញការងារក្នុងការគ្រប់គ្រង ដឹកនាំ និងបង្ហាត់បង្ហាញផ្លូវ និងជួយតម្រង់ទិសដល់ពួកខ្ញុំដោយមិនខ្លាចនឿយហត់ ដោយអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីចូលរួមបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយគុណភាព និងសមត្ថភាពពេញលេញ មុននឹងឈានទៅដល់ការប្រកបវិជ្ជាជីវៈនាថ្ងៃអនាគត។

**លោកសាស្រ្តាចារ្យជំនួយ ព្រុំ រិទ្ធី** នៃសាកលវិទ្យាល័យនីតិសាស្រ្ត ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីជួយណែនាំ និងជ្រោមជ្រែងរហូតដល់ការរៀបរៀងសារណានេះបានចប់សព្វគ្រប់ទៅដោយរលូន។ ទោះបីជាលោករវល់នឹងកិច្ចការលោកយ៉ាងណាក្តី ក៏លោកតែងតែផ្តល់ស្នាមញញឹមរីករាយស្វាគមន៍ក្នុងការជួយបង្ហាត់បង្ហាញ ដើម្បីកែតម្រូវកំហុសឆ្គងក្នុងការសរសេរសារណានេះ ព្រមទាំងអនុសាសន៍ល្អៗដែលលោកបានផ្តល់ឲ្យយើងខ្ញុំទាំងពីរនាក់ដើម្បីយកមកពិចារណាបន្ថែមទៀត។

ជាចុងក្រោយផងដែរ យើងខ្ញុំទាំងពីររូបសូមជូនពរឲ្យអ្នកមានគុណ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស និងលោក លោកស្រីសាស្រ្តាចារ្យ ព្រមទាំងបុគ្គលិកបម្រើការងានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ព្រមទាំងនិស្សិតទាំងអស់ឲ្យមានសុខភាពល្អ សម្រេចជោគជ័យគ្រប់ភារកិច្ចដូចអ្វីដែលបានប៉ងប្រាថ្នា និងសូមជូនពរឲ្យជួបប្រទះពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ និងដឹងគុណយ៉ាងជ្រាលជ្រៅបំផុតពីរូបយើងខ្ញុំទាំងពីរនាក់។

# អារម្ភកថា

តាមការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រអស់រយៈពេល ៤ ឆ្នាំកន្លងមកនេះ មុខវិជ្ជាដែលយើងទាំងពីរនាក់គិតថាស្រលាញ់ ចូលចិត្ត និងសាកសមលើកយកមកស្រាវជ្រាវ ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ គឺមុខវិជ្ជានីតិក្រុមហ៊ុន និងមានកិត្តិយសដ៏ថ្លៃថ្លា សម្រាប់ឱកាសតាក់តែង ស្រាវជ្រាវក្រោមប្រធានបទ "ក្រុមហ៊ុនសហកម្មសិទ្ធិនៅប្រទេសកម្ពុជា"។ វិស័យក្រុមហ៊ុនពិតជាមានសារៈសំខាន់ និងមានសន្ទុះនៃការរីកចម្រើនឡើងក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋខ្មែរនាពេលបច្ចុប្បន្ន ជាពិសេសអ្នកដែលមានបំណងចង់បង្កើតក្រុមហ៊ុន។ ដូច្នេះ ពួកយើងសម្រេចចិត្តលើកយកប្រធានបទ"ក្រុមហ៊ុនសហកម្មសិទ្ធិនៅប្រទេសកម្ពុជា"មួយនេះមកធ្វើការស្រាវជ្រាវ ។

តាមរយៈប្រធានបទខាងលើ អាចជាគន្លឹះខ្លះៗដល់អ្នកដែលមានបំណងចង់បង្កើតក្រុមហ៊ុនពាណិជ្ជកម្ម និងអាចធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវមួយ ថាតើខ្លួនគួរជ្រើសរើសក្រុមហ៊ុនប្រភេទណា ដើម្បីប្រកបអាជីវកម្មឲ្យសាកសមនឹងសមត្ថភាពរបស់ខ្លួន រួមទាំងដើមទុន និងជាពិសេសរួមចំណែកជួយដល់ការសិក្សារបស់និស្សិតផងដែរ។

នៅក្នុងអត្ថបទស្រាវជ្រាវនេះ យើងខ្ញុំទាំងពីរនាក់បានចំណាយពេលវេលាយ៉ាងច្រើនក្នុងការស្វែងរកឯកសារពាក់ព័ន្ធផ្សេងៗដែលមាននៅក្នុងបណ្ណាល័យ និងតាមគេហទំព័រផ្សេងៗ ដើម្បីចងក្រងជាសៀវភៅនិក្ខេបបទនេះឡើង។ យើងខ្ញុំសង្ឃឹមថា កិច្ចការមួយនេះអាចជាចំណែកនៃគុណប្រយោជន៍តូចមួយ ដើម្បីជំនួយដល់ការសិក្សាស្រាវជ្រាវបន្ថែមរបស់និស្សិតជំនាន់ក្រោយដែលមានបំណងក្នុងការសិក្សាស្វែងយល់នូវប្រធាបទនេះ។

យើងខ្ញុំរីករាយស្វាគមន៍ រាល់ការកែរលម្អ ស្ថាបនាពីសំណាក់សាស្ត្រាចារ្យ និងមជ្ឈដ្ឋានអ្នកសិក្សាទាំងអស់ ដើម្បីអភិវឌ្ឍស្នាដៃស្រាវជ្រាវនេះឲ្យកាន់តែល្អប្រសើរឡើង ចំពោះការភ្លាំងភ្លាត់ ខ្វះចន្លោះ ទាំងផ្នែកអត្ថន័យខ្លឹមសារ និងផ្នែកអក្ខរាវិរុទ្ធក្តីដោយប្រការណាមួយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១

## ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ

**ផ្នែកទី១ លក្ខខណ្ឌគ្រឹះនៃការបង្កើតក្រុមហ៊ុន** ........ ៦

១.១ នាមករណ៍ ........ ៧

១.២ សញ្ជាតិ ........ ៨

១.៣ កម្មវត្ថុ ........ ៩

១.៤ ដើមទុននៃក្រុមហ៊ុនសហកម្មសិទ្ធិ ........ ១០

១.៥ សមត្ថភាព ........ ១០

១.៦ ការព្រមព្រៀង ........ ១១

**ផ្នែកទី២ លក្ខខណ្ឌទម្រង់នៃការបង្កើតក្រុមហ៊ុន** ........ ១២

២.១ កិច្ចសន្យាក្រុមហ៊ុន ........ ១២

២.២ លក្ខន្តិកៈក្រុមហ៊ុន ........ ១៣

២.៣ ការចុះបញ្ជីក្រុមហ៊ុន ........ ១៤

**ផ្នែកទី៣ ទណ្ឌកម្មនៃការបង្កើតក្រុមហ៊ុន** ........ ១៧

៣.១ មោឃភាព និងការលុបចោលនៃកិច្ចសន្យាក្រុមហ៊ុន ........ ១៧

៣.២ អានុភាព ........ ១៩

៣.៣ អាជ្ញាយុកាល ........ ២០

## ជំពូកទី២

## ដំណើរការ និងការប្រព្រឹត្តិទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិ

**ផ្នែកទី១ ការគ្រប់គ្រងក្រុមហ៊ុន** ........ ២១

១.១ ការជ្រើសតាំងអ្នកគ្រប់គ្រង ........ ២១

១.២ ការដកហូតអ្នកគ្រប់គ្រង ........ ២២

**ផ្នែកទី២ សិទ្ធិ និងករណីយកិច្ចរបស់សហកម្មសិទ្ធិករទូទៅ** ........ ២២

២.១ សិទ្ធិរបស់សហកម្មសិទ្ធិករទូទៅ ........ ២៣

២.២ ករណីយកិច្ច និងការទទួលខុសត្រូវនៃសហកម្មសិទ្ធិករទូទៅ ........ ២៦

**ផ្នែកទី៣ សិទ្ធិ និងករណីយកិច្ចរបស់សហកម្មសិទ្ធិករមានកម្រិត** ..................... ៣២
៣.១ សិទ្ធិរបស់សហកម្មសិទ្ធិករមានកម្រិត ..................... **៣២**
៣.២ ករណីយកិច្ចរបស់សហកម្មសិទ្ធិករមានកម្រិត ..................... **៣៣**

## ជំពូកទី៣

## ការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិ

**ផ្នែកទី១ មូលហេតុនៃការរំលាយក្រុមហ៊ុន** ..................... **៣៥**
១.១ ការរំលាយដោយពេញច្បាប់ ..................... **៣៥**
១.២ ការរំលាយដោយអំណាចកិច្ចសន្យា ..................... **៣៦**
១.៣ ការរំលាយដោយអំណាចតុលាការ ..................... **៣៧**
១.៤ ការផ្លាស់ប្តូរដោយការបាត់បង់សហកម្មសិទ្ធិករ ..................... **៣៨**
**ផ្នែកទី២ នីតិវិធីនៃការរំលាយក្រុមហ៊ុន** ..................... **៣៩**
២.១ កិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុន ..................... **៣៩**
២.២ ការជូនដំណឹងអំពីការរំលាយក្រុមហ៊ុន ..................... **៣៩**
២.៣ ការជម្រះបញ្ជី ..................... **៤០**
២.៤ ការទូទាត់នៃការជម្រះបញ្ជី ..................... **៤២**
**ផ្នែកទី៣ អានុភាពនៃការរំលាយក្រុមហ៊ុន** ..................... **៤២**
៣.១. អានុភាពចំពោះសហកម្មសិទ្ធិករ ..................... **៤២**
៣.២. អានុភាពចំពោះតតិយជន ..................... **៤៣**
**សេចក្តីសន្និដ្ឋាន** ..................... **៤៤**
**អនុសាសន៍** ..................... **៤៦**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

នាពេលបច្ចុប្បន្ន បុគ្គលគ្រប់រូបតែងតែបានរៀបចំ គិតគូគម្រោងផែនការអនាគតរបស់ខ្លួន។ បុគ្គលភាគច្រើនតែងគិតចង់ធ្វើភាពម្ចាស់លើខ្លួន ពោលគឺ ការធ្វើអាជីវកម្ម ឬការរកស៊ីធ្វើជំនួញ។ ពាណិជ្ជករដែលគ្រប់គ្រងពាណិជ្ជកម្មត្រូវតែជាបុគ្គលដែលមានធនធាន ចំណេះដឹង គួបផ្សំជាមួយសមត្ថភាពតាមផ្លូវច្បាប់ ទើបមានសិទ្ធិប្រកបអាជីវកម្មស្របច្បាប់បាន។ ការរកស៊ីធ្វើជំនួញទទួលបានប្រាក់ចំណេញច្រើនជាងការធ្វើការងារស៊ីប្រាក់ខែ និងមិនសូវមានសម្ពាធ និងការគាបសង្កត់លើផ្លូវកាយ និង ផ្លូវចិត្តទៀតផង។ ប៉ុន្តែ មានបុគ្គលខ្លះទៀតបានគិតថាការធ្វើការងារយកប្រាក់ពីថៅកែមានភាពសេរី ងាយស្រួល និងមិនចាំបាច់គិតច្រើន ឬមិនមានភាពស្មុគស្មាញ។ ប៉ុន្តែ ប្រសិនបើបុគ្គលភាគច្រើនមានគំនិតប្រកបអាជីវកម្ម ឬបង្កើតក្រុមហ៊ុនដោយខ្លួនឯង នោះវាមានភាពប្រសើរ ព្រោះវាបានជួយដល់សេដ្ឋកិច្ចជាតិផងដែរ។

ក្រុមហ៊ុនពាណិជ្ជកម្ម បានចាប់បដិសន្ធិដំបូងនៅកម្ពុជា តាមបញ្ញត្តិក្រមពាណិជ្ជកម្មដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៥០។ ថ្វីបើក្រមនេះត្រូវបានធ្វើវិសោធនកម្មច្រើនលើកច្រើនសារក៏ដោយ ក៏ទម្រង់ក្រុមហ៊ុននៅសម័យនោះនៅតែជាទម្រង់ក្រុមហ៊ុនតាមប្រព័ន្ធច្បាប់បារាំង។ ទម្រង់ក្រុមហ៊ុននោះរួមមាន ក្រុមហ៊ុនអនាមិក ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនចម្រុះ ក្រុមហ៊ុនសមូហនាម ក្រុមហ៊ុនបុគ្គល សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ក្រុមហ៊ុនឯកបុគ្គលនិងសម្ព័ន្ធផលប្រយោជន៍សេដ្ឋកិច្ច។ សញ្ញាណក្រុមហ៊ុនទាំងនេះ ត្រូវបានគេបោះបង់ចោលក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៨) ហើយមានការកើតឡើងសារជាថ្មីបន្ទាប់ពីការដួលរលំនៃរបបនេះ។

ក្រុមហ៊ុនសហកម្មសិទ្ធិដែលត្រូវបានគេស្គាល់ មានប្រវត្តិតាំងពីបុរាណកាលមកម្ល៉េះ។ គំនិតនៃបុគ្គលរួមគ្នាដើម្បីធ្វើអាជីវកម្ម និងចែករំលែកប្រាក់ចំណេញនិងការខាតបង់គឺជាទម្រង់មួយក្នុងចំណោមទម្រង់ចាស់បំផុតនៃពាណិជ្ជកម្ម។ ក្នុងឆ្នាំ១៨៤៤ នៅទីក្រុង Rochdale នៃចក្រភពអង់គ្លេស បានបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិដំបូង ដែលគេត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថាជា Rochdale Society of Equitable Pioneers។ គំនិតផ្តួចផ្តើមនេះគឺជាការឆ្លើយតបទៅនឹងបញ្ហាប្រឈមសេដ្ឋកិច្ចសង្គម ដែលកម្មករប្រឈមមុខក្នុងអំឡុងពេលបដិវត្តន៍ឧស្សាហកម្ម។ គោលបំណងចម្បងនៃការបង្កើតក្រុមហ៊ុននេះ គឺដើម្បីដោះស្រាយបញ្ហាសេដ្ឋកិច្ចដែលកម្មករបានជួបប្រទះ។ ក្នុងអំឡុងបដិវត្តន៍ឧស្សាហកម្ម កម្មករជាច្រើនបានស៊ូទ្រាំនឹងការធ្វើការងារច្រើនម៉ោង និងប្រាក់ឈ្នួលទាប ខណៈដែលតម្លៃនៃការរស់នៅបន្តកើនឡើង។ ក្រោយមក ភាពជោគជ័យនៃការបង្កើតនេះ បានជំរុញឱ្យមានការបង្កើតសហករណ៍ជាច្រើននៅទូទាំងចក្រភពអង់គ្លេស និងបណ្តាលពិភព

លោកទៀតផង។ វាបានបង្ហាញថា មនុស្សសាមញ្ញអាចរួមគ្នាបង្កើតសេដ្ឋកិច្ចដែលផ្តល់អាទិភាពដល់ភាពយុត្តិធម៌ គុណភាព និងសហគមន៍លើប្រាក់ចំណេញ។ ចលនាសហប្រតិបត្តិការដែលកើតចេញពី Rochdale បានជះឥទ្ធិពលយូរអង្វែងលើវិស័យផ្សេងៗរួមទាំងកសិកម្ម ការលក់រាយ ធនាគារ និងលំនៅដ្ឋាន ការលើកកម្ពស់យុត្តិធម៌សង្គម និងសេដ្ឋកិច្ចនៅទូទាំងពិភពលោក។ សរុបមក កំណើតនៃក្រុមហ៊ុនសហដៃគូ គឺត្រូវចាក់ឫសតាមប្រពៃណីប្រវត្តិសាស្ត្រនៃបុគ្គលដែលមករួមគ្នាដើម្បីបន្តគោលដៅអាជីវកម្មរួម។ ភាពជាដៃគូនៅតែបន្តជាទម្រង់នៃអង្គភាពអាជីវកម្មដ៏ពេញនិយមនាពេលបច្ចុប្បន្ន ដោយផ្តល់នូវភាពបត់បែន និងឱកាសសម្រាប់ការសហការគ្នាក្នុងចំណោមដៃគូអាជីវកម្ម។[1]

នៅក្នុងឆ្នាំ១៩៩៥ ប្រទេសកម្ពុជាបានអនុម័តច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម។ ច្បាប់នេះមានដើមកំណើតនៅប្រទេសកម្ពុជាដោយយកគំរូតាមច្បាប់ប្រទេសបារាំង ដែលមានការទាក់ទងនឹងពាណិជ្ជកម្ម។[2] ក្រុមហ៊ុនសហកម្មសិទ្ធិនៅក្នុងប្រទេសកម្ពុជា ត្រូវបានទទួលស្គាល់ចាប់តាំងពីការអនុវត្តច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មក្នុងឆ្នាំ ១៩៩៥។ ច្បាប់នេះបានផ្តល់នូវក្របខ័ណ្ឌច្បាប់សម្រាប់ប្រភេទផ្សេងៗនៃអង្គភាពអាជីវកម្ម រួមទាំងភាពជាដៃគូផងដែរ។ ប្រទេសកម្ពុជាបានបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិដំបូងរបស់ខ្លួននៅក្នុងឆ្នាំ២០០៥ ដែលជាកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសជាតិក្នុងការជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចតាមរយៈគំរូអាជីវកម្មសហប្រតិបត្តិការ។ គំនិតនេះបានផ្តួចផ្តើមឡើងក្នុងបរិបទដែលកម្ពុជាកំពុងបន្តក្នុងភាពជម្លោះ និងអស្ថិរភាពជាច្រើនទស្សវត្សរ៍ ហើយវាមានគោលបំណងដោះស្រាយបញ្ហាប្រឈមនានាដែលសេដ្ឋកិច្ចសង្គមជួបប្រទះ។ ដូច្នេះហើយ ក្រុមហ៊ុនសហការជាដៃគូបានក្លាយជាផ្នែកមួយនៃទិដ្ឋភាពធុរកិច្ចរបស់ប្រទេសកម្ពុជាអស់រយៈពេលជិត ២៩ ឆ្នាំគិតត្រឹមឆ្នាំ ២០២៤។ បុគ្គលគ្រប់រូប មិនថារូបវន្តបុគ្គល ឬនីតិបុគ្គលឱ្យតែមានលក្ខណៈសម្បត្តិស្របច្បាប់ អាចសហការគ្នាបាន ដោយដាក់ទុនចូលគ្នាបង្កើតជាក្រុមហ៊ុនមួយ ក្នុងគោលបំណងធ្វើពាណិជ្ជកម្មដើម្បីរកប្រាក់ចំណេញរួមគ្នា។ ក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥ មាត្រា ១ បានកំណត់អំពីប្រភេទនៃក្រុមហ៊ុន ដែលមានក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនមូលធន។

ច្បាប់សហគ្រាសពាណិជ្ជកម្មកម្ពុជាត្រូវបានកែប្រែជាច្រើនដងក្នុងកំឡុងឆ្នាំ១៩៩៣ ដល់ឆ្នាំ២០២២។ វិសោធនកម្មពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ១៩៩៥ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មកម្ពុជា មានគោលបំណងធ្វើសេរីភាវូបនីយកម្ម និងកំណែទម្រង់សេដ្ឋកិច្ចរបស់ប្រទេស បន្ទាប់ពីសង្គ្រាមស៊ីវិល និងរបប

[1] *The Rochdale Pioneers and the Co-operative Principles.* http://www.columbia.edu/~hauben/amalgamated/history/34/ ចូលទស្សនាថ្ងៃទី)២ មិថុនា ២០២៤(

[2] កៅ មុយថង, *ច្បាប់ពាណិជ្ជកម្ម*, បោះពុម្ពលើកទី៣ (ភ្នំពេញៈ អង្គរ, ២០១៥), ទំព័រ១។

ខ្មែរក្រហម។ វិសោធនកម្មទាំងនេះបានស្វែងរកការទាក់ទាញ ការវិនិយោគពីបរទេសជំរុញកំណើនសេដ្ឋកិច្ច និងបង្កើតភាពងាយស្រួលសម្រាប់អាជីវកម្មនៅកម្ពុជា។ វិសោធនកម្មជាក់លាក់ក្នុងអំឡុងពេលនេះរួមមានការផ្លាស់ប្តូរនៅក្នុងបទប្បញ្ញត្តិទាក់ទងនឹងកម្មសិទ្ធិបរទេស ការលើកទឹកចិត្តក្នុងការ វិនិយោគ និងនីតិវិធីនៃការផ្តល់អាជ្ញាប័ណ្ណ។ វិសោធនកម្មមួយនេះបានដាក់នូវច្បាប់សំខាន់ៗដូចជា៖ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ បានកត់សម្គាល់ការចាប់ផ្តើមនៃយុគសម័យថ្មី ដែលផ្តល់មូលដ្ឋានគ្រឹះផ្នែកច្បាប់សម្រាប់សេដ្ឋកិច្ចទីផ្សារ។ រដ្ឋធម្មនុញ្ញចែងសិទ្ធិកម្មសិទ្ធិឯកជន និងគោលការណ៍សេរីភាវូបនីយកម្មសេដ្ឋកិច្ច។ ច្បាប់ស្តីពីការវិនិយោគនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៤ ជាច្បាប់សំខាន់ដែលបង្កើតឡើងដើម្បីទាក់ទាញការវិនិយោគពីបរទេស។ អនុក្រឹត្យស្តីពីការបង្កើតសហគ្រាសពាណិជ្ជកម្មឆ្នាំ ១៩៩៥ បានដាក់ចេញនូវនីតិវិធីជាមូលដ្ឋានសម្រាប់ការចុះបញ្ជី និងបង្កើតអាជីវកម្មនៅកម្ពុជា ដោយផ្តល់នូវក្របខណ្ឌច្បាប់សម្រាប់ការបង្កើតសហគ្រាសឯកជន។ ការវិសោធនកម្មនេះ គឺដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ ព្រមទាំងមានក្របខណ្ឌច្បាប់ដែលអាចគាំទ្រដល់ប្រតិបត្តិការអាជីវកម្មឯកជន។ មួយវិញទៀត ជំរុញឲ្យមានការវិនិយោគពីបរទេស ដើម្បីកសាងសេដ្ឋកិច្ចដែលហែកហួរដោយសារសង្គ្រាម។ ច្បាប់ថ្មីនេះត្រូវបានបង្កើតឡើងក្នុងការបង្កើតបរិយាកាសអំណោយផលសម្រាប់អ្នកវិនិយោគបរទេសដោយផ្តល់នូវការការពារផ្លូវច្បាប់និងការលើកទឹកចិត្តសេដ្ឋកិច្ច។ ម្យ៉ាងទៀត កម្ពុជាចាំបាច់ត្រូវបង្កើតស្ថាប័នច្បាប់ និងច្បាប់ដែលគាំទ្រដល់សេដ្ឋកិច្ចទីផ្សារ។ នេះជាការចាប់ផ្តើមនៃការធ្វើអាជីវកម្មជាផ្លូវការក្នុងប្រទេស និងផ្តល់បរិយាកាសដែលមានរចនាសម្ព័ន្ធសម្រាប់សហគ្រាស។

វិសោធនកម្មពីឆ្នាំ ១៩៩៥ - ២០០៥ នៅចុងទសវត្សរ៍ឆ្នាំ ១៩៩០ និងដើមទសវត្សរ៍ឆ្នាំ ២០០០ ប្រទេសកម្ពុជាបានបន្តស្ថិរភាពនយោបាយ និងសេដ្ឋកិច្ច។ រយៈពេលនេះបានឃើញការធ្វើសមាហរណកម្មបន្ថែមទៀតទៅក្នុងសេដ្ឋកិច្ចពិភពលោក ដោយឈានដល់ការចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ក្នុងឆ្នាំ ២០០៤។ ការធ្វើវិសោធនកម្មបន្ថែមលើច្បាប់សហគ្រាសពាណិជ្ជកម្មកម្ពុជា ដើម្បីដោះស្រាយបញ្ហាប្រឈម និងឱកាសដែលកំពុងកើតមាននៅក្នុងសេដ្ឋកិច្ចរបស់ប្រទេស។ វិសោធនកម្មទាំងនេះត្រូវបានជំរុញដោយកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការលើកកម្ពស់ការប្រកួតប្រជែង កែលម្អក្របខណ្ឌបទប្បញ្ញត្តិ និងតម្រឹមច្បាប់អាជីវកម្មកម្ពុជាជាមួយនឹងស្តង់ដារអន្តរជាតិ។ ក្នុងនោះផងដែរ បទប្បញ្ញត្តិដែលវិសោធនកម្ម បានចែងលម្អិតស្តីពីការបង្កើត ប្រតិបត្តិការ និងការរំលាយក្រុមហ៊ុន រួមទាំងច្បាប់ស្តីពីអភិបាលកិច្ចសាជីវកម្មសិទ្ធិម្ចាស់ភាគហ៊ុន និងភារកិច្ចរបស់នាយក។ ព្រមទាំងណែនាំយន្តការទំនើបសម្រាប់ប្រតិបត្តិការទូទាត់ និងហិរញ្ញវត្ថុ ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុដែលមានមុខងារ និងគាំទ្រពាណិជ្ជកម្ម

វិសោធនកម្មនេះក៏បានពង្រឹងបរិយាកាសធុរកិច្ច លើកកម្ពស់អភិបាលកិច្ចសាជីវកម្ម ការធ្វើទំនើបកម្មប្រព័ន្ធហិរញ្ញវត្ថុ និងដើម្បីបំពេញតាមលក្ខខណ្ឌនៃសមាជិកភាព WTO។

គួរបញ្ជាក់ផងដែលថា ក្រុមហ៊ុនសហកម្មសិទ្ធិមាននិយមន័យទូទៅ គឺទំនាក់ទំនងរវាងបុគ្គលពីរឬច្រើននាក់ ឬជាសមាគមនៃបុគ្គលទាំងឡាយ ដែលរួមគ្នាសំរាប់គោលបំណងចែកប្រាក់ចំណេញ និងការបង់ខាតជាមួយគ្នា ដែលកើតចេញពីការប្រើប្រាស់ទុន កម្លាំង ពលកម្ម ឬ បំណិននៅក្នុងប្រតិបត្តិការរួមគ្នាមួយ ឬនៅក្នុងប្រតិបត្តិការបន្តបន្ទាប់គ្នា។ ក្រុមហ៊ុនសហកម្មសិទ្ធិបែងចែកចេញជាពីរ គឺក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និង ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ ក្រុមហ៊ុនសហកម្មសិទ្ធិត្រូវមានកិច្ចព្រមព្រៀង រវាងសហកម្មសិទ្ធិករទូទៅជាលាយលក្ខណ៍អក្សរ ឬជាផ្ទាល់មាត់ ដោយមានភាពជាក់លាក់ ដូចជា នាមករណ៍ អាសយដ្ឋាន ចំនួនទឹកប្រាក់បណ្តាក់ទុន និងការបែងចែកនូវប្រាក់ចំណេញ។ ចំពោះដើមទុនដែលយកមករកស៊ីជាមួយគ្នា ក្នុងប្រភេទក្រុមហ៊ុនសហកម្មសិទ្ធិទូទៅទៅនេះ គឺដាក់អាចជាសាច់ប្រាក់ ជាទ្រព្យសម្បត្តិ ជាចំណេះដឹង ឬជាជំនាញ។ រយៈពេលនៃកិច្ចសន្យាបង្កើតក្រុមហ៊ុននេះ អាចធ្វើឡើងដោយមានរយៈពេលកំណត់ក៏បាន និងមិនកំណត់ក៏បានដូចគ្នា។ ជាទូទៅ ក្រុមហ៊ុនសហកម្មសិទ្ធិ គេច្រើនបង្កើតឡើង នៅក្នុងអាជីវកម្មជាលក្ខណៈវិជ្ជាជីវៈ ដូចជាបង្កើតគ្លីនិកពេទ្យ ការិយាល័យមេធាវី គណនេយ្យករ ស្ថាបត្យករ ឬកុងស៊ុលតង់ជាដើម។[3] ប្រភេទក្រុមហ៊ុននេះមានលក្ខណៈងាយស្រួលនៅត្រង់ថា ក្រុមហ៊ុនសហកម្មសិទ្ធិ អាចចាប់ផ្តើមដំណើរការបានដោយមិនទាមទារដើមទុនច្រើន មានគ្នាតែពីរ ឬបីនាក់ មានកម្លាំង មានពេលវេលា មានជំនាញ មានដើមទុនម្នាក់បន្តិចៗ ល្មមអាចចូលគ្នា ដើម្បីទិញ ឬជួលទីតាំង និងសម្ភារៈសំខាន់ៗចាំបាច់ គឺអាចចាប់ផ្តើមដំណើរការបង្កើតជាក្រុមហ៊ុនសហកម្មសិទ្ធិ ដើម្បីប្រកបអាជីវកម្មបាន ហើយក៏មិនតម្រូវឲ្យមានឯកសារច្បាប់អ្វីស្មុគស្មាញច្រើនដែរ។ ក៏ប៉ុន្តែនៅក្នុងប្រទេសកម្ពុជា ភាគច្រើនគេនិយមបង្កើតក្រុមហ៊ុនមូលធនជាងក្រុមហ៊ុនសហកម្មសិទ្ធិ ព្រោះវាផ្តល់ភាពងាយស្រួលក្នុងការបង្កើតអាជីវកម្មក្នុងទ្រង់ទ្រាយធំ ហើយងាយស្រួលក្នុងការស្វែងរកទុនបន្ថែម ដើម្បីពង្រីកអាជីវកម្ម។ ការបោះទុនវិនិយោគក្នុងក្រុមហ៊ុនមូលធន និងការដកទុនចេញវិញ ក៏មានលក្ខណៈងាយស្រួលជាងក្រុមហ៊ុនសហកម្មសិទ្ធិ។ ការទទួលខុសត្រូវរបស់ម្ចាស់ហ៊ុនមានកម្រិតត្រឹមដើមទុនដែលវិនិយោគ ហើយទ្រព្យនិងបំណុលរបស់ក្រុមហ៊ុនត្រូវបែងចែកគ្នាដាច់ស្រឡះ ពីទ្រព្យ និងបំណុលរបស់បុគ្គលជាម្ចាស់ហ៊ុន។ នេះជាបញ្ហាដែលត្រូវសង្កត់ធ្ងន់គួរកត់សម្គាល់ថា ហេតុអ្វីបានជាក្រុមហ៊ុនសហកម្មសិទ្ធិ មិនសូវជាពេញនិយមដូចក្រុម

[3] *គុណសម្បត្តិ និងគុណវិបត្តិនៃប្រភេទក្រុមហ៊ុនពាណិជ្ជកម្មក្នុងច្បាប់ខ្មែរ.* https://www.rfi.fr/km/different-types-of-companies-in-cambodian-law? (ចូលទស្សនាថ្ងៃទី ៣១ មិថុនា ២០២៤)

ហ៊ុនដទៃទៀត? ដោយសារតែមើលឃើញនូវបញ្ហានេះបានសម្រេចចិត្តយកប្រធានបទ"ក្រុមហ៊ុនសហកម្មសិទ្ធិនៅប្រទេសកម្ពុជា"នេះ មកបកស្រាយ ម្យាងវិញទៀត ក្រុមហ៊ុននេះក៏ជាប្រភេទក្រុមហ៊ុនខ្នាតតូចដែរ បែបនេះហើយទើបមានការលិចឡើងនូវចម្ងល់ថា តើក្រុមហ៊ុនសហកម្មសិទ្ធនេះមានទម្រង់អ្វីខ្លះ? តើក្រុមហ៊ុនសហកម្មសិទ្ធនេះមានលក្ខណៈពិសេសយ៉ាងដូចម្ដេចខ្លះ?

ដើម្បីឈានដល់ការបកស្រាយប្រធានបទខាងលើនេះ គេបានធ្វើការសិក្សាស្រាវជ្រាវវិភាគទៅលើឯកសារច្បាប់ និងបទដ្ឋានគតិយុត្តដែលទាក់ទងនឹងវិស័យពាណិជ្ជកម្ម ជាពិសេសច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។ ហេតុដូច្នេះហើយ ប្លង់នៃកិច្ចការស្រាវជ្រាវនេះបានបែងចែកចេញជាបីជំពូកគឺ៖

**ជំពូកទី១**៖ ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ ដែលក្នុងជំពូកនេះចែកចេញជា៣ផ្នែកទៀតគឺ **ផ្នែកទី១** លក្ខខណ្ឌគ្រឹះនៃការបង្កើតក្រុមហ៊ុន; **ផ្នែកទី២** លក្ខខណ្ឌទម្រង់នៃការបង្កើតក្រុមហ៊ុន និង**ផ្នែកទី៣** ទណ្ឌកម្មនៃការបង្កើតក្រុមហ៊ុន។

**ជំពូកទី២**៖ ដំណើរការ និងការប្រព្រឹត្តិទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិ ដែលក្នុងជំពូកនេះចែកចេញជា៣ផ្នែកទៀតគឺ **ផ្នែកទី១** ការគ្រប់គ្រងក្រុមហ៊ុន; **ផ្នែកទី២** សិទ្ធិ និងករណីកិច្ចរបស់សហកម្មសិទ្ធិករទូទៅ និង **ផ្នែកទី៣** សិទ្ធិ និងករណីកិច្ចរបស់សហកម្មសិទ្ធិករមានកម្រិត។

**ជំពូកទី៣**៖ ការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិ ដែលក្នុងជំពូកនេះចែកចេញជា៣ផ្នែកទៀតគឺ **ផ្នែកទី១** មូលហេតុនៃការរំលាយក្រុមហ៊ុន; **ផ្នែកទី២** នីតិវិធីនៃការរំលាយក្រុមហ៊ុន និង**ផ្នែកទី៣** អានុភាពនៃការរំលាយក្រុមហ៊ុន។

# ជំពូកទី១
# ការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ

មុននឹងឈានដល់ការបកស្រាយលើការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ ត្រូវយល់ជាមុនថាអ្វីទៅជាក្រុមហ៊ុនសហកម្មសិទ្ធិ។ ក្រុមហ៊ុនសហកម្មសិទ្ធិគឺ ទំនាក់ទំនងរវាងបុគ្គលពីរ ឬច្រើននាក់ ឬជាសមាគមនៃបុគ្គលទាំងឡាយ ដែលរួមប្រសព្វគ្នាសំរាប់គោលបំណងចែកប្រាក់ចំណេញ និងការបង់ខាតជាមួយគ្នា ដែលកើតចេញពីការប្រើប្រាស់ទុន កម្លាំង ពលកម្ម ឬបំណិននៅក្នុងប្រតិបត្តិការរួមគ្នាមួយ ឬនៅក្នុងប្រតិបត្តិការបន្តបន្ទាប់គ្នា។ យោងតាមមាត្រា១ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ២០២២ ក្រុមហ៊ុនសហកម្មសិទ្ធិបែងចែកចេញជាពីរ គឺក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺជាកិច្ចសន្យារវាងបុគ្គលពីរនាក់ ឬច្រើននាក់ដែលដាក់រួមគ្នានូវទ្រព្យសម្បត្តិ ចំណេះដឹង ឬសកម្មភាពរបស់បុគ្គលទាំងនោះ ដើម្បីប្រកបពាណិជ្ជកិច្ចរួមក្នុងគោលបំណងរកប្រាក់ចំណេញ។[4]

ចំណែកឯក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតមានន័យថា ជាកិច្ចសន្យាដែលធ្វើឡើងរវាងសហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ ដែលមានបុគ្គលម្នាក់ត្រូវបានអនុញ្ញាតឱ្យគ្រប់គ្រង និងមានកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនជាមួយសហកម្មសិទ្ធិករមានកម្រិតម្នាក់ ឬច្រើននាក់ ដែលមានកាតព្វកិច្ចបង់ភាគទុនចូលទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិនោះ។[5]

ក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ ត្រូវគោរពទៅតាមលក្ខខណ្ឌមួយចំនួនដែលមានចែងនៅក្នុងច្បាប់សហគ្រាសពាណិជ្ជកម្ម និងច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម។ ជាពិសេសបុគ្គលទាំងឡាយណា ដែលមានបំណងចង់បង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ ក៏ត្រូវតែបំពេញនូវលក្ខខណ្ឌដែលស្របតាមច្បាប់នេះបានតម្រូវ។

## ផ្នែកទី១ លក្ខខណ្ឌគ្រឹះនៃការបង្កើតក្រុមហ៊ុន

លក្ខខណ្ឌគ្រឹះក្នុងការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធ គឺការធ្វើកិច្ចព្រមព្រៀងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនេះគឺ បង្ហាញនូវលក្ខណៈ និងគោលបំណងរបស់អាជីវកម្ម នាមករណ៍ អាសយដ្ឋាន ចំនួនប្រាក់ដែលបានវិនិយោគ និងវិធីបែងចែកប្រាក់ចំណេញ។

---

[4] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ព្រះរាជក្រមលេខ នស/រកម/០១២២/០០៣, ៦ មករា ២០២២, មាត្រា៨។

[5] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៦៤។

## ១.១ នាមករណ៍

ដើម្បីឱ្យច្បាប់សហគ្រាសពាណិជ្ជកម្មទទួលស្គាល់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបាន លុះត្រាតែបានចុះបញ្ជីពាណិជ្ជកម្មហើយក្នុងនាមជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅឲ្យបានត្រឹមត្រូវ ព្រមទាំងបញ្ជាក់ឈ្មោះ និងសញ្ជាតិ។ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម មាត្រា១៤ បានចែងពីវិធានសំរាប់ដាក់ឈ្មោះក្រុមហ៊ុនសហកម្មសិទ្ធិដោយបានចែងថា៖ នាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវដាក់បញ្ចូលនូវនាមរបស់សហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ ហើយនៅខាងក្រោយ ឬនៅខាងក្រោមនាមករណ៍នោះត្រូវបន្ថែមពាក្យថា"ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ"។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវប្រើនាមករណ៍របស់ខ្លួននៅក្នុងពេលធ្វើពាណិជ្ជកិច្ច។[6] បានន័យថា រាល់ឈ្មោះរបស់ក្រុមហ៊ុនសហកម្មសិទ្ធិត្រូវដាក់បញ្ចូលនូវឈ្មោះរបស់សមាជិកនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅម្នាក់ ឬច្រើននាក់ហើយនៅខាងក្រោម នាមករណ៍នោះត្រូវបន្ថែមពាក្យថា"ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ"។ ពេលធ្វើពាណិជ្ជកម្ម ឬអាជីវកម្មក្រុមហ៊ុនសហកម្មសិទ្ធិនោះត្រូវប្រើប្រាស់នាមករណ៍របស់ខ្លួន។

ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម មាត្រា ៦៨ បានចែងថា នាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតត្រូវមានឈ្មោះសហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ដោយមានកន្ទុយពាក្យថា"ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត"។ មានភាពដូចគ្នាទៅនឹងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែល ត្រូវដាក់បញ្ចូលនូវឈ្មោះរបស់សមាជិករបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅម្នាក់ ឬច្រើននាក់ហើយនៅខាងក្រោយនាមករណ៍នោះត្រូវបន្ថែមពាក្យថា"ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត"។

ក៏ប៉ុន្តែតាមមាត្រា ៧៣ នៃច្បាប់សហគ្រាសពាណិជ្ជកម្មចែងថា៖ សហកម្មសិទ្ធិករមានកម្រិត ដែលមានឈ្មោះនៅក្នុងនាមករណ៍ជាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ដូចសហកម្មសិទ្ធិករទូទៅដែរ លើកលែងតែស្ថានភាពរបស់សហកម្មសិទ្ធិករមានកម្រិតនោះត្រូវបានបញ្ជាក់ច្បាស់លាស់។ ឈ្មោះរបស់សហកម្មសិទ្ធិករមានកម្រិតណាម្នាក់មិនអាចមាននៅលើនាមករណ៍របស់ក្រុមហ៊ុនបានទេ បើពុំនោះទេ សហកម្មសិទ្ធិករមានកម្រិតនោះនឹងត្រូវទទួលខុសត្រូវគ្មានកម្រិត ដូចជាសហកម្មសិទ្ធិករទូទៅដែរ។ បើកាលណាយកឈ្មោះសហកម្មសិទ្ធិករមានកម្រិតណាម្នាក់មកធ្វើជាឈ្មោះក្រុមហ៊ុនសហកម្មសិទ្ធិករមានកម្រិតនោះត្រូវ ទទួលខុសត្រូវក្នុងឋានៈជាសហកម្មសិទ្ធិករទូទៅ ។

នាមករណ៍ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវផ្លាស់ប្តូរ ប្រសិនបើសហកម្មសិទ្ធិករទូទៅថ្មីត្រូវបានផ្លាស់ប្តូរដោយសារតែឈ្មោះនៃសហកម្មសិទ្ធិករជាធម្មតាមានការពាក់ព័ន្ធនៅក្នុងអាជីវកម្ម។ យោងតាមច្បាប់កម្ពុជាស្តីពីសហគ្រាសពាណិជ្ជកម្ម ឈ្មោះនៃសហកម្មសិទ្ធិករទូទៅត្រូវតែបញ្ចូលឈ្មោះទាំងអស់។ ដូច្នេះ នៅពេល

[6] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា១៤។

ដែលដៃគូថ្មីចូលរួម ឈ្មោះនៃសហកម្មសិទ្ធិករទូទៅគួរតែធ្វើបច្ចុប្បន្នភាព ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនេះ ដោយធានាថាវាអនុលោមតាមតម្រូវការច្បាប់។ ប៉ុន្តែ ឈ្មោះក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មិនចាំបាច់ផ្លាស់ប្តូរទេទោះមានសហកម្មសិទ្ធិករមានកម្រិតថ្មីចូលរួមក៏ដោយ ឈ្មោះនៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត តម្រូវឱ្យបញ្ចូលឈ្មោះរបស់សហកម្មសិទ្ធិករទូទៅយ៉ាងហោចណាស់មួយនាក់ ប៉ុន្តែមិនចាំបាច់បញ្ចូលឈ្មោះសហកម្មសិទ្ធិករទាំងអស់ ជាពិសេសសហកម្មសិទ្ធិករមានកម្រិត។ ដូច្នេះ ប្រសិនបើសហកម្មសិទ្ធិករមានកម្រិតថ្មីចូលរួម នោះឈ្មោះនៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតមិនចាំបាច់ត្រូវផ្លាស់ប្តូរទេលុះត្រាតែមានតម្រូវការផ្នែកច្បាប់ ឬកិច្ចសន្យាជាក់លាក់ដើម្បីធ្វើដូច្នេះ។[7]

### ១.២ សញ្ជាតិ

ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលមានសហកម្មសិទ្ធិករសញ្ជាតិខ្មែរ ត្រូវមានសញ្ជាតិក្រុមហ៊ុនជាខ្មែរ។ ប៉ុន្តែបើក្រុមហ៊ុនសហកម្មសិទ្ធិមួយមានសមាជិកខ្មែរផង និងសមាជិកបរទេសផង សញ្ជាតិក្រុមហ៊ុនសហកម្មសិទ្ធិត្រូវយោងទៅតាមចំណែកទុនភាគច្រើននៃសមាជិកណាមួយ ឬក្រុមណាមួយ និងទីកន្លែងធ្វើអាជីវកម្ម។ ប្រសិនបើចង់បានក្រុមហ៊ុនដែលមានសមាជិកពីរសញ្ជាតិ សញ្ជាតិជាខ្មែរត្រូវស្របតាមច្បាប់សហគ្រាសពាណិជ្ជកម្ម ត្រង់មាត្រា ១៣ ដែរបានលើកឡើងថា៖ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅទទួលបាននូវនីតិបុគ្គលិកលក្ខណៈសញ្ជាតិ ខ្មែរលុះត្រាតែគោរពនូវលក្ខខណ្ឌពីរ៖

- ❖ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមានទីស្នាក់ការចុះបញ្ជី និងទីកន្លែងធ្វើអាជីវកម្មស្ថិតនៅក្នុង ព្រះរាជាណាចក្រកម្ពុជា បានន័យថា ដើម្បីឲ្យក្រុមហ៊ុនសហកម្មសិទ្ធិមួយមានសញ្ជាតិជាខ្មែរ ក្រុមហ៊ុននោះ ត្រូវចុះបញ្ជីអាស័យដ្ឋាននៃការិយាល័យរបស់ខ្លួន ដោយការិយាល័យចុះបញ្ជីនៅប្រទេសកម្ពុជា។ ក្រុមហ៊ុនត្រូវតែងតាំងភ្នាក់ងារចុះបញ្ជីមួយដែលមានការិយាល័យចុះបញ្ជីនៅក្នុងប្រទេសខ្មែរ។ ចំណែកឯ ទីកន្លែងអាជីវកម្មគឺត្រូវស្ថិតនៅក្នុងប្រទេសកម្ពុជា។ ទីកន្លែងរបស់ក្រុមហ៊ុនសហកម្មសិទ្ធិជារឿងមួយសំខាន់ព្រោះវាទាក់ទងនឹងការបញ្ជូនលិខិត និង សមត្ថកិច្ចតុលាការ។
- ❖ អត្ថប្រយោជន៍នៅក្នុងក្រុមហ៊ុនចាប់ពី ៥១ (៥០ + ១) ភាគរយត្រូវបានកាន់កាប់ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលមានសញ្ជាតិខ្មែរ។[8] ចំពោះចំណុចនេះ ច្បាប់សហគ្រាសពាណិជ្ជកម្មបានយកគំរូតាមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា តាំងពីឆ្នាំ១៩៩៤មកម៉្លេះដែលសព្វថ្ងៃច្បាប់នេះត្រូវបាននរាករណ៍ ដោយសហកម្មសិទ្ធិករខ្មែរត្រូវមានចំណែកផលប្រយោជន៍នៅក្នុងក្រុមហ៊ុនចំនួន ៥១

[7] កៅ មុយថង, *ច្បាប់ពាណិជ្ជកម្ម*, បោះពុម្ពលើកទី៣ (ភ្នំពេញ៖ អង្គរ, ២០១៥), ទំព័រ២២០។

[8] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា១៤។

ភាគរយ។ ចំណែកផលប្រយោជន៍នេះ ត្រូវកំណត់ដោយសមាមាត្រនៃចំណែកទុនរបស់ខ្លួននៅក្នុងក្រុមហ៊ុន។ ការកំណត់នៃសិទ្ធិកាន់កាបនេះបាន អនុលោមតាមរដ្ឋធម្មនុញ្ញច្បាប់ និងបទបញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធទៅនឹងកម្មសិទ្ធិ និងការប្រើប្រាស់ដីធ្លី៖ កម្មសិទ្ធិដីធ្លីសម្រាប់បម្រើឲ្យគោលដៅនៃសកម្មភាពវិនិយោគ ត្រូវបានប្រគល់ជូនចំពោះអ្នកវិនិយោគដែលជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ។ នីតិបុគ្គលមានសញ្ជាតិជាខ្មែរ គឺជានីតិបុគ្គលដែលមានភាគហ៊ុនពី ៥១% ឡើងទៅនៃដើមទុនសរុបជាកម្មសិទ្ធិរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរ។

**១.៣ កម្មវត្ថុ**

កម្មវត្ថុនៃក្រុមហ៊ុនសហកម្មសិទ្ធិ ជាសេចក្តីថ្លែងពីគោលបំណងទូទៅ និងទំហំនៃសកម្មភាពដែលក្រុមហ៊ុនសហកម្មសិទ្ធិត្រូវអនុវត្តដើម្បីឲ្យសម្រេងគោលបំណងទូទៅរបស់ខ្លួន។ គោលបំណងទូទៅនោះ គឺស្វែងរកចំណេញ មិនមែនបង្កើតឡើងដើម្បីធ្វើសប្បុរសធម៌នោះទេ។ កម្មវត្ថុដែលថ្លែងពីទំហំនៃសកម្មភាពរបស់ក្រុមហ៊ុននេះគឺជា ការរាយបញ្ជីនូវសកម្មភាពដែលក្រុមហ៊ុនត្រូវធ្វើ។ ការរាយបញ្ជីនូវ សកម្មភាពរបស់ក្រុមហ៊ុននេះធ្វើឡើង ដើម្បីឲ្យមន្ត្រីចុះបញ្ជីដឹងថា សកម្មភាពណាខ្លះត្រូវបានហាមឃាត់ និងសកម្មភាពណាទៀតត្រូវបានអនុញ្ញាត។ កាលណាក្រុមហ៊ុនសហកម្មសិទ្ធិចែងពីសកម្មភាពដែលច្បាប់ហាមឃាត់ មន្ត្រីចុះបញ្ជីអាចបដិសេធមិនចុះបញ្ជីឲ្យ។[9] ឧទាហរណ៍ ក្រុមហ៊ុនដែលមានកម្មវត្ថុបើកកន្លែងរកស៊ីផ្លូវភេទ ឬកន្លែងលក់សារធាតុញៀនដែលផ្ទុយទៅនឹងច្បាប់បានចែងនោះមិនអាចចុះបញ្ជីបានទេ ព្រោះជាកម្មវត្ថុមិនស្របច្បាប់។ សម្រាប់ទំហំនៃសកម្មភាពរបស់ក្រុមហ៊ុនអាចរាយនូវមុខបញ្ជីសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនខ្លួនបានច្រើនប្រភេទ។

ក្រុមហ៊ុនដែលចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម អាចរៀបរាប់ពីសកម្មភាពច្រើនរបស់ក្រុមហ៊ុននៅក្នុងកម្មវត្ថុ ទោះបីជាសកម្មភាពខ្លះស្ថិតនៅក្នុងវិស័យជំនាញ ឬការយកចិត្តទុកដាក់របស់ខ្លួនក៏ដោយ។ ការរៀបរាប់បែបនេះ ដើម្បីជាផលប្រយោជន៍នៅថ្ងៃក្រោយ ប្រសិនក្រុមហ៊ុនចង់ធ្វើមុខរបរផ្សេងមួយទៀត។ បើថ្ងៃណាមួយម្ចាស់ក្រុមហ៊ុនចង់ប្តូរអាជីវកម្ម នោះគេមិនបាច់កែប្រែលក្ខន្តិកៈ និងចុះបញ្ជីម្តងទៀតឡើយ ដោយវិសោធនកម្មលក្ខន្តិកៈជាមួយមន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ដែលតម្រូវដោយមាត្រា ១៨ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម។ ឧទាហរណ៍ ក្រុមហ៊ុនមួយដែលមានគោលបំណងរកស៊ីខាងសំណង់ បែរជារាយនៅក្នុងកម្មវត្ថុរបស់ខ្លួននូវបញ្ជីសកម្មភាពអាជីវកម្មរ៉ែ, ភាពយន្ត, អាហារដ្ឋានីហារ៍ណ, ភោជនីយដ្ឋាន។ល។ ដោយហេតុដូច្នេះនៅថ្ងៃខាងមុខ ប្រសិនបើក្រុមហ៊ុនចង់ផ្លាស់ប្តូរពីក្រុមហ៊ុនសំណង់ ទៅជាក្រុមហ៊ុនលក់គ្រឿងផ្ទះបាយវិញបាន

[9] កុយនាម, *ច្បាប់ក្រុមហ៊ុន*, ការផ្សាយលើកទី១ (ឧត្តម្ភការបោះពុម្ភពីលោកមេធាវី សួន វិសាល, ២០១៦), ទំព័រ១០៨។

ដោយហេតុថាខ្លួនបានវាយឈ្មោះប្រភេទក្រុមហ៊ុន នេះនៅក្នុងកម្មវត្ថុបន្ទាប់បន្សំរបស់ខ្លួន។ កម្មវត្ថុរបស់ក្រុមហ៊ុនដែលមានភាពទូលំទូលាយ មិននាំឱ្យប៉ះពាល់ទៅដល់ទម្រង់ក្រុមហ៊ុនដទៃទៀតទេ ប៉ុន្តែវាអាចនាំមកនូវគ្រោះថ្នាក់ចំពោះសមាជិកទាំងឡាយនៃក្រុមហ៊ុននេះ។ ព្រោះថា សមាជិកក្រុមហ៊ុនត្រូវទទួលខុសត្រូវដោយគ្មានកម្រិត និងដោយសាមគ្គីចំពោះបំណុលរបស់តតិយជន។[10]

## ១.៤ ដើមទុននៃក្រុមហ៊ុនសហកម្មសិទ្ធិ

ដើមទុននៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ គឺជាចំនួនកំណត់ជាក់លាក់ដោយកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិ ដែលសហកម្មសិទ្ធិករម្នាក់ៗបានរួមចំណែកដើម្បីចាប់ផ្ដើមនិងប្រកបពាណិជ្ជកិច្ចរបស់គេ។ យោងតាមមាត្រា ២១ នៃច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្មចែងថាៈ ដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅរួមមានភាគទុនជាសាច់ប្រាក់ និងជាវត្ថុ។ ភាគទុនជាវត្ថុត្រូវវាយតម្លៃជាសាច់ប្រាក់ ហើយសហកម្មសិទ្ធិករទូទៅទាំងអស់ត្រូវទទួលស្គាល់ការវាយតម្លៃនោះ។ ការគណនាដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មិនត្រូវរាប់បញ្ចូលនូវភាគទុនជាចំណេះដឹង ជាសេវា ឬភាគទុនជាសកម្មភាពទេ។[11] បានសេចក្ដីថា ដើមទុនរបស់ក្រុមហ៊ុនសហសកម្មសិទ្ធិត្រូវគិតជាសាច់ប្រាក់, វត្ថុ (ចលនវត្ថុ ឬអចលនវត្ថុ), ចំណេះដឹង, ឬ សេវកម្ម ដែលភាគទុនទាំងនោះ ត្រូវគិតជាសាច់ប្រាក់និងរូបិយប័ណ្ណជាតិ(ប្រាក់រៀល)។ វិភាគទានជាភាគទុនរបស់សហកម្មសិទ្ធិករទាំងនេះក្លាយទៅជាកម្មសិទ្ធិរបស់ក្រុមហ៊ុន។ ដើមទុនជាផ្នែកមួយនៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន។ ដើមទុនជាចំនួននឹងថ្កល់ តែទ្រព្យសម្បត្តិមានការប្រែប្រួលទៅតាមការរីកចម្រើន ឬការខាតបង់នៃអាជីវកម្ម។

## ១.៥ សមត្ថភាព

សមត្ថភាពរបស់សហកម្មសិទ្ធិករទូទៅ ពុំចាំបាច់ជាពាណិជ្ជករនោះទេ ពីព្រោះក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅប្រកបពាណិជ្ជកិច្ចភាគច្រើនជាប្រភេទអាជីវកម្មខ្នាតតូច ហើយបង្កើតឡើងក្នុងគោលបំណងរកប្រាក់ចំណេញ ពុំមានមាត្រានៃច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្មចែងអំពីបញ្ហានេះឡើយ។ ប៉ុន្តែតាមមាត្រា៨ នៃច្បាប់នេះបានចែងថា ក្រុមហ៊ុនសហកម្មសិទ្ធទូទៅជាកិច្ចសន្យារវាងបុគ្គលពីរ ឬច្រើននាក់ដែលដាក់រួមគ្នានូវទ្រព្យ ចំណេះដឹង ឬសកម្មភាព ដើម្បីប្រកបពាណិជ្ជកម្មរួមក្នុងគោលបំណងរកប្រាក់ចំណេញ។ អ្នកដែលមានសិទ្ធិចូលជាម្ចាស់ភាគហ៊ុននៃក្រុមហ៊ុនប្រភេទនេះបាន លុះត្រាជានីតិជនដែលមានសមត្ថភាពយល់ដឹងគ្រប់គ្រាន់ និងអនីតិជនដែលទទួលបានអត្តាធីនភាព គឺជាអំពើគតិយុត្តដែលអនុញ្ញាតឱ្យអនីតិជន ដែលមានអាយុ

[10] កុយនាម, *ច្បាប់ក្រុមហ៊ុន*, ការផ្សាយលើកទី១ (ឧត្ដមការបោះពុម្ពពីលោកមេធាវី សួន វិសាល, ២០១៦), ទំព័រ១០៩។

[11] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២១។

ចាប់ពីអាយុ១៦ឆ្នាំឡើងទៅ ទទួលបានសមត្ថភាពពេញលេញដូចជានីតិជនផងដែរ។[12]

រីឯក្រុមហ៊ុនសហកម្មសិទ្ធមានកម្រិត ចំពោះសមត្ថភាពរបស់សហកម្មសិទ្ធករ ហាក់មានភាពស្មុគស្មាញមួយកម្រិតទៀត ដោយហេតុថាការទទួលខុសត្រូវចំពោះបំណុលរបស់ក្រុមហ៊ុនអាចប្រែប្រួលទៅតាមគុណភាព ឬសិទ្ធិរបស់ម្ចាស់ភាគទុន។ បើជាសហកម្មសិទ្ធិករទូទៅ នោះការទទួលខុសត្រូវមានលក្ខណៈទូទៅ និងឥតកំណត់។ បើជាសហកម្មសិទ្ធិករទទួលខុសត្រូវមានកម្រិត គេទទួលខុសត្រូវត្រឹមដើមទុនរបស់ក្រុមហ៊ុនប៉ុណ្ណោះ។ ហេតុនេះហើយទើបគេយល់ថា ម្ចាស់ភាគហ៊ុនប្រភេទនេះអាចជាអនីតិជន ឬនីតិជនក្រោមអាណាព្យាបាល។[13] ព្រោះវាមានលក្ខណៈទទួលខុសត្រូវត្រឹមដើមទុនតែប៉ុណ្ណោះ មិនមានការទទួលខុសត្រូវដល់បំណុលដែលត្រូវចេញប្រាក់ពីហោប៉ៅខ្លួនផ្ទាល់នោះទេ ។

### ១.៦ ការព្រមព្រៀង

ការព្រមព្រៀងរបស់សហកម្មសិទ្ធិករក៏មានសារៈសំខាន់ខ្លាំងដែរ ក្នុងការបង្កើត ក៏ដូចជាក្នុងដំណើរការ និងការសម្រេចចិត្តលើកិច្ចការអ្វីមួយនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ ជាទូទៅ ការព្រមព្រៀងកើតមានឡើងស្របពេលក្នុងការបង្កើតកិច្ចសន្យា។ ក្នុងនេះផងដែរ នៅពេលដែលសហកម្មសិទ្ធិករទូទៅទាំងអស់មានឆន្ទៈស្របគ្នា បង្កើតឲ្យមានការព្រមព្រៀង។ ការបង្ហាញឆន្ទៈត្រូវស្ថិតក្នុងលក្ខខណ្ឌច្បាស់លាស់ ពោលគឺ វាមិនមែនជាឆន្ទៈដែលកើតចេញមកពីការភាន់ច្រឡំ ការឆបោក ការគម្រាមកំហែង ការបង្ហាញការមិនពិតរបស់ភាគីម្ខាង ឬជា "ឆន្ទៈ"មួយដែលស្តែងឡើងក្រោមរូបភាពជាការឆ្លៀតឱកាស ហើយមានគោលបំណងកេងចំណេញហួសហេតុ។ ដូចនេះ រាល់ការសម្តែងឆន្ទៈមិនពិត អាចធ្វើឱ្យកិច្ចសន្យាគ្មានសុពលភាព ឬភាគីម្ខាងទៀតអាចស្នើសុំមោឃភាព។

ផ្ទុយទៅវិញ ប្រសិនបើករណីមិនមានការព្រមព្រៀងគ្នា នោះនឹងមិនមានការកកើតនូវកិច្ចសន្យាក្រុមហ៊ុនឡើយ។ ម៉្យាងវិញទៀត ក្នុងករណីដែលកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ បានចែងនៅកិច្ចព្រមព្រៀងដោយសហកម្មសិទ្ធិករទូទៅនីមួយពីការព្រមព្រៀងសន្យាថា នឹងធ្វើអ្វី ផ្តល់អ្វីខ្លះដល់ក្រុមហ៊ុន(ភាគទុន) បើសហកម្មសិទ្ធិករបានសន្យា មានការព្រមព្រៀងក្នុងសន្យាហើយនឹងត្រូវគោរពតាមកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ។ បើពុំដូច្នេះទេ នឹងអាចមានការខាតបង់ទៅកាន់ក្រុមហ៊ុនសហកម្មសិទ្ធិក៏ដូចជាធ្វើឲ្យមានបញ្ហាទៅដល់ដំណើរការរបស់ក្រុមហ៊ុនជាមិនខាន់។[14]

---

[12] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧,០៣០, ០៨ ធ្នូ ២០០៧, មាត្រា ២១។

[13] កៅ មុយថង, *ច្បាប់ពាណិជ្ជកម្ម*, បោះពុម្ពលើកទី៣ (ភ្នំពេញ៖ អង្គរ, ២០១៥), ទំព័រ៣១-៣២។

[14] កៅ មុយថង, *ច្បាប់ពាណិជ្ជកម្ម*, បោះពុម្ពលើកទី៣ (ភ្នំពេញ៖ អង្គរ, ២០១៥), ទំព័រ២៦-៣២។

## ផ្នែកទី២៖ លក្ខខណ្ឌទម្រង់នៃការបង្កើតក្រុមហ៊ុន

លក្ខខណ្ឌទម្រង់ គឺជារបៀប ឬទម្រង់ផ្សេងៗដែលបង្ហាញពីជំហានឬបច្ចេកទេសផ្សេងៗ ជាបន្តបន្ទាប់ពណ៌នានៅក្នុងសេចក្តីលម្អិតប្រាប់អំពីភារកិច្ច ឬការងារជាក់លាក់ណាមួយ តើគេត្រូវដោះស្រាយការងារនោះដោយវិធីសាស្ត្រណា? ជាទូទៅ ទម្រង់ការបង្ហាញព័ត៌មានលម្អិតនៃសកម្មភាពជាច្រើនដែលត្រូវអនុវត្តនៅក្នុងគោលបំណងដើម្បីសម្រេចនូវកម្មវិធីរបស់ក្រុមហ៊ុន។

### ២.១ កិច្ចសន្យាក្រុមហ៊ុន

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវបានបង្កើតឡើងនៅពេលភាគីទាំងអស់ចុះកិច្ចសន្យាជាមួយគ្នា។ មាត្រា ៩ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មចែងថា កិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ អាចធ្វើជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ក៏បាន។ ដោយត្រូវគោរពតាមគោលការណ៍សុពលភាពនៃកិច្ចសន្យាដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលគ្មានកិច្ចសន្យា ជាប្រភេទក្រុមហ៊ុនក្រៅប្រព័ន្ធ ឬជាក្រុមហ៊ុនដែលមិនបានចុះបញ្ជី។ ប្រសិនបើកិច្ចសន្យាក្រុមហ៊ុនធ្វើឡើងជាលាយលក្ខណ៍អក្សរ សហកម្មសិទ្ធិករទូទៅទាំងអស់ត្រូវចុះហត្ថលេខាលើកិច្ចសន្យានោះ។ កិច្ចសន្យារបស់ក្រុមហ៊ុន អាចត្រូវគេធ្វើឡើងច្រើនច្បាប់តាមដែលអាចធ្វើទៅបាន។ ក្នុងនេះគេត្រូវ៖

- ដាក់តម្កល់នៅឯទីស្នាក់ការក្រុមហ៊ុន
- ដាក់តម្កល់នៅឯស្ថាប័នមានសមត្ថកិច្ច
- បំពេញតាមទម្រង់នានាដែលច្បាប់តម្រូវ
- ចែកជូនដល់សមាជិកក្រុមហ៊ុនទាំងអស់។

នៅក្នុងកិច្ចសន្យា ត្រូវមានបញ្ជាក់ពីបំណងផ្សេងៗរបស់ក្រុមហ៊ុនក្នុងលក្ខណៈមួយងាយស្រួលទៅដល់លទ្ធភាពដែលអាចបត់បែនបាន។

ដូចគ្នានឹងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែរ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតកើតឡើងដោយកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ហើយសហកម្មសិទ្ធិករទូទៅទាំងអស់ រួមទាំងសហកម្មសិទ្ធិករមានកម្រិតយ៉ាងតិចមួយនាក់ចុះហត្ថលេខាលើកិច្ចសន្យានេះ។[15] អត្ថិភាពនៃក្រុមហ៊ុននេះត្រូវប្រកាសជាសាធារណៈ ព្រោះដោយសារតែក្រុមហ៊ុននេះមានសហកម្មសិទ្ធិករខ្លះជាសហកម្មសិទ្ធិករទទួលខុសត្រូវត្រឹមតែទុនវិនិយោគរបស់ខ្លួន ការប្រកាសជាសាធារណៈនេះជាការដាស់តឿនឲ្យដឹងថា សហកម្មសិទ្ធិករណាមានការទទួល

[15] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៦៦។

ខុសត្រូវគ្មានកម្រិត និងខ្លះទៀតមានការទទួលខុសត្រូវមានកម្រិត។ ម៉្យាងទៀត លក្ខខណ្ឌចម្បងមួយក្នុងការបង្កើតក្រុមហ៊ុន គឺកិច្ចសន្យារវាងសហកម្មសិទ្ធិករទូទៅ និងសហកម្មសិទ្ធិករមានកម្រិត ដើម្បីបង្កើតសិទ្ធិ និងកាតព្វកិច្ចរវាងគ្នានឹងគ្នា។ រយៈពេលនៃកិច្ចសន្យាត្រូវកំណត់មិនឲ្យលើសពី ៩៩ឆ្នាំឡើយ។ តែទោះបីជាពេលវេលាត្រូវបានកំណត់យ៉ាងជាក់លាក់ក៏ដោយ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតអាចបន្តថេរៈវេលានេះបាន។

**២.២ លក្ខន្តិកៈក្រុមហ៊ុន**

លក្ខន្តិកៈនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវបង្កើតឡើងដោយមានភាគីទាំងអស់ចុះហត្ថលេខា។ ក្នុងការអនុវត្តជាក់ស្តែង ក្រសួងពាណិជ្ជកម្មពុំមានទម្រង់ណាមួយសម្រាប់ឱ្យភាគីប្រើប្រាស់ទេ គឺភាគីជាអ្នកតាក់តែងដោយខ្លួនឯងដែលក្នុងនោះកំណត់អំពីខចែងនានាដោយអនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មជាអាទិ៍។

គួរបញ្ជាក់ផងដែលថា មាត្រា១៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុនដែលត្រូវចុះបញ្ជី ត្រូវតម្កល់ឯកសារពីរគឺ ប្រតិវេទន៍ និងលក្ខន្តិកៈ។[16] ប្រតិវេទន៍ ជាបែបបទមួយដែលគេត្រូវបំពេញព័ត៌មានគ្រួសៗអំពីក្រុមហ៊ុន។ លក្ខន្តិកៈ ជាឯកសារដែលចែងលម្អិតអំពីក្រុមហ៊ុន និងសិទ្ធិ និងកាតព្វកិច្ចរបស់សមាជិក។ ក្នុងករណីលក្ខន្តិកៈស្មើនឹងកិច្ចសន្យា នោះក្រុមហ៊ុនសហកម្មសិទ្ធិដែលមានតែកិច្ចសន្យា ផ្ទាល់មាត់មិនអាចចុះបញ្ជីបានទេ។ ក្រុមហ៊ុនដែលមានកិច្ចសន្យាផ្ទាល់មាត់ អាចតម្កល់បានត្រឹមតែប្រតិវេទន៍ ព្រោះគេអាចបំពេញពត៌មាននៅក្នុងបែបបទប្រតិវេទន៍នេះបាន។

ចំពោះការតាក់តែងលក្ខន្តិកៈក្រុមហ៊ុន នេះគឺជាកិច្ចព្រមព្រៀងដែលកំណត់អំពីៈ

- នាមករណ៍ក្រុមហ៊ុន
- ទម្រង់ក្រុមហ៊ុន (សហកម្មសិទ្ធិទូទៅ, សហកម្មសិទ្ធិមានកម្រិត។ល។)
- កម្មវត្ថុអាជីវកម្ម និងសកម្មភាពចំបង
- ថិរវេលានៃសកម្មភាពក្រុមហ៊ុន
- ទីស្នាក់ការចុះបញ្ជី
- ដើមទុនជារូបិយវត្ថុជាតិ រួមទាំង ការបែងចែកជាភាគហ៊ុន តម្លៃចារឹកនៃភាគហ៊ុននីមួយ
- ឈ្មោះ, មុខរបរ, សញ្ជាតិ, អាស័យដ្ឋាន, អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែននៃម្ចាស់ហ៊ុនម្នាក់ៗ, ចំណែកភាគហ៊ុនរបស់ម្ចាស់ហ៊ុនម្នាក់ៗ

[16] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម, នស/រកម/០១២២/០០២, ២៩ មករា ២០២២, មាត្រា១៧ថ្មី(ពីរ)។

- ឈ្មោះ, មុខរបរ, សញ្ជាតិ, អាស័យដ្ឋាន, អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន នៃអភិបាលម្នាក់
- ការទទួលនិងការបាត់បង់សមាជិកភាព
- គណនេយ្យ
- ការរំលាយ
- ការកែប្រែលក្ខន្តិកៈ
- វិធីផ្សព្វផ្សាយជាសាធារណៈ
- សមាជិកក្រុមហ៊ុនអាចបន្ថែមប្រការផ្សេងៗទៀតបាន បើគេចង់បន្ថែម។[17]

សម្រាប់លក្ខន្តិកៈនៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ក៏មានភាពដូចគ្នាទៅនឹងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែរ ថ្វីបើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មមិនតម្រូវឲ្យកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរក្តី។ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតត្រូវបញ្ចេញព័ត៌មានស្ទើរតែស្មើនឹងព័ត៌មាននៅក្នុងកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ ដូច្នេះ បទបញ្ញត្តិដែលមិនតម្រូវឲ្យក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតសរសេរកិច្ចសន្យា ហាក់ដូចជាគ្មានប្រយោជន៍ប៉ុន្មានទេ ព្រោះលក្ខន្តិកៈស្មើគ្នានឹងកិច្ចសន្យាទៅហើយ។

### ២.៣ ការចុះបញ្ជីក្រុមហ៊ុន

ការបង្កើតក្រុមហ៊ុនមួយដោយស្របតាមនីតិវិធីច្បាប់ កិច្ចសំខាន់ដែលសហកម្មសិទ្ធិករត្រូវបំពេញនោះគឺ ត្រូវចុះបញ្ជីក្រុមហ៊ុនរបស់ខ្លួននៅក្រសួងពាណិជ្ជកម្មឱ្យទាន់ពេលវេលាដែលបានកំណត់នៅក្នុងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ដោយក្នុងនោះបានចែងថា គ្រប់ក្រុមហ៊ុនដែលធ្វើសកម្មភាពពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវចុះក្នុងបញ្ជីពាណិជ្ជកម្មទោះបីបែបបទនៃការបង្កើតនិងថេរវេលារបស់ក្រុមហ៊ុនទាំងនោះមានលក្ខណៈបែបណាក៏ដោយ ឬក៏អាចចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្ត។ ដោយយោងតាមប្រកាសលេខ ២១៣ ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្មបានចែងថា រាល់ពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយ ដែលមានគ្រឹះស្ថានសាខា ការិយាល័យតំណាង បុត្រសម្ព័ន្ធ ឬទីភ្នាក់ងាររបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្មពីគ្រប់ទីកន្លែងតាមរយៈគេហទំព័រ។[18]

---

[17] សេចក្តីជូនដំណឹងស្តីពីឯកសារតំរូវការសំរាប់ការចុះបញ្ជីពាណិជ្ជកម្ម, លេខ ១៤១៤ MOC/SM, ចុះថ្ងៃទី ២០ មិថុនា ២០០៦។

[18] *គេហទំព័រចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម.* www.businessregistration.moc.gov.kh (ចូលទស្សនាថ្ងៃទី ១០ កក្កដា ២០២៤)

សហាកម្មសិទ្ធិករត្រូវបំពេញនូវព័ត៌មាន និងបញ្ចូលលក្ខខណ្ឌតម្រូវទាំងអស់តាមទម្រង់កំណត់នៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម ព័ត៌មានស្នើសុំចុះបញ្ជីពាណិជ្ជកម្មដែលបានបំពេញដោយសហាកម្មសិទ្ធិករ និងឯកសារតម្រូវសម្រាប់តម្កល់នៅក្រសួងពាណិជ្ជកម្ម ត្រូវបញ្ចូលក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្មជាទម្រង់អេឡិចត្រូនិក។ ក្នុងករណីសហាកម្មសិទ្ធិករមិនអាចបំពេញនូវព័ត៌មាន និងបញ្ចូលលក្ខខណ្ឌតម្រូវក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មដោយខ្លួនឯងបាន អាចទៅក្រសួងពាណិជ្ជកម្ម ដើម្បីស្នើឲ្យមន្ត្រីចុះបញ្ជីបំពេញនូវព័ត៌មាន និងបញ្ចូលលក្ខខណ្ឌតម្រូវក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មជំនួស។[19] គួរបញ្ជាក់ផងដែរថា កាលណាក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតមិនបានចុះបញ្ជីពាណិជ្ជកម្មទេ ក្រុមហ៊ុននោះនឹងក្លាយជាក្រុមហ៊ុនសហកម្មសិទ្ធិទូទៅវិញ។ ក្នុងករណីនេះក្រុមហ៊ុនពុំទទួលបាននីតិបុគ្គលិកលក្ខណៈទេ។ ជាក់ស្តែងចំពោះការចុះបញ្ជីនេះ អ្នកត្រូវផ្តល់ព័ត៌មានមួយចំនួនអំពីអាជីវកម្មរបស់អ្នក ដើម្បីទទួលបានវិញ្ញាបនបត្រក្នុងការចុះបញ្ជីពាណិជ្ជកម្ម។

ជាក់ស្តែង ការចុះបញ្ជីក្រុមហ៊ុនត្រូវធ្វើជាមួយនឹងក្រសួងពាណិជ្ជកម្មអគ្គនាយកដ្ឋានពន្ធដារ និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ដូចជាត្រូវចុះបញ្ជីជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាផងដែរ ប្រសិនបើក្រុមហ៊ុននោះទទួលបានគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ ជាភាពងាយស្រួលក្នុងការចុះបញ្ជីនាពេលបច្ចុប្បន្ននេះ អ្នកអាចធ្វើការចុះបញ្ជីបានតាមរយៈថ្នាក់បច្ចេកវិទ្យាព័ត៌មានត្រឹមតែមួយប៉ុណ្ណោះ គឺតាមប្រព័ន្ធដែលមានឈ្មោះថា CamDX [20] ឬដែលអាចហៅថា Single Portal ដែលជាថ្នាក់បច្ចេកវិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាល។ ការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន គឺជានីតិវិធីនៃការចុះបញ្ជីអាជីវកម្មថ្មីដែលមានលក្ខណៈបង្រួបបង្រួម និងធ្វើឡើងតាមអនឡាញទាំងស្រុងដោយប្រើប្រាស់ថ្នាក់បច្ចេកវិទ្យាព័ត៌មាន ដំណើរការចុះបញ្ជីថ្មីនេះមានការចំណាយពេលយ៉ាងយូរត្រឹមតែ០៨ថ្ងៃប៉ុណ្ណោះ។

ការចុះបញ្ជីនេះគឺតម្រូវឲ្យមានឯកសារមួយចំនួន ដែលឯកសារទាំងនោះរួមមានដូចជា៖

- ឯកសារបញ្ជាក់អាសយដ្ឋាន ដែលអាចជា វិក័យប័ត្រអគ្គិសនី វិក័យប័ត្រទឹក កិច្ចសន្យាជួលផ្ទះឬអគារលិខិតប្រៃសណីយ៍ ជាដើម
- កិច្ចសន្យាបង្កើតក្រុមហ៊ុន
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់សហាកម្មសិទ្ធិករ និងអ្នកគ្រប់គ្រង
- រូបថត ៤x៦

[19] ប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម តាមប្រព័ន្ធស្វ័យប្រវត្តកម្ម, លេខ ២១៣ ព.ណ ចបព.ប្រក, ២៤ មិថុនា ២០១៦, មាត្រា ២។

[20] Cambodia Data eXchange .https://camdx.gov.kh/២០២៤ កក្កដា ចូលទស្សនាថ្ងៃទី៣) )

- សេចក្ដីប្រកាសដោយសុទ្ធចិត្តរបស់អ្នកគ្រប់គ្រងថា គ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ និងមិនមែនជាមន្ត្រីរាជការដែលស្ថិតនៅក្រោមច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- ករណីសហកម្មសិទ្ធិករជានីតិបុគ្គល ៖
  - ច្បាប់ចម្លងឯកសារគតិយុត្តិនៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើម ដោយមានការបញ្ជាក់ស្របតាមការតម្រូវរបស់បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
  - សេចក្ដីសម្រេចក្នុងការបង្កើតក្រុមហ៊ុន និងការតែងតាំងអ្នកតំណាងនីតិបុគ្គលជាសហកម្មសិទ្ធិករ
- ក្នុងអំឡុងពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ក្រុមហ៊ុនត្រូវផ្ញើមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនូវឯកសារដូចខាងក្រោម៖
  - កិច្ចសន្យាបង្កើតក្រុមហ៊ុនច្បាប់ដើម (ចំនួន ០២ ច្បាប់)
  - ករណីសហកម្មសិទ្ធិករជានីតិបុគ្គល៖ សេចក្ដីសម្រេចក្នុងការបង្កើតក្រុមហ៊ុន និងតែងតាំងអ្នកតំណាងនីតិបុគ្គលជាសហកម្មសិទ្ធិករច្បាប់ដើម (ចំនួន ០១ ច្បាប់)

ក្នុងករណី នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មមិនបានទទួលកិច្ចសន្យាបង្កើតក្រុមហ៊ុនច្បាប់ដើម ក្នុងចិរវេលា៣០ថ្ងៃនេះទេ ក្រសួងពាណិជ្ជកម្មអាចជំទាស់នឹងការចុះបញ្ជី និងលុបចោលការចុះបញ្ជីពាណិជ្ជកម្ម ។[21]

នៅពេលដែលឯកសារដូចបានរៀបរាប់ខាងលើមានគ្រប់គ្រាន់សម្រាប់ការចុះបញ្ជី សហកម្មសិទ្ធិករទូទៅត្រូវបង្ហាញខ្លួននៅក្រសួងពាណិជ្ជកម្ម ដើម្បីចុះហត្ថលេខាលើបែបបទនៃពាក្យសុំមុនពេលចេញវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម។ ប្រសិនបើពាក្យសុំត្រូវបានធ្វើឡើងនៅសាខាចុះបញ្ជីពាណិជ្ជកម្មខេត្ត សហកម្មសិទ្ធិករទូទៅត្រូវមកបង្ហាញខ្លួននៅសាខាបញ្ជីពាណិជ្ជកម្មនោះ ដើម្បីចុះហត្ថលេខាលើបែបបទនៃពាក្យសុំមុនពេលចេញវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម។[22]

រាល់ពាណិជ្ជករ ឬអ្នកដឹកនាំក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយណាដែលមិនបានសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមកាលបញ្ញត្តិ នឹងត្រូវប្ដឹងទៅតុលាការអំពីបទប្រកបសកម្មភាពពាណិជ្ជកម្មមិនស្របច្បាប់ និងត្រូវផ្ដន្ទាទោសឱ្យទទួលខុសត្រូវខាងរដ្ឋប្បវេណី និងព្រហ្មទណ្ឌតាមបទបញ្ញត្តិច្បាប់ ។[23]

---

[21] ប្រកាសស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម តាមប្រព័ន្ធស្វ័យប្រវត្តកម្ម, លេខ ២១៣ ព.ណ ចបព.ប្រក, ២៤ មិថុនា ២០១៦, មាត្រា៣។

[22] កៅ មុយថង, *ច្បាប់ពាណិជ្ជកម្ម*, បោះពុម្ពលើកទី៣ (ភ្នំពេញ៖ អង្គរ, ២០១៥), ទំព័រ៨៣។

[23] គង់ សាផន, *នីតិពាណិជ្ជកម្ម*, បោះពុម្ពលើកទី៣ (ភ្នំពេញ៖ សុខ ចេង, ២០២១), ទំព័រ១៦២។

## ផ្នែកទី៣ ឧបណ្ណកម្មនៃការបង្កើតក្រុមហ៊ុន

នៅក្នុងកិច្ចសន្យានៃការបង្កើតក្រុមហ៊ុន ប្រសិនបើការបង្ហាញឆន្ទៈរបស់សហកម្មសិទ្ធិករណាម្នាក់ដែលមានវិការៈ សកម្មភាពរបស់សហកម្មសិទ្ធិករនោះនឹងទុកជាមោឃៈ និងអាចលុបចោលពីកិច្ចសន្យាបង្កើតក្រុមហ៊ុនដោយមិនមានការប៉ះពាល់ក្រុមហ៊ុននោះទេ។ យោងតាមមាត្រា ៧០០ នៃក្រមរដ្ឋប្បវេណី កថាខណ្ឌទី៤បានចែងថា៖ ក្នុងករណីដែលសកម្មភាពនៃការបង្កើតក្រុមហ៊ុនរបស់ភាគីណាមួយក្នុងចំណោមភាគីដែលបានព្រមព្រៀងបង្កើតក្រុមហ៊ុន ក្លាយទៅជាមោឃៈ ឬត្រូវបានលុបចោល ត្រូវចាត់ទុកថា ក្រុមហ៊ុននោះត្រូវបានបង្កើតដោយភាគីដទៃទៀត។[24] ពោលគឺ ក្នុងករណីដែលសកម្មភាពនៃការបង្កើតរបស់អ្នកវិនិយោគខ្លួន ក្លាយទៅជាមោឃៈ ឬត្រូវបានលុបចោលដោយពិនិត្យមើលទៅតាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនព្រមទាំងការគោរពនូវឆន្ទៈភាគី បញ្ញត្តិនេះក៏ទទួលស្គាល់នូវការបង្កើតក្រុមហ៊ុន ទោះបីជាការបង្កើតរបស់បុគ្គលណាម្នាក់ក្លាយទៅជាមោឃៈ ឬត្រូវបានលុបចោលក៏ដោយ។[25]

### ៣.១. មោឃភាព និងការលុបចោលនៃកិច្ចសន្យាក្រុមហ៊ុន

កិច្ចសន្យាមានអានុភាពនៅពេលដែលសំណើ និងស្វីការត្រូវគ្នា តែនៅក្នុងករណីដែលការបង្ហាញឆន្ទៈមានវិការៈ ឬខ្លឹមសារនៃកិច្ចសន្យាផ្ទុយនឹងច្បាប់ នោះកិច្ចសន្យាត្រូវបានរំលាយដោយក្រមរដ្ឋប្បវេណី។ ការរំលាយកិច្ចសន្យានេះមានពីរបែប គឺមោឃភាព និងការលុបចោលនៃកិច្ចសន្យា។

យោងតាមមាត្រា៣៥៦ នៃក្រមរដ្ឋប្បវេណី ដោយពាក្យថា " សកម្មភាព " នេះគឺសំដៅទៅលើកិច្ចសន្យា ឬសកម្មភាពឯកតោភាគី។[26]

#### ក. មោឃភាពនៃកិច្ចសន្យាក្រុមហ៊ុន

នៅក្នុងមាត្រា៣៥៧ នៃក្រមរដ្ឋប្បវេណីដែលបានប្រាប់ពីអត្ថន័យនៃមោឃភាពបានចែងថា៖ ប្រសិនបើអត្ថន័យនៃសកម្មភាព ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន។ ក្នុងករណីដែលសកម្មភាពត្រូវចាត់ទុកជាមោឃៈដោយសារសកម្មភាពនោះផ្ទុយនឹងទម្រង់ដែលត្រូវបានទាមទារឱ្យមានដោយក្រមនេះ ឬ

[24] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧,០៣០, ០៨ ធ្នូ ២០០៧, មាត្រា៧០០ កថាខណ្ឌទី៤។

[25] គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី, សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី (ភ្នំពេញ៖ ការិយាល័យកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌នៅក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា, ២០១០), ទំព័រ១៣៩។

[26] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧,០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៥៦។

ច្បាប់ផ្សេង ជនណាក៏អាចអះអាងនូវមោឃភាពនៃកិច្ចសន្យានោះបាន។[27] ក្នុងករណីដែលអត្ថន័យនៃកិច្ចសន្យា និងសកម្មភាពឯកតោភាគីត្រូវទុកជាមោឃៈដោយសារផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ មិនមែនតែភាគីនៃកិច្ចសន្យា ឬសកម្មភាពឯកតោភាគីទេ គឺរួមទាំងបុគ្គលផ្សេងទៀតក៏អាចអះអាងអំពីមោឃភាពនៃសកម្មភាពនោះបានដែរ។ ភាគីអាចផ្តល់សច្ចានុមតិចំពោះសកម្មភាពដែលទុកជាមោឃៈផងដែរ តែមានករណីលើកលែងទៅលើបញ្ញត្តិដែលអនុវត្តដោយបង្ខំ គឺនៅតែមានអានុភាពនៅពេលផ្តល់សច្ចានុមតិ តែមិនមានការផ្លាស់ប្តូរនៅពេលផ្តល់សច្ចានុមតិទេ ទោះបីជាកិច្ចសន្យានោះត្រូវបានផ្តល់សច្ចានុមតិក៏ដោយ ក៏កិច្ចសន្យានោះត្រូវចាត់ទុកជាមោឃភាពដែរ។[28]

**ខ. ការលុបចោលនៃកិច្ចសន្យាក្រុមហ៊ុន**

ក្នុងករណីដែលសហកម្មសិទ្ធិករណាម្នាក់បានបង្ហាញឆន្ទៈដោយមានវិការៈ ដោយសារការភាន់ច្រឡំ ការឆបោក ការគំរាមកំហែង ជាអាទិ៍ សហកម្មសិទ្ធិករនោះអាចលុបចោលកិច្ចសន្យាបាន។[29]

ភាពខុសគ្នារវាងមោឃភាព និងសកម្មភាពដែលអាចលុបចោលបាន គឺថា មោឃភាព មិនមានអានុភាពតាំងពីដំបូង ជនណាក៏អាចអះអាងនូវមោឃភាពនេះបានគ្រប់ពេល គឺមិនមានការរំលត់អាជ្ញាយុកាលឡើយ។ ផ្ទុយទៅវិញ នៅក្នុងករណីនៃសកម្មភាពដែលអាចលុបចោលបាន មានតែអ្នកមានសិទ្ធិលុបចោលទើបអាចលុបចោល ឬផ្តល់សច្ចានុមតិទៅលើសកម្មភាពនោះ ហើយគាត់អាចអនុវត្តសិទ្ធិនេះនៅក្នុងរយៈពេល ៣ ឆ្នាំ។[30]

នៅក្នុងករណីដែលមានវិការៈក្នុងការបង្ហាញឆន្ទៈ ជនដែលបានបង្ហាញឆន្ទៈដោយមានវិការៈ ឬអ្នកតំណាងដែលច្បាប់បានកំណត់របស់ជននោះអាចលុបចោលកិច្ចសន្យាបាន។ ទន្ទឹមនឹងនេះ សន្តតិជនរបស់ជនដែលបង្ហាញឆន្ទៈក៏អាចអនុវត្តសិទ្ធិលុបចោលបានដែរ។ នៅក្នុងករណីដែលសកម្មភាពត្រូវបានធ្វើឡើងដោយជនដែលគ្មានសមត្ថភាព ឬត្រូវបានគេកម្រិតសមត្ថភាពនោះ សាមីជន អ្នកតំណាងដែលច្បាប់បានកំណត់ ឬ ហិតូបត្ថម្ភកៈរបស់ជននោះ ឬសន្តតិជន ឬអច្ច័យលាភីសកលរបស់សាមីជននោះអាចលុបចោលបាន។ ការលុបចោលដែលធ្វើឡើងដោយជនដែលគ្មានសមត្ថភាព ឬ ត្រូវបានគេកម្រិតសមត្ថភាពមិនត្រូវបានគេចាត់

[27] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧,០៣០, ០៨ ធ្នូ ២០០៧ មាត្រា ៣៥៧

[28] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី,សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី (ភ្នំពេញ៖ ការិយាល័យកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌នៅក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា, ២០១០), ទំព័រ៦៦។

[29] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧,០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៤៥។

[30] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧,០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៦៣។

ទុកថាជា "សកម្មភាពដែលអាចលុបចោលបាននោះទេ ព្រោះជាទូទៅ ការបដិសេធនូវអានុភាពនៃសកម្មភាព ត្រូវបានចាត់ទុកថាជាការការពារនូវជននោះដែរ។

ការផ្តល់សច្ចានុមតិ គឺជាសកម្មភាពជាឯកភាគី ហើយវាត្រូវបានអានុភាពចាប់ពីពេលដែលការជូនដំណឹងនោះបានដល់ភាគីម្ខាងទៀត។ ប្រសិនបើជនដែលមានសិទ្ធិក្នុងការលុបចោល បានផ្តល់នូវសច្ចានុមតិចំពោះសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនោះត្រូវបានចាត់ទុកថាមានសុពលភាពជាស្ថាពរ។ នៅពេលជនដែលមានសិទ្ធិលុបចោលបានផ្តល់សច្ចានុមតិ នោះសកម្មភាពដែលអាចលុបចោលបាន មិនអាចត្រូវបានគេលុបចោលទៀតទេ។[31]

### ៣.២. អានុភាព

សកម្មភាព ដែលចាត់ទុកជាមោឃៈមិនមានអានុភាពតាំងពីដំបូងចាប់ពីធ្វើសកម្មភាព។ ប្រសិនបើភាគីបានអនុវត្តកាតព្វកិច្ចដោយផ្អែកលើកិច្ចសន្យាដែលត្រូវទុកជាមោឃៈ។ ជាទូទៅ ភាគីម្ខាងទៀតត្រូវសងតាវកាលិកនោះមកវិញដោយផ្អែកលើសេចក្តីចំរើនឥតហេតុ។ ម្យ៉ាងវិញទៀត កិច្ចសន្យាដែលបានបង្កើតឡើងដែលមានការឃុបឃិតជាមួយភាគីម្ខាងទៀត ត្រូវចាត់ទុកជាមោឃភាពដោយសារការបង្ហាញឆន្ទៈមិនពិត។ ការមោឃភាពនេះ គឺមិនអាចអះអាងចំពោះតតិយជនដែលមានទំនាក់ទំនងផលប្រយោជន៍ ដោយយកកិច្ចសន្យាដែលផ្អែកលើការបង្ហាញឆន្ទៈមិនពិតជាមូលដ្ឋានបានឡើយ។ នេះ គឺជាករណីលើកលែងដ៏សំខាន់មួយ។[32]

សកម្មភាពដែលអាចលុបចោលបាន មានសុពលភាពរហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោលសកម្មភាពនោះ។ ប្រសិនបើអ្នកដែលមានសិទ្ធិលុបចោលបានលុបចោលសកម្មភាពដែលអាចលុបចោលបាន សកម្មភាពនោះត្រូវបានចាត់ទុកជាមោឃៈតាំងពីដំបូង។[33] នៅក្នុងន័យម្យ៉ាងទៀត សកម្មភាពគឺមានសុពលភាព ទោះបីសកម្មភាពនោះអាចត្រូវបានគេលុបចោលក៏ដោយ ហើយការលុបចោល គឺជាការបង្ហាញឆន្ទៈក្នុងការបដិសេធនូវអានុភាពនោះ។ ក្នុងករណីដែលភាគីម្ខាងទៀតនៃសកម្មភាពដែលអាចលុបចោលបាន ត្រូវបានកំណត់ច្បាស់លាស់ ការលុបចោល ឬ សច្ចានុមតិត្រូវធ្វើឡើងដោយការជូនដំណឹងទៅភាគីម្ខាងទៀតនោះ។ អានុភាពនៃការលុបចោល ឬសច្ចានុមតិត្រូវកើតឡើងនៅពេលដែលដំណឹងនោះបានដល់ភាគីម្ខាងទៀតនោះ។ ការលុបចោល គឺជាសកម្មភាពឯកតោភាគី។ ដូច្នេះ ការលុបចោលត្រូវមានអានុភាព នៅពេលដែលការជូន

---

[31] ក្រុមការងារនៃអនាគតគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី, ភាគ១, (ភ្នំពេញ៖ គម្រោងអភិវឌ្ឍវិស័យច្បាប់ និងតុលាការរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA), ២០១៣), ទំព័រ ១១១។

[32] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧,០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៥៣។

[33] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧,០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៥៨។

ដំណឹងពីការលុបចោលនោះបានដល់ភាគីម្ខាងទៀត។[34]

**៣.៣. អាជ្ញាយុកាល**

ដោយផ្អែកទៅលើមាត្រា ៣៦៣ នៃក្រមរដ្ឋប្បវេណី បុគ្គលដែលមានសិទ្ធិលុបចោល ត្រូវតែអនុវត្តសិទ្ធិលុបចោល និងទាមទារអោយប្រគល់ត្រឡប់មកវិញ ដោយផ្អែកតាមសេចក្តីចម្រើនឥតហេតុ នៅក្នុងអំឡុងពេល ៣ ឆ្នាំ ចាប់តាំងពីថ្ងៃដែលសច្ចានុមតិអាចត្រូវបានផ្តល់។ ក្នុងករណីនេះ បញ្ញត្តិទាក់ទងនឹងការផ្អាកនៃអាជ្ញាយុកាលមិនត្រូវយកមកអនុវត្តឡើយ។ ទន្ទឹមនឹងនេះ សិទ្ធិលុបចោលត្រូវរលត់ដោយអំឡុងពេល ១០ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃសកម្មភាពនោះ។ ក្រោយពេលអាជ្ញាយុកាលរំលត់ត្រូវបានបញ្ចប់ នោះជនដែលមានសិទ្ធិលុបចោល មិនអាចលុបចោលសកម្មភាពដែលអាចលុបចោលនោះទៀតទេ ដូច្នេះ សកម្មភាពនោះត្រូវបានចាត់ទុកថា មានសុពលភាពជាស្ថាពរ។ ប្រសិនបើមានបុគ្គលច្រើននាក់មានសិទ្ធិលុបចោល នោះសិទ្ធិលុបចោលរបស់បុគ្គលម្នាក់ៗត្រូវរលត់រៀងៗខ្លួនដែលអនុវត្តទៅតាមកថាខណ្ឌទី១ និងទី២ នៃមាត្រា៣៦៣ ដដែលផងដែរ។

[34] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧,០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៦០។

# ជំពូកទី២
# ដំណើរការ និងការប្រព្រឹត្តិទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិ

ក្រុមហ៊ុនសហកម្មសិទ្ធិ គឺជារចនាសម្ព័ន្ធអាជីវកម្មដែលបុគ្គលជាច្រើនចែករំលែកភាពជាម្ចាស់ និងការទទួលខុសត្រូវសម្រាប់ប្រតិបត្តិការ។ អត្ថប្រយោជន៍ចម្បងគឺការប្រមូលផ្តុំធនធាន និងជំនាញ។ រចនាសម្ព័ន្ធនេះជំរុញឱ្យមានកិច្ចសហការ និងការសម្រេចចិត្តក្នុងចំណោមដៃគូ។ ហេតុដូចនេះ នៅផ្នែកខាងក្រោមនេះ នឹងបកស្រាយអំពីការប្រព្រឹត្តទៅនៃទម្រង់ក្រុមហ៊ុនសហកម្មសិទ្ធិ ដោយមាននូវការបញ្ជាក់ពីសិទ្ធិ និងកាតព្វកិច្ចនានាផងដែរ។

## ផ្នែកទី១៖ ការគ្រប់គ្រងក្រុមហ៊ុន

សហកម្មសិទ្ធិករទូទៅទាំងឡាយអាចតែងតាំងសហកម្មសិទ្ធិករទូទៅម្នាក់ ឬច្រើននាក់ ឬបុគ្គលដែលមិនមែនជាសហកម្មសិទ្ធិករទូទៅឱ្យគ្រប់គ្រងកិច្ចការជំនួសខ្លួននៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិនោះបាន។[35] អ្នកគ្រប់គ្រងអាចអនុវត្តរាល់សកម្មភាពនៅក្នុងសិទ្ធិអំណាចខ្លួន ហើយការប្រព្រឹត្តរបស់អ្នកគ្រប់គ្រងត្រូវជាប់កាតព្វកិច្ចនឹងក្រុមហ៊ុនសហកម្មសិទ្ធិនោះ។

ក្នុងការគ្រប់គ្រងក្រុមហ៊ុនផងដែរ សហកម្មសិទ្ធិករទាំងអស់អាចគ្រប់គ្រងក្រុមហ៊ុនដោយផ្ទាល់ក៏បាន ឬអាចជួលអ្នកក្រៅធ្វើជាគណៈគ្រប់គ្រងជំនួសក៏បាន។ នៅក្នុងការគ្រប់គ្រងដោយផ្ទាល់ គេអាចតែងតាំងតាមការយល់ព្រមដោយសម្លេងឯកច្ឆន្ទ ឬភាគច្រើនដោយជៀបឲ្យអ្នកណាម្នាក់ជាសហកម្មសិទ្ធិករគ្រប់គ្រង និងសហកម្មសិទ្ធិករផ្សេងទៀតទទួលខុសត្រូវតាមផ្នែកផ្សេងៗ ដូចជាផ្នែកហិរញ្ញវត្ថុ, ផ្នែកទីផ្សារ។ គេត្រូវពិពណ៌នាអំពីភារៈកិច្ច និងអំណាចរបស់សហកម្មសិទ្ធិករម្នាក់ៗនៅក្នុងការគ្រប់គ្រង។ នៅក្នុងករណីនៃការគ្រប់គ្រងដោយគណៈគ្រប់គ្រង សហកម្មសិទ្ធិករអាចធ្វើប្រតិភូកម្មអំណាចមួយផ្នែកឲ្យទៅគណៈគ្រប់គ្រង ដើម្បីអាចធ្វើសេចក្តីសម្រេចលើរឿងខ្លះ ដោយមិនចាំបាច់មានការយល់ព្រមពីខ្លួន។[36]

### ១.១ ការជ្រើសតាំងអ្នកគ្រប់គ្រង

ចំពោះការគ្រប់គ្រងក្រុមហ៊ុន អាចធ្វើការជ្រើសតាំងដោយសហកម្មសិទ្ធិករទូទៅ ហើយការជ្រើសតាំងនោះ គឺត្រូវមើលទៅលើសមត្ថភាពពិតប្រាកដក្នុងការដឹកនាំក្រុមហ៊ុនឱ្យមានការរីកចម្រើន។ គេមិនសូវជ្រើសរើសយកតតិយជនឱ្យធ្វើជាអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនទេ ដោយហេតុថា ជាក្រុមហ៊ុនដែលមានការទទួលខុសត្រូវ

[35] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសរកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៣៥។
[36] កុយនាម, *ច្បាប់ក្រុមហ៊ុន*, ការផ្សាយលើកទី១ (ឧត្តមការបោះពុម្ពពីលោកមេធាវី សួន វិសាល, ២០១៦), ទំព័រ១៩៥។

ដោយគ្មានកំណត់ និងដោយសាមគ្គី ដូច្នេះគេមិនសូវមានភាពជឿទុកចិត្តខ្លាំង ក្រៅពីសមាជិកភាគហ៊ុនដែលមានសមត្ថភាពនោះទេ លើកលែងតែសហកម្មសិទ្ធិករមិនមានពេល ឬមានភារៈកិច្ច ហេតុនេះទើបមានការជួលអ្នកក្រៅធ្វើជំនួស ដោយមានកិច្ចសន្យា និងបានចែងពីអំណាចច្បាស់លាស់។ [37]

ក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត មានតែសហកម្មសិទ្ធិករទូទៅប៉ុណ្ណោះដែលមានសិទ្ធិក្នុងការចាត់ចែង និងដឹកនាំក្រុមហ៊ុន ហើយក៏ជាអ្នកទទួលខុសត្រូវទាំងស្រុង។ ប៉ុន្តែ សហកម្មសិទ្ធិករមានកម្រិតអាចផ្តល់យោបល់ខ្លះៗ។[38] ដោយសារសហកម្មសិទ្ធិករមានកម្រិត គ្រាន់តែជាអ្នកវិនិយោគ ដើម្បីរកប្រាក់ចំណេញប៉ុណ្ណោះ គាត់មិនមានសិទ្ធិចូលរួមក្នុងការចាត់ចែងក្រុមហ៊ុនទេ។ សហកម្មសិទ្ធិករមានកម្រិតអាចដឹកនាំការងារក្រុមហ៊ុនបានក្នុងករណីសហកម្មសិទ្ធិករទូទៅមិនអាចបំពេញការងារពាណិជ្ជកម្មតទៅមុខទៀតបាន ប៉ុន្តែការដឹកនាំការងារនោះគ្រាន់តែបំពេញការងាររដ្ឋបាលប្រចាំថ្ងៃដែលជាតម្រូវការក្នុងដំណើរការគ្រប់គ្រងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតប៉ុណ្ណោះ ។

### ១.២ ការដកហូតអ្នកគ្រប់គ្រង

អ្នកគ្រប់គ្រងត្រូវដកហូតចេញពីមុខតំណែង ដោយសំលេងភាគច្រើនធៀបនឹងវត្តមានរបស់សហកម្មសិទ្ធិករទូទៅទាំងឡាយក្នុងពេលបោះឆ្នោត លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ អ្នកគ្រប់គ្រងត្រូវបញ្ចប់ពីមុខតំណែងក្នុងករណីដល់កាលកំណត់ ទទួលមរណៈភាព អសម្ថតភាព ត្រូវបានដកហូតមុខតំណែងដោយសារមានកំហុស និងការសុំលាលែងពីមុខងារ។ ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម អនុញ្ញាតឲ្យសម្លេងភាគច្រើនដោយធៀបនៃសហកម្មសិទ្ធិករដែលមានវត្តមាននៅក្នុងកិច្ចប្រជុំអាចដកហូតបាន។[39]

## ផ្នែកទី២៖ សិទ្ធិ និងករណីយកិច្ចរបស់សហកម្មសិទ្ធិករទូទៅ

នៅពេលដែលក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវបានបង្កើតឡើង ភាគីទាំងឡាយនៃកិច្ចសន្យាបង្កើតនោះ ត្រូវជាប់កាតព្វកិច្ច និងទទួលបានសិទ្ធិនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិចាប់ពីពេលដែលកិច្ចសន្យានោះត្រូវបានធ្វើឡើងចប់សព្វគ្រប់។ ប្រសិនបើកិច្ចសន្យានោះមានការចែងផ្សេង ដែលត្រូវជាប់កាតព្វកិច្ច នោះភាគីត្រូវអនុវត្តតាមការចែងនោះ។

[37] កៅ មុយថង, *ច្បាប់ពាណិជ្ជកម្ម*, បោះពុម្ពលើកទី៣ (ភ្នំពេញ៖ អង្គរ, ២០១៥),ទំព័រ១៩៨។

[38] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសររកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៧៩។

[39] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសររកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៣៥។

### ១.១ សិទ្ធិរបស់សហកម្មសិទ្ធិករទូទៅ

សហកម្មសិទ្ធិករទូទៅ ទទួលបានសិទ្ធិនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិតាមរយៈការកំណត់នៅក្នុងកិច្ចសន្យាបង្កើតក្រុមហ៊ុន និងបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។ សិទ្ធិទាំងនោះទាក់ទងនឹងបេតិកភណ្ឌ និងទំនាក់ទំនងរវាងសហកម្មសិទ្ធិករនៅក្នុងក្រុមហ៊ុន។ សិទ្ធិសំខាន់ៗមួយចំនួនដែលសហកម្មសិទ្ធិករទូទៅម្នាក់ៗត្រូវមានដូចជា៖

#### ក. សិទ្ធិទទួលចំណែកនៃប្រាក់ចំណេញ

ប្រាក់ចំណេញគឺជាគោលដៅចំបងនៃការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ។ របៀបបែងចែកប្រាក់ចំណេញត្រូវធ្វើឡើងស្របទៅតាមការព្រមព្រៀងគ្នារវាងសហកម្មសិទ្ធិករ។ បើកិច្ចសន្យា មិនបានចែងពីរបៀបបែងចែកប្រាក់ចំណេញទេនោះ ច្បាប់សន្មតថា សហកម្មសិទ្ធិករទាំងអស់ ត្រូវបានទទួលប្រាក់ចំណេញក្នុងចំណែកស្មើគ្នា នេះជាវិធានស្វ័យប្រវត្តិដែលកំណត់ដោយច្បាប់។

ក្នុងចំណុចនេះ នៅក្នុងក្រមរដ្ឋប្បវេណីមាត្រា ៧០៦ ទាមទារឲ្យសមាជិកក្រុមហ៊ុនកំណត់ពេលទៀងទាត់ ដូចជាមួយឆ្នាំម្តងជាដើម ដើម្បីគិតគូរចំនួនដែលក្រុមហ៊ុនបានចំណេញឬខាត ហើយបើមានចំណេញសមាជិកក្រុមហ៊ុនអាចទាមទារឲ្យមានការចែកផលចំណេញរវាងសមាជិកទាំងអស់។ ការបែងចែកប្រាក់ចំណេញតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី គឺផ្អែកលើសមាមាត្រនៃចំនួនទឹកប្រាក់ដែលសហកម្មសិទ្ធិករម្នាក់ៗបានរួមចំណែកទុននៅក្នុងក្រុមហ៊ុន នៅពេលណាកិច្ចសន្យាក្រុមហ៊ុនមិនបានចែងជាមុន នូវភាគចំណេញដែលសមាជិកនីមួយៗត្រូវទទួល។ នេះគឺផ្ទុយពីច្បាប់សហគ្រាសពាណិជ្ជកម្ម ដែលចែងថា សហកម្មសិទ្ធិករម្នាក់ៗត្រូវទទួលភាគចំណេញស្មើគ្នា នៅពេលណាកិច្ចសន្យាក្រុមហ៊ុនមិនបានកំណត់ភាគចំណេញដែលត្រូវទទួល។[40]

#### ខ. សិទ្ធិក្នុងការកាន់កាប់និងប្រើប្រាស់ទ្រព្យសម្បត្តិក្រុមហ៊ុន

សហកម្មសិទ្ធិករមានផលប្រយោជន៍ស្មើគ្នានៅក្នុងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនដែរ លើកលែងតែនៅពេលចុះកិច្ចសន្យាបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ សហកម្មសិទ្ធិករម្នាក់ៗចែងបញ្ជាក់ពីទំហំនៃផលប្រយោជន៍របស់ខ្លួននៅក្នុងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ដើម្បីកំណត់ពីសមាមាត្រនៃផលប្រយោជន៍របស់ខ្លួននៅក្នុងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន។[41] សហកម្មសិទ្ធិករទូទៅអាចកំណត់ពីតម្លៃសរុបនៃទ្រព្យសម្បត្តិ ដែលបានដាក់ចូលក្នុងក្រុមហ៊ុនហើយកំណត់ភាគរយនៃតម្លៃទ្រព្យសម្បត្តិ។

សហកម្មសិទ្ធិករទូទៅជាម្ចាស់រួមលើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ដូច្នេះ សហកម្មសិទ្ធិករម្នាក់ៗមាន

[40] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧,០៣០, ០៨ ធ្នូ ២០០៧ មាត្រា៧០៦។

[41] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសរកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២៤។

សិទ្ធិស្មើគ្នាក្នុងការកាន់កាប់ទ្រព្យនិងប្រើប្រាស់សម្បត្តិនោះក្នុងនាមនៃក្រុមហ៊ុន។ ប៉ុន្តែ សហកម្មសិទ្ធិករមិនអាចប្រើប្រាស់ទ្រព្យសម្បត្តិនោះជាប្រយោជន៍ផ្ទាល់ខ្លួនបានទេ លើកលែងតែមានការយល់ព្រមពីសហកម្មសិទ្ធិករដទៃទៀត។ សហកម្មសិទ្ធិករដែលយកទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនទៅប្រើដោយគ្មានការយល់ព្រមពីសហកម្មសិទ្ធិករដទៃទៀត មិនអាចទទួលផលកម្រៃដែលកើតចេញពីការប្រើប្រាស់នោះទេ។

នៅមាត្រា ២៦ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម បានចែងថា៖ គ្មានសហកម្មសិទ្ធិករទូទៅណាម្នាក់ត្រូវទទួលប្រាក់បៀវត្សពីការធ្វើពាណិជ្ជកិច្ចក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឡើយ។ ក៏ប៉ុន្តែ សហកម្មសិទ្ធិករទាំងអស់អាចចែងនៅក្នុងកិច្ចសន្យាក្រុមហ៊ុន ដើម្បីអនុញ្ញាតឲ្យសហកម្មសិទ្ធិករដែលចំណាយពេលវេលារបស់ខ្លួន ដែលធ្វើការឲ្យក្រុមហ៊ុនបានទទួលការទូទាត់ចំពោះសេវាកម្មរបស់ខ្លួន។ តែកិច្ចសន្យាត្រូវចែងពីការទូទាត់សេវាកម្មរបស់សហកម្មសិទ្ធិករម្នាក់ៗ ក្នុងឋានៈជានិយោជិតរបស់ក្រុមហ៊ុនដែលនឹងត្រូវកំណត់ដោយកិច្ចសន្យាការងារ ព្រមទាំងចែងពីពេលណាដែលសហកម្មសិទ្ធិករអាចដកយកប្រាក់ចំណេញបានហើយក្នុងអត្រាប៉ុន្មាន ដោយពេលខ្លះក្រុមហ៊ុនត្រូវការរក្សាទុកប្រាក់ចំណេញខ្លះ ដើម្បីពង្រីកអាជីវកម្ម។[42]

សហកម្មសិទ្ធិករក៏មានសិទ្ធិទទួលបានប្រាក់ពីក្រុមហ៊ុននូវការទូទាត់ការចំណាយនោះមកវិញ ដោយសហកម្មសិទ្ធិករបានចំណាយប្រាក់ផ្ទាល់ខ្លួនដើម្បីធ្វើការអ្វីមួយជាប្រយោជន៍ដល់ក្រុមហ៊ុន ក៏ដូចជាកម្ចីរបស់សហកម្មសិទ្ធិករនោះទៅឲ្យក្រុមហ៊ុន។ ការចំណាយនេះត្រូវធ្វើនៅក្នុងវង្វង់កិច្ចការអាជីវកម្មរបស់ក្រុមហ៊ុន និងដោយភាពស្មោះត្រង់។[43]

មាត្រា ៣៧ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មចែងថា៖ សហកម្មសិទ្ធិករទូទៅត្រូវបានចាត់ទុកថាមានសិទ្ធិគ្រប់គ្រងរាល់កិច្ចការរបស់ ក្រុមហ៊ុនសហកម្មសិទ្ធិករទូទៅនោះ។ សកម្មភាពដែលបានអនុវត្តដោយសហកម្មសិទ្ធិករទូទៅម្នាក់ ដែលទាក់ទងនឹងសកម្មភាពរួមរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ក៏ត្រូវជាប់កាតព្វកិច្ចទៅនឹងសហកម្មសិទ្ធិករទូទៅផ្សេងទៀតដែរ។ តាមមាត្រានេះ សហកម្មសិទ្ធិករម្នាក់ៗជាម្ចាស់ក្រុមហ៊ុន មានសិទ្ធិនៅក្នុងការគ្រប់គ្រងក្រុមហ៊ុន មិនអាចមាននរណាលុបសិទ្ធិរបស់សហកម្មសិទ្ធិករបានឡើយ។ សិទ្ធិរបស់សហកម្មសិទ្ធិករក្នុងការចូលរួមក្នុងការគ្រប់គ្រងជាសិទ្ធិដែលមិនអាចដកហូតបាន។ តែមាត្រានេះមិនបានចែងបញ្ជាក់ថា សហកម្មសិទ្ធិករទូទៅមានសិទ្ធិ "ស្មើគ្នា" ឬ "មិនស្មើគ្នា" នៅក្នុងការគ្រប់គ្រងក្រុមហ៊ុនឡើយ។[44] សហកម្មសិទ្ធិករម្នាក់អាចជ្រើសរើសថាខ្លួនចូលគ្រប់គ្រងដោយផ្ទាល់ ឬទុកឲ្យសហកម្មសិទ្ធិករដទៃ

---

[42] ច្បាប់សហគ្រាសពាណិជ្ជកម្ម, លេខ នសរកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២៦

[43] កុយនាម, *ច្បាប់ក្រុមហ៊ុន*, ការផ្សាយលើកទី១ (ឧត្តមការបោះពុម្ពពីលោកមេធាវី សួន វិសាល, ២០១៦), ទំព័រ១៣២។

[44] កុយនាម, *ច្បាប់ក្រុមហ៊ុន*, ការផ្សាយលើកទី១ (ឧត្តមការបោះពុម្ពពីលោកមេធាវី សួន វិសាល, ២០១៦), ទំព័រ១២៣។

ទៀត ឬអ្នកក្រៅណាមួយផ្សេងទៀតឲ្យគ្រប់គ្រងក្រុមហ៊ុនជំនួសខ្លួនក៏បាន។ សហកម្មសិទ្ធិករដែលផ្តល់សិទ្ធិឲ្យសហកម្មសិទ្ធិករដទៃទៀតចាត់ចែងកិច្ចការជំនួសខ្លួននៅតែមានសិទ្ធិចូលរួមនៅក្នុងការសម្រេចលើកិច្ចការណាមួយតាមចិត្តចង់របស់គេ។[45]

**គ. សម្លេងចាំបាច់ក្នុងការធ្វើសេចក្តីសម្រេច**

សិទ្ធិចូលរួមនៅក្នុងការចាត់ចែងក្រុមហ៊ុនជាសិទ្ធិដាច់ខាតដែលសហកម្មសិទ្ធិកររាល់រូបត្រូវមានអាចព្រមព្រៀងគ្នា ដើម្បីកំណត់ចំនួនសម្លេងដែលអាចអនុម័តលើកិច្ចការអ្វីមួយដោយមាន សុពលភាព។ បើគ្មានការព្រមព្រៀងគ្នាដើម្បីកំណត់ចំនួនសម្លេងជាក់លាក់ណាមួយ ដើម្បីអនុម័តលើកិច្ចការរបស់ក្រុមហ៊ុននោះទេ ច្បាប់សន្មតថា សម្លេងភាគច្រើនដោយធៀបអាចអនុម័តលើកិច្ចការណាមួយប្រកបដោយសុពលភាព។ យោងតាមមាត្រា ៣៨ កថាខណ្ឌទី ២៖ លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ រាល់សេចក្តីសម្រេចត្រូវធ្វើឡើងដោយការបោះឆ្នោតតាមសំឡេងភាគច្រើន ដោយប្រៀបរបស់សហកម្មសិទ្ធិករទូទៅ ដោយមិនគិតតម្លៃអត្ថប្រយោជន៍របស់គេនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះទេ។ ប៉ុន្តែ សេចក្តីសម្រេចក្នុងការកែប្រែកិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវធ្វើឡើងដោយសំឡេងឆ្នោតជាឯកច្ឆន្ទ។ តាមមាត្រានេះ សហកម្មសិទ្ធិករម្នាក់ៗមានសម្លេងស្មើគ្នា ទោះបីសហកម្មសិទ្ធិករណាមួយមានភាគទុនតិចជាងសហកម្មសិទ្ធិករផ្សេងទៀតក៏ដោយ មានន័យថាសហកម្មសិទ្ធិករម្នាក់អាចបោះឆ្នោតបានមួយសម្លេងដូចគ្នា។ ប៉ុន្តែការសម្រេចដែលយកជាការបានលុះត្រាតែមានសម្លេងភាគច្រើនដោយធៀប។[46]

ផ្ទុយទៅវិញ នៅក្នុងក្រមរដ្ឋប្បវេណីមាត្រា ៧០២ បានលើកឡើងថាបើកិច្ចសន្យាក្រុមហ៊ុនពុំបានកំណត់ឲ្យសហកម្មសិទ្ធិករណាម្នាក់ ឬតតិយជនណាម្នាក់ទទួលអនុវត្តកិច្ចការក្នុងកិច្ចសន្យាក្រុមហ៊ុនទេ នោះសហកម្មសិទ្ធិករម្នាក់ៗមានអំណាចពេញលេញក្នុងអនុវត្តកិច្ចការដែលមានចែងក្នុងកិច្ចសន្យាក្រុមហ៊ុន ប៉ុន្តែកិច្ចការនោះត្រូវបានអនុម័តដោយសម្លេងភាគច្រើននៃសហកម្មសិទ្ធិករទាំងអស់។ ក្នុងករណីដែលកិច្ចសន្យាបានកំណត់ឲ្យសហកម្មសិទ្ធិករលើសពីម្នាក់ទទួលការអនុវត្តកិច្ចការក្នុងកិច្ចសន្យាក្រុមហ៊ុន ការអនុវត្តកិច្ចការនោះត្រូវសម្រេចដោយសម្លេងភាគច្រើននៃអ្នកដែលទទួលភារៈអនុវត្តកិច្ចការនោះ។[47]

**ឃ. សិទ្ធិទទួលព័ត៌មានពីអាជីវកម្ម**

ដើម្បីចូលរួមក្នុងការគ្រប់គ្រងក្រុមហ៊ុន សហកម្មសិទ្ធិករម្នាក់ៗត្រូវមានសិទ្ធិទទួលបានព័ត៌មានដោយពេញលេញ អំពីកិច្ចការទាំងអស់ និងអំពីរបៀបដែលអាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានដឹកនាំ។ ការដែលសហកម្ម

[45] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសរកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៣៤។

[46] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសរកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៣៨។

[47] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧,០៣០, ០៨ ធ្នូ ២០០៧ មាត្រា៧០២។

សិទ្ធិករខ្លះទុកឲ្យសហកម្មសិទ្ធិករដទៃទៀតជំនួស មិនមានន័យថាសហកម្មសិទ្ធិករដែលមិនគ្រប់គ្រងដោយផ្ទាល់បានបោះបង់សិទ្ធិទទួលព័ត៌មានពីប្រតិបត្តិការរបស់ក្រុមហ៊ុនឡើយ។ សហកម្មសិទ្ធិករម្នាក់ៗមានសិទ្ធិស៊ើបអង្កេតទង្វើទាំងឡាយរបស់ក្រុមហ៊ុនដើម្បីដឹងច្បាស់ថា អាជីវកម្មរបស់ក្រុមហ៊ុនបានប្រព្រឹត្តទៅដោយមានការគោរពគោលការណ៍សុទ្ធចិត្ត និងការអនុវត្តល្អរបស់ក្រុមហ៊ុន។ សហកម្មសិទ្ធិករដែលគ្រប់គ្រងក្រុមហ៊ុនត្រូវបំពេញករណីយកិច្ចបើកចំហឲ្យសហកម្មសិទ្ធិករដទៃទៀតអនុវត្តសិទ្ធិរបស់គេ ដើម្បីដឹងពីព័ត៌មានទាំងអស់របស់ក្រុមហ៊ុន។

មាត្រា ៣៩នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មចែងថា៖ សហកម្មសិទ្ធិករទូទៅម្នាក់ៗមានសិទ្ធិទទួលព័ត៌មានអំពីកិច្ចការទាំងឡាយរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ហើយមានសិទ្ធិពិគ្រោះយោបល់លើសៀវភៅ បញ្ជី និងកំណត់ហេតុ ទោះបីជាសហកម្មសិទ្ធិករទូទៅនោះគ្មានតួនាទីជាអ្នកគ្រប់គ្រងក៏ដោយ។ នៅក្នុងការអនុវត្តសិទ្ធិនេះ សហកម្មសិទ្ធិករទូទៅមិនត្រូវបង្អាក់កិច្ចប្រតិបត្តិការរបស់ក្រុមហ៊ុនដោយគ្មានហេតុផលត្រឹមត្រូវ ឬមិនត្រូវធ្វើឲ្យរាំងស្ទះដល់សហកម្មសិទ្ធិករទូទៅផ្សេងទៀតក្នុងការអនុវត្តសិទ្ធិដូចគ្នាឡើយ។[48] តាមមាត្រានេះ សិទ្ធិទទួលព័ត៌មានពីអាជីវកម្មរួមមានសិទ្ធិត្រួតពិនិត្យ បញ្ជី របាយការណ៍ ផែនការ និងសកម្មភាពរបស់ក្រុមហ៊ុន។ គេអាចពិនិត្យបញ្ជី និងឯកសារដទៃទៀតដោយខ្លួនឯងផ្ទាល់ ឬតែងតាំងអ្នកតំណាងម្នាក់ឲ្យពិនិត្យជំនួសបាន។ សិទ្ធិទទួលព័ត៌មាននាំឲ្យមានកាតព្វកិច្ចត្រូវផ្តល់ព័ត៌មានដល់សហកម្មសិទ្ធិករផងដែរ។ ហើយក្រុមហ៊ុនត្រូវរក្សាទុកនូវសៀវភៅបញ្ជី និងកំណត់ហេតុផងទាំងឡាយនៅទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុន។[49]

### ខ. សិទ្ធិធ្វើអាជីវកម្មដោយឡែក

សហកម្មសិទ្ធិករម្នាក់អាចប្រកបអាជីវកម្មណាមួយដោយឡែកក្រៅពីអាជីវកម្មរបស់ក្រុមហ៊ុនសហកម្មសិទ្ធិដែលខ្លួនជាសមាជិក កាលណាគ្មានកិច្ចព្រមព្រៀងដែលកម្រិតពីសិទ្ធិនេះ។ សិទ្ធិនេះកើតចេញពីគោលការណ៍នៃកាតព្វកិច្ចស្មោះត្រង់ដែលចែងនៅក្នុងមាត្រា ២៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ដែលសហកម្មសិទ្ធិករមិនមានភាពប្រកួតប្រជែងជាមួយក្រុមហ៊ុន។[50]

## ១.២ ករណីយកិច្ចរបស់សហកម្មសិទ្ធិករទូទៅ

នៅពេលដែលក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវបានបង្កើតឡើង ភាគីទាំងឡាយនៃកិច្ចសន្យាបង្កើតនោះ ត្រូវជាប់កាតព្វកិច្ចចំពោះក្រុមហ៊ុនចាប់ពីពេលដែលកិច្ចសន្យានោះត្រូវបានធ្វើឡើងចប់សព្វគ្រប់។ ប្រសិនបើកិច្ចសន្យានោះមានការចែងផ្សេង ដែលត្រូវជាប់កាតព្វកិច្ច នោះភាគីត្រូវអនុវត្តតាមការចែងនោះ។

[48] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៣៩។

[49] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា១៥, កថាខណ្ឌទី២។

[50] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នស/រកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២៨។

ករណីយកិច្ចសំខាន់ៗដែលសហកម្មសិទ្ធិករទូទៅម្នាក់ៗត្រូវបំពេញមានដូចតទៅ៖

**ក. ករណីយកិច្ចសហកម្មសិទ្ធិករត្រូវអនុវត្តតាមកិច្ចសន្យា**

កិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិ ជាឯកសារគោលនៃការបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិ ហើយបង្កើតនូវសិទ្ធិ និងកាតព្វកិច្ចរបស់សហកម្មសិទ្ធិករ មានចែងពីធាតុនៃអាជីវកម្ម, ដើមទុន, ចំណែកទុន, សិទ្ធិ, អំណាច, ករណីយកិច្ច, ការបែងចែកផលចំណេញ, ការរំលែកការខាតបង់។ល។

សហកម្មសិទ្ធិករទូទៅនីមួយៗ ត្រូវគោរពប្រតិបត្តិតាមអ្វីដែលខ្លួនបានយល់ព្រមនៅពេលបង្កើតក្រុមហ៊ុន លើកលែងមានភាពខុសពីច្បាប់។ ទោះសហកម្មសិទ្ធិករមិនបានធ្វើកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរក្តី ក៏នៅតែមានករណីយកិច្ចគោរពតាមការព្រមព្រៀងផងដែរ។ នៅពេលដែលកិច្ចសន្យាក្រុមហ៊ុនសហកម្មសិទ្ធិមានចំណុចចែងមិនច្បាស់ វិធាននៃការបកស្រាយកិច្ចសន្យាទូទៅត្រូវយកមកអនុវត្ត។ គេត្រូវពិនិត្យទៅលើចេតនារបស់សហកម្មសិទ្ធិករនៅពេលបង្កើតកិច្ចសន្យា ដោយឈរលើខចែងនៃកិច្ចសន្យា និងកាលៈទេសៈនៅជុំវិញការបង្កើតកិច្ចសន្យានោះ។[51]

**ខ.ករណីយកិច្ចសហកម្មសិទ្ធិករត្រូវមានសុចរិតធម៌**

សហកម្មសិទ្ធិករម្នាក់ៗត្រូវសំដែងសេចក្តីស្មោះត្រង់ និងផ្តល់ទំនុកចិត្តដល់គ្នាទៅវិញទៅមកនៅរាល់ប្រតិបត្តិការទាំងអស់ ចាប់ពីពេលចរចាបង្កើតក្រុមហ៊ុនរហូតដល់ការរំលាយក្រុមហ៊ុន។ សហកម្មសិទ្ធិករម្នាក់ៗក៏ត្រូវមានករណីយកិច្ចជាឆ្មាំការពារផលប្រយោជន៍របស់ក្រុមហ៊ុនផងដែល។ នេះជាករណីយកិច្ចដ៏សំខាន់ នៅពេលដែលអ្នកណាម្នាក់សុខចិត្តសុខកាយចូលរួមអាជីវកម្មជាមួយគ្នា។[52]

នៅក្នុងក្រមរដ្ឋប្បវេណីមាត្រា ៧០៣ ចែងពីករណីយកិច្ចត្រូវប្រុងប្រយ័ត្នរបស់អាណត្តិគាហកដែលត្រូវអនុវត្តចំពោះសហកម្មសិទ្ធិករដែរ។ បញ្ញត្តិចាប់ពីមាត្រា ៦៤០ (ករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក) រហូតដល់មាត្រា ៦៤៧ (សិទ្ធិទាមទារឲ្យសងវិញជាអាទិ៍នូវសោហ៊ុយរបស់អាណត្តិគាហក) នៃក្រមនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការរបស់ក្រុមហ៊ុន។ នៅមាត្រា ៦៤០នៃក្រមរដ្ឋប្បវេណី បានបញ្ញត្តិអំពី ការបំពាក់ករណីយកិច្ចដល់អ្នកទទួលអាណត្តិ ត្រូវមានសុចរិតធម៌ដាច់ខាតនៅក្នុងការចាត់ចែងកិច្ចការដែលអាណត្តិទាយកប្រគល់ឲ្យ។

**គ.ករណីយកិច្ចត្រូវបង់ភាគទុន**

សហកម្មសិទ្ធិករមួយអាចមិនទាន់បានបង់ភាគទុនរបស់ខ្លួននៅពេលបង្កើតក្រុមហ៊ុន សហកម្មសិទ្ធិករនោះនៅជំពាក់ក្រុមហ៊ុននូវចំនួនប្រាក់ ឬវត្ថុមានតម្លៃដែលខ្លួនបានសន្យាចូលរួមក្នុងក្រុមហ៊ុន។ សហកម្ម

---

[51] កុយនាម, *ច្បាប់ក្រុមហ៊ុន*, ការផ្សាយលើកទី១ (ឧត្តម្ភការបោះពុម្ពពីលោកមេធាវី សួន វិសាល, ២០១៦), ទំព័រ១៣៥។

[52] ច្បាប់សហគ្រាសពាណិជ្ជកម្ម, លេខ នសរកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២៥។

សិទ្ធិករនោះត្រូវទទួលខុសត្រូវចំពោះការខាតបង់របស់ក្រុមហ៊ុន ថ្វីបើខ្លួនពុំទាន់បានបង់ភាគទុនចូលក្នុងក្រុមហ៊ុនក៏ដោយ។ នៅពេលដែលក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវបានបង្កើតឡើង ភាគីនៃកិច្ចសន្យា ត្រូវជាប់កាតព្វកិច្ចចាប់ពីពេលដែលកិច្ចសន្យានោះត្រូវបានធ្វើឡើងចប់សព្វគ្រប់លើកលែងតែកិច្ចសន្យាមានចែងផ្សេងពីនេះ។ យោងតាមមាត្រា១១ នោះគេមិនអាចប្រកែកថា ខ្លួនគេនៅមិនទាន់ក្លាយខ្លួនជាសហកម្មសិទ្ធិករនៃក្រុមហ៊ុននៅឡើយទេ លើកលែងតែកិច្ចសន្យាបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិអនុញ្ញាតឲ្យភាគីនោះរួចពីកាតព្វកិច្ចនោះ។[53] ចំពោះភាគីដែលយឺតយ៉ាវក្នុងការបង់ភាគទុនត្រូវទទួលខុសត្រូវក្នុងការបង់ចុងការប្រាក់សំរាប់រយៈពេលចាប់ពីពេលចុះកិច្ចសន្យារហូតដល់ថ្ងៃបង់ភាគទុនផងដែរ។ ផ្ទុយទៅវិញ ការដកទុនរបស់សហកម្មសិទ្ធិករទូទៅនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅគួរមានចែងក្នុងកិច្ចសន្យាដែលហាមឃាត់មិនឲ្យមានការដកភាគទុនរបស់សហកម្មសិទ្ធិករទូទៅម្នាក់ៗ ព្រោះវាធ្វើឲ្យមានការប៉ះពាល់ដល់ប្រតិបត្តិការរបស់ក្រុមហ៊ុន អាចឲ្យក្រុមហ៊ុនជួបបញ្ហាផ្នែកសេដ្ឋកិច្ចផងដែល។[54]

រីឯការបង់ទុននៃក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតវិញ ការបង់ភាគទុនរបស់សហកម្មសិទ្ធិករមានកម្រិតអាចជាទឹកប្រាក់ ឬជាទ្រព្យសម្បត្តិតែប៉ុណ្ណោះ។ សហកម្មសិទ្ធិករមានកម្រិតអាចបន្ថែមភាគទុនបាននៅគ្រប់ពេលវេលា។ ការបង់ភាគទុនរបស់សហកម្មសិទ្ធិករទូទៅ អាចជាសាច់ប្រាក់ ជាវត្ថុ ជាសេវាពីមុនដែលកំពុងបន្តនាពេលបច្ចុប្បន្ន ឬជាការសន្យាថានឹងផ្តល់សេវានាពេលអនាគត។ សហកម្មសិទ្ធិករមានកម្រិត អាចធ្វើបានចំពោះតែការបង់ភាគទុនជាសាច់ប្រាក់ ឬជាវត្ថុប៉ុណ្ណោះ។ ការបង់ជាវត្ថុត្រូវគណនាជាសាច់ប្រាក់ដូចក្នុងករណីសហកម្មសិទ្ធិករទូទៅ។[55] សម្រាប់ការដកទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត សហកម្មសិទ្ធិករមានកម្រិតមិនអាចដកហូតយកចំណែកនៃភាគទុនរបស់ខ្លួនបានទេ លើកលែងតែមានការយល់ព្រមពីមតិភាគច្រើនដាច់ខាតនៃសហកម្មសិទ្ធិករទាំងអស់ និងក្រោយពីការដកនោះទ្រព្យសម្បត្តិដែលនៅសល់ក្នុងក្រុមហ៊ុនមានគ្រប់គ្រាន់ ដើម្បីដោះបំណុលរបស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះបាន។[56] នេះមិនមានន័យថា សហកម្មសិទ្ធិករមិនអាចដកហូតយកភាគទុនរបស់ខ្លួនវិញនោះទេ សហកម្មសិទ្ធិករមានកម្រិតមានសិទ្ធិដកវិនិយោគរបស់ខ្លួនក្រោមលក្ខខណ្ឌពីរះ

- មានការយល់ព្រមពីសហកម្មសិទ្ធិករដទៃទៀត ច្រើនជាងពាក់កណ្តាលទាំងទូទៅទាំងមានកម្រិត។ គឺដូចដែលបានបកស្រាយខាងលើ គឺត្រូវមានការឯកភាពច្រើនជាងពាក់កណ្តាលនៃក្រុមហ៊ុនទាំងសហ

[53] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសររកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា១១។

[54] កុយនាម, *ច្បាប់ក្រុមហ៊ុន*, ការផ្សាយលើកទី១ (ឧត្តមការបោះពុម្ពពីលោកមេធាវី សួន វិសាល, ២០១៦), ទំព័រ១៩៣។

[55] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសររកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៧០។

[56] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសររកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៧៧។

កម្មសិទ្ធិករទូទៅ និងសហកម្មសិទ្ធិករមានកម្រិត។

- ទ្រព្យសម្បត្តិក្រុមហ៊ុនរួមទាំងភាគទុនរបស់សហកម្មសិទ្ធិករមានកម្រិតផង មានច្រើនជាងបំណុល ក្រោយពេលដកភាគទុនរបស់សហកម្មសិទ្ធិករមានកម្រិត។ មានន័យថានៅពេលសហកម្មសិទ្ធិករ មានកម្រិតចង់ដកទុន នោះទ្រព្យដែលក្រុមហ៊ុនមានទាំងអស់ដែលនៅសល់ត្រូវនៅមានឲ្យច្រើនជាង បំណុលដែលជំពាក់។

**ឃ. ករណីយកិច្ចរួមចំណែកក្នុងការខាតបង់**

សហកម្មសិទ្ធិករទូទៅម្នាក់ត្រូវរួមចំណែកការខាតបង់របស់ក្រុមហ៊ុនក្នុងចំណែកស្មើគ្នា មិនថាសហកម្មសិទ្ធិករណាម្នាក់បានរួមចំណែកភាគទុនច្រើន ឬតិចទេ។ ឧទាហរណ៍ សហកម្មសិទ្ធិករ ខារី និង ម៉េងហុង រួមការខាតបង់ក្នុងចំណែកស្មើគ្នា ទោះបី ម៉េងហុង មានការដាក់ភាគទុនច្រើនជាង ខារី ពីរដងក៏ដោយ។ ប៉ុន្តែបើនៅក្នុងកិច្ចសន្យាបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិករទាំងពីរចែងថា គេយល់ព្រមបង់ខាតទៅតាមសមាមាត្រនៃភាគទុនរបស់គេ នោះគេមានករណីយកិច្ចបង់ខាតតែត្រឹមសមាមាត្រដែលបានកំណត់នោះ។ យោងតាមមាត្រា ២៤ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មចែងថា៖

- ការខាតបង់គឺស្មើគ្នា លើកលែងតែមានចែងផ្សេងក្នុងកិច្ចសន្យា។
- ប្រសិនបើកិច្ចសន្យាចែងអំពីផលប្រយោជន៍របស់សហកម្មសិទ្ធិករទូទៅ ដោយសំដៅចំពោះតែទ្រព្យសម្បត្តិ ប្រាក់ចំណេញ ឬការខាតបង់ ពេលនោះ សមាមាត្រដែលបានបង្កើតឡើងនៅក្នុងករណីនេះត្រូវបានសន្មតជាមុន ដើម្បីអនុវត្តទៅលើតែលើករណីទាំងបីនោះ។

នៅពេលដែលសហកម្មសិទ្ធិករបានចែងក្នុងកិច្ចសន្យាតែសមាមាត្រនៃភាគចំណេញ ប៉ុន្តែមិនបានចែងពីសមាមាត្រនៅក្នុងភាគផលប្រយោជន៍ក្នុងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនទេ ដូចនេះសមាមាត្រនៅក្នុងការរួមចំណែកក្នុងការត្រូវទទួលទាំងអស់គ្នា។ កថាខណ្ឌទី២ នៃមាត្រាខាងលើ សន្មតថាសមាមាត្រនៃប្រាក់ចំណេញនោះត្រូវអនុវត្តចំពោះការខាតបង់ផងដែរ។

ក្រមរដ្ឋប្បវេណី មាត្រា៧០៦ កថាខណ្ឌទី៣ បានចែងថា បើកិច្ចសន្យាកំណត់តែសមាមាត្រនៃការបែងចែកប្រាក់ចំណេញ ឬការរួមចំណែកក្នុងបង់ខាតប៉ុណ្ណោះ សមាមាត្រនេះត្រូវយកទៅអនុវត្តចំពោះសមាមាត្រនៃប្រាក់ចំណេញផងនិងការបង់ខាតផង។[57] ក្នុងករណីដែលមានសហកម្មសិទ្ធិករមួយ ឬ ច្រើនមិនបានរួមវិភាគទានទុកជាសាច់ប្រាក់ តែបានរួមចំណែកជាសេវាកម្ម។ បើតាមវិធានទូទៅ សហកម្មសិទ្ធិករទូទៅម្នាក់ៗត្រូវមានករណីយកិច្ចរួមចំណែកការខាតបង់។ ប៉ុន្តែ មានការវែកញែក វាអយុត្តិធម៌ចំពោះសហកម្មសិទ្ធិករដែលចូលរួមជាសេវាកម្ម ដែលខាតកម្លាំង សេវាកម្មរបស់ខ្លួនហើយ នៅតែត្រូវយកប្រាក់ផ្ទាល់ខ្លួនមកជួយរួមបង់ខាត

[57] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧,០៣០, ០៨ ធ្នូ ២០០៧, មាត្រា៧០៦, កថាខណ្ឌទី៣។

ទៀត។[58]

**ខ. ករណីយកិច្ចមិនប្រើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន**

សហកម្មសិទ្ធិករនោះត្រូវទទួលខុសត្រូវ សងក្រុមហ៊ុននូវប្រាក់ចំណេញដែលបានពីការលក់ដូរនោះ ដោយយោងទៅតាមមាត្រា ២៥ នៃច្បាប់ស្តីសហគ្រាសពាណិជ្ជកម្ម។ នៅមាត្រានេះផងដែរ កាតព្វកិច្ចត្រូវមាន សុទ្ធចិត្តតម្រូវឲ្យសហកម្មសិទ្ធិករម្នាក់ៗមិនត្រូវស្វែងរកអត្ថប្រយោជន៍ផ្ទាល់ខ្លួន ហើយធ្វើឲ្យខូចប្រយោជន៍របស់ ក្រុមហ៊ុនទេ។ សហកម្មសិទ្ធិករ មិនអាចលួចយកមូលនិធិរបស់ក្រុមហ៊ុនទៅប្រើដើម្បីកេងយកចំណេញផ្ទាល់ ខ្លួនបានទេ។ ប៉ុន្តែ ប្រសិនបើការយកប្រាក់ពីក្រុមហ៊ុនដោយមានការយល់ព្រមពីសហកម្មសិទ្ធិករដទៃទៀតទាំង អស់នោះ សហកម្មសិទ្ធិករមិនទទួលខុសត្រូវសងការប្រាក់នោះទៅក្រុមហ៊ុនវិញទេ។ មាត្រា ២៥ នៃច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្មក៏បានហាមប្រាមការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ដែលគ្មានការយល់ព្រមពី សហកម្មសិទ្ធិដទៃទៀតទាំងអស់ ដើម្បីកេងយកផលប្រយោជន៍ ឬចំណេញខ្លួនឯង។

**ច. ករណីយកិច្ចមិនប្រកួតប្រជែង**

ច្បាប់មិនហាមឃាត់សហកម្មសិទ្ធិករណាម្នាក់មិនឲ្យប្រកបអាជីវកម្មមួយផ្សេងពីអាជីវកម្មរបស់ក្រុម ហ៊ុនសហកម្មសិទ្ធិក្តី[59] ការធ្វើអាជីវកម្មនេះត្រូវប្រព្រឹត្តទៅដោយឈរលើគោលការណ៍ដែលមិនឆក់យកឱកាស អាជីវកម្មរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ។ ដើម្បីចៀសវាងបញ្ហាឆក់យកឱកាសអាជីវកម្មរបស់ក្រុមហ៊ុនសហ កម្មសិទ្ធិ នៅពេលចរចាបង្កើតក្រុមហ៊ុន សហកម្មសិទ្ធិករទាំងអស់ត្រូវប្រកាសពីអាជីវកម្មដែលខ្លួនមានស្រាប់ មុនពេលបង្កើតក្រុមហ៊ុន ដើម្បីឲ្យសហកម្មសិទ្ធិករដទៃទៀតដឹង និងធ្វើសេចក្តីសម្រេចថាពួកគេត្រូវអនុញ្ញាត សហកម្មសិទ្ធិករនោះបន្តអាជីវកម្មរបស់ខ្លួនដែលមានការប្រកួតប្រជែងនឹងអាជីវកម្មរបស់ក្រុមហ៊ុន ឬបដិសេធ មិនឲ្យសហកម្មសិទ្ធិករនោះចូលជាសមាជិកក្រុមហ៊ុន។

បើសហកម្មសិទ្ធិករទាំងអស់មិនមានអាជីវកម្មប្រកួតប្រជែងជាមួយអាជីវកម្មរបស់ក្រុមហ៊ុនទេ គេគួរ តែចែងខហាមឃាត់(ចែងក្នុងកិច្ចសន្យា ឬលក្ខន្តិកៈ) មិនឲ្យសហកម្មសិទ្ធិករណាមួយប្រកបអាជីវកម្មដោយ ឡែកដែលប្រកួតប្រជែងជាមួយក្រុមហ៊ុន។ នៅពេលដែលសហកម្មសិទ្ធិករមានសេរីភាពនឹងប្រកួតប្រជែង ជាមួយក្រុមហ៊ុនដែលត្រូវបានរំលាយ ព័ត៌មានសម្ងាត់របស់ក្រុមហ៊ុនត្រូវរក្សាទុករហូត លើកលែងតែមានការ ព្រមព្រៀងផ្សេង។[60]

---

[58] កុយនាម, *ច្បាប់ក្រុមហ៊ុន*, ការផ្សាយលើកទី១ (ឧត្តមការបោះពុម្ពពីលោកមេធាវី សួន វិសាល, ២០១៦), ទំព័រ១៣៨។

[59] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសរកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា២៥។

[60] កុយនាម, *ច្បាប់ក្រុមហ៊ុន*, ការផ្សាយលើកទី១ (ឧត្តមការបោះពុម្ពពីលោកមេធាវី សួន វិសាល, ២០១៦), ទំព័រ១៤២។

### ឆ. ករណីយកិច្ចសងការខូចខាតដល់ក្រុមហ៊ុន

មាត្រា ២៧ នៃច្បាប់ពាណិជ្ជកម្មចែងថា "សហកម្មសិទ្ធិករម្នាក់ៗត្រូវទទួលខុសត្រូវចំពោះក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនូវរាល់ការខូចខាតដែលបង្កឡើងដោយកំហុសឆ្គងរបស់សហកម្មសិទ្ធិករទូទៅនោះ"។ ករណីយកិច្ចត្រូវសងដល់ក្រុមហ៊ុនដែលបង្កដោយកំហុសរបស់សហកម្មសិទ្ធិករនេះក៏មានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី មាត្រា ៧០៣ ដែលតម្រូវឲ្យសហកម្មសិទ្ធិករមានករណីយកិច្ចប្រុងប្រយ័ត្ន។[61] ហើយមាត្រា ៦៤០ នៃក្រមដដែលតម្រូវថា ការមិនគោរពតាមករណីយកិច្ចប្រុងប្រយ័ត្ននេះជាហេតុឲ្យក្រុមហ៊ុនទាមទារសំណងខូចខាតដែលបង្កឡើងដោយការមិនគោរពករណីយកិច្ចនេះ។[62] ដូច្នេះ មាត្រា ២៧ បានន័យថា សហកម្មសិទ្ធិករមានករណីយកិច្ចប្រុងប្រយ័ត្ន នៅក្នុងការដឹកនាំឬចាត់ចែង អាជីវកម្មរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ។ សហកម្មសិទ្ធិករទូទៅត្រូវអនុវត្តកិច្ចការដោយមិនធ្វេសប្រហែស ឬដោយមានចេតនាបំផ្លាញ។

### ជ. ករណីយកិច្ចរបស់សហកម្មសិទ្ធិករទូទៅថ្មីចំពោះបំណុលរបស់ក្រុមហ៊ុន

បុគ្គលដែលចូលជាសមាជិកថ្មីនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលបានបង្កើតរួច ត្រូវទទួលខុសត្រូវចំពោះបំណុលដែលកើតមានឡើងនៅពេលដែលបុគ្គលនោះចូលជាសមាជិក។ ក៏ប៉ុន្តែ បំណុលដែលកើតឡើងមុនពេលបុគ្គលនោះចូលជាសមាជិកបំណុលនោះអាចសងដោយទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនតែប៉ុណ្ណោះ ហើយមិនត្រូវចេញសងដោយទ្រព្យសម្បត្តិផ្ទាល់ខ្លួនទេ លើកលែងតែមានការព្រមព្រៀងផ្សេងនៅក្នុងលិខិតជាលាយលក្ខណ៍អក្សរ។

សហកម្មសិទ្ធិករទូទៅជាម្ចាស់នៃក្រុមហ៊ុនផងនិងជាតំណាងរបស់ក្រុមហ៊ុនផង។ សម្រាប់ការរំលោភសេចក្តីទុកចិត្តគឺថា មនុស្សម្នាក់បានទទួលការកាន់កាប់ទ្រព្យសម្បត្តិអ្នកដទៃ ហើយយកទ្រព្យនោះទៅធ្វើជារបស់ខ្លួនឯង ឬប្រើទ្រព្យនោះខុសពីគោលដៅដែលម្ចាស់ទ្រព្យបានកំណត់។ នៅក្នុងករណីនេះ ទ្រព្យសម្បត្តិដែលប្រើប្រាស់នៅក្នុងក្រុមហ៊ុនជាទ្រព្យរបស់ក្រុមហ៊ុន ដែលមានភស្តុតាងនៃការផ្ទេរទ្រព្យសម្បត្តិរបស់សហកម្មសិទ្ធិករម្នាក់ៗទៅឲ្យក្រុមហ៊ុន។ ដូច្នេះ សហកម្មសិទ្ធិករណាដែលក្លែងបន្លំទ្រព្យសម្បត្តិទាំងនោះ ត្រូវទទួលខុសត្រូវពីបទរំលោភលើសេចក្តីទុកចិត្ត។ តែបើទ្រព្យសម្បត្តិដែលក្រុមហ៊ុនប្រើប្រាស់ ជាទ្រព្យសម្បត្តិដែលក្រុមហ៊ុនខ្ចីពីសហកម្មសិទ្ធិករទូទៅណាម្នាក់ ប្រសិនបើសហកម្មសិទ្ធិករនោះបានយកទ្រព្យសម្បត្តិនោះមិនទទួលខុសត្រូវទេ។[63]

---

[61] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧,០៣០, ០៨ ធ្នូ ២០០៧, មាត្រា៧០៣។

[62] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧,០៣០, ០៨ ធ្នូ ២០០៧, មាត្រា៦៤០។

[63] កុយនាម, *ច្បាប់ក្រុមហ៊ុន*, ការផ្សាយលើកទី១ (ឧត្តមការបោះពុម្ពពីលោកមេធាវី សួន វិសាល, ២០១៦), ទំព័រ១៤៥។

## ផ្នែកទី៣ សិទ្ធិ និងករណីយកិច្ចរបស់សហកម្មករមានកម្រិត

សិទ្ធិនិងកាតព្វកិច្ចនៃសមាជិកក្រុមហ៊ុននេះ វាក៏មានលក្ខណៈប្រដូចទៅនឹងសមាជិកនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅផងដែរ។ វាមានលក្ខណៈដូចតទៅះ

### ៣.១ សិទ្ធរបស់សហកម្មករមានកម្រិត

សហកម្មសិទ្ធិករមានកម្រិតត្រូវបានហាមឃាត់មិនឲ្យចូលរួមក្នុងការគ្រប់គ្រងអាជីវកម្មក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតឡើយ។ ក្នុងករណីដែលសហកម្មសិទ្ធិករទូទៅពុំអាចបំពេញការងារពាណិជ្ជកម្មទៅមុខបានដោយមូលហេតុណាមួយនោះ សហកម្មសិទ្ធិករមានកម្រិតអាចបំពេញកិច្ចការរដ្ឋបាលប្រចាំថ្ងៃជំនួសបានជាប្រយោជន៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតក្នុងការដំណើរការសកម្មភាពពាណិជ្ជកម្ម។ តែទោះបីជាយ៉ាងណាក៏ដោយពួកគេនៅតែទទួលបានសិទ្ធិមួយចំនួនក្នុងក្រុមហ៊ុននេះ ដូចជាការទទួលបានព័ត៌មានពិគ្រោះយោបល់ ទទួលបានប្រាក់ចំណេញ និងអាចផ្ទេរភាគហ៊ុនរបស់ខ្លួនទៅឲ្យអ្នកដទៃបាន។

#### ក. សិទ្ធិទទួលបានព័ត៌មាន និងពិគ្រោះយោបល់របស់សហកម្មសិទ្ធិករមានកម្រិត

សហកម្មសិទ្ធិករមានកម្រិតអាចទទួលព័ត៌មានពីសៀវភៅគណនី និងឯកសារក្រុមហ៊ុនពីការរីកចម្រើនក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបាន។[64] វាជាសិទ្ធិដែលសហកម្មសិទ្ធិករមានកម្រិតត្រូវតែទទួលបានព្រោះពួកគេក៏ជាសមាជិកម្នាក់នៅក្នុងក្រុមហ៊ុនដែរ ដូចនេះការទទួលបានព័ត៌មានទាក់ទងនឹងស្ថានការណ៍របស់ក្រុមហ៊ុនជារឿងមួយចាំបាច់សម្រាប់ពួកគេ។ តាមរយៈព័ត៌មានដែលទទួលបាន សហកម្មសិទ្ធិករមានកម្រិតអាចលើកជាគំណិត យោបល់ចំពោះប្រតិបត្តិការអាជីវកម្មក្រុមហ៊ុន ដាក់ជូនសហកម្មសិទ្ធិករទូទៅ និងអភិបាលដើម្បីធ្វើការពិគ្រោះក្នុងគោលដៅដើម្បីផលប្រយោជន៍ក្រុមហ៊ុន នៅក្នុងមហាសន្និបាតបាន។

#### ខ. សិទ្ធិទទួលបានប្រាក់ចំណេញ

សហកម្មសិទ្ធិករមានកម្រិតម្នាក់ៗមានសិទ្ធិទទួលបានចំណែកនៃប្រាក់ចំណេញរបស់ខ្លួន។ តែក្នុងករណីដែលការផ្តល់ជូនប្រាក់ចំណេញនោះធ្វើឲ្យមានឱនភាពនៃដើមទុនរបស់ក្រុមហ៊ុនសហកម្មសិទ្ធមានកម្រិត។ ក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មផងដែរ មានបានចែងបញ្ជាក់ថា សហកម្មសិទ្ធិករមានកម្រិតដែលទទួលបានប្រាក់នោះត្រូវបង្វិលចំនួនទឹកប្រាក់ចាំបាច់ណាមួយនៃប្រាក់ចំណេញនោះចូលទៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតវិញ ដើម្បីទប់ទល់ឱនភាពនៃភាគទុននោះ។ សហកម្មសិទ្ធិករមានកម្រិត មានសិទ្ធិទទួលបានប្រាក់ចំណេញដែលបានប្រតិបត្តិពាណិជ្ជកម្មរបស់ក្រុមហ៊ុនតាមសមាមាត្រភាគហ៊ុនដែលពួកគេបានចូលរួម ឬទទួលបានប្រាក់ចំណេញដោយមិនសមាមាត្របើមានកំណត់ដាក់លាក់ក្នុងកិច្ចសន្យា។ លើសពីនេះទៅទៀត

---

[64] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសរកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៧៩ , កថាខណ្ឌទី២។

ក្នុងករណីដែរសហកម្មសិទ្ធិករមានកម្រិតជានិយោជិកនោះ ខ្លួនអាចទទួលបានប្រាក់បៀវត្សពីក្រុមហ៊ុនសហកម្មសិទ្ធិបានតាមរយៈកិច្ចសន្យាការងារអាស្រ័យលើផលប្រយោជន៍របស់ក្រុមហ៊ុន និងភាពប៉ិនប្រសប់របស់សហកម្មសិទ្ធិករមានកម្រិតនោះ។[65]

**គ. សិទ្ធិការផ្ទេរប្រយោជន៍របស់សហកម្មសិទ្ធិករមានកម្រិត**

ក្នុងចំណុចនេះ គ្មានការរឹតត្បិតខ្លាំងចំពោះការផ្ទេរប្រយោជន៍របស់សហកម្មសិទ្ធិករមានកម្រិត ដូចសហកម្មសិទ្ធិករទូទៅទេ។ សហកម្មសិទ្ធិករមានកម្រិតមានសិទ្ធិពេញលេញដើម្បីធ្វើការផ្ទេរអត្ថប្រយោជន៍របស់ខ្លួនបាន នៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ដោយពុំចាំបាច់មានការយល់ព្រមជាឯកច្ឆន្ទពីសហកម្មសិទ្ធិករដទៃទៀតឡើយ ។រីឯក្នុងទំនាក់ទំនងជាមួយតតិយជនទោះបីជាខ្លួនបានផ្ទេរអត្ថប្រយោជន៍រួចហើយក៏ដោយ ក៏នៅតែជាប់កាតព្វកិច្ចដែលកើតមានឡើងនៅពេលខ្លួននៅជាសហកម្មសិទ្ធិករមានកម្រិត។[66]

**៣.២ ករណីយកិច្ចរបស់សហកម្មសិទ្ធិករមានកម្រិត**

ដោយសារសហកម្មសិទ្ធិករមានកម្រិតជាបុគ្គលមានលក្ខណៈជាអ្នកវិនិយោគទុនច្រើនជាងគេក្នុងចំណោមសហកម្មសិទ្ធិករនៃក្រុមហ៊ុន កាតព្វកិច្ចរបស់គាត់ក៏មិនមានច្រើនដូចសហកម្មសិទ្ធិករទូទៅដែរ។ កាតព្វកិច្ចសំខាន់របស់គាត់មានដូចជា ការបង់ភាគទុន និងការទទួលខុសត្រូវចំណោះបំណុល។

**ក. ករណីយកិច្ចបង់ភាគទុន**

ការបង់ភាគទុនទៅឲ្យក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត គឺជាកាតព្វកិច្ចមួយដែលសហកម្មសិទ្ធិករមានកម្រិតត្រូវតែបំពេញ។ សហកម្មសិទ្ធិករមានកម្រិតអាចទទួលបានសមាជិកភាពនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបានតាមរយៈការចូលរួមភាគហ៊ុន ដូច្នេះ ពួកគេត្រូវតែបង់ភាគហ៊ុនចូលទៅក្នុងមូលធនក្រុមហ៊ុនតាមចំណែកដែលខ្លួនបានសន្យានៅពេលបង្កើតកិច្ចសន្យាក្រុមហ៊ុន។ ការបង់ភាគទុនរបស់សហកម្មសិទ្ធិករមានកម្រិត អាចជាទឹកប្រាក់ ឬជាទ្រព្យសម្បត្តិតែប៉ុណ្ណោះ ហើយសហកម្មសិទ្ធិករមានកម្រិតអាចបន្ថែមភាគទុនបាននៅគ្រប់ពេលវេលា។[67]

**ខ. ករណីយកិច្ចទទួលខុសត្រូវចំពោះបំណុល**

សហកម្មសិទ្ធិករមានកម្រិតត្រូវទទួលខុសត្រូវត្រឹមតែចំនួនទឹកប្រាក់ ឬតម្លៃនៃទ្រព្យសម្បត្តិ ដែលខ្លួនបានព្រមព្រៀងដាក់ជាភាគទុនក្នុងក្រុមហ៊ុនប៉ុណ្ណោះ ហើយម្ចាស់បំណុលពុំមានសិទ្ធិរឹបអូសបេតិកភ័ណ្ឌផ្ទាល់

[65] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសរកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា ៧១-៧២។
[66] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសរកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៧៨។
[67] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសរកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៧០។

ខ្លួនរបស់សហកម្មសិទ្ធិករមានកម្រិតបានឡើយ។[68] នេះជាលក្ខណៈពិសេស មួយដែលពួកគេទទួលបាន។ តែទោះជាយ៉ាងនេះ ពួកគេត្រូវទទួលខុសត្រូវដោយផ្ទាល់រាល់កាតព្វកិច្ចដែលបានធ្វើឡើងដោយការចរចាកិច្ចការពាណិជ្ជកម្មក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ដោយគ្មានការអនុញ្ញាតឲ្យធ្វើជាភ្នាក់ងារក្រុមហ៊ុន ឬមិនអនុញ្ញាតឲ្យប្រើឈ្មោះរបស់ខ្លួនក្នុងសកម្មភាពពាណិជ្ជកម្មណាមួយរបស់ក្រុមហ៊ុន។ វាអាចជាការទទួលខុសត្រូវដោយគ្មានកម្រិត ឬលើសពីកម្រិតដែលមាននៅក្នុងភាគហ៊ុនក្រុមហ៊ុន។ ក្រៅពីនេះ សហកម្មសិទ្ធិករមានកម្រិតដែលមានឈ្មោះក្នុងនាមករណ៍ក្រុមហ៊ុនសហកម្មសិទ្ធិត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិ ដូចជាសហកម្មសិទ្ធិការទូទៅដែរ លើកលែងតែស្ថានភាពរបស់សហកម្មសិទ្ធិករមានកម្រិតនោះត្រូវបានកំណត់ច្បាស់លាស់។[69]

[68] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសររកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៨២។

[69] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសររកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៧៣។

# ជំពូកទី៣៖ ការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិ

ការរំលាយក្រុមហ៊ុន គឺជាការបញ្ចប់ជីវិតក្រុមហ៊ុន។ ក្រុមហ៊ុនត្រូវបានរំលាយទៅតាមប្រភេទនៃក្រុមហ៊ុននីមួយៗ សម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវរំលាយដោយឆន្ទៈនៃសហកម្មសិទ្ធិករ, ការផ្លាស់ប្តូរសមាសភាពក្រុមហ៊ុន, ភាពក្ស័យធននៃសហកម្មសិទ្ធិករណាមួយ និងសាលក្រមតុលាការបង្គាប់ឲ្យរំលាយ។ ការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនអាចប៉ះពាល់សិទ្ធិតតិយជនដែលធ្វើពាណិជ្ជកម្មជាមួយដោយស្មោះត្រង់ និងមិនអាចប៉ះពាល់ទៅនឹងបុគ្គលណាមួយ ដែលបានចុះកិច្ចសន្យាជាមួយសហកម្មសិទ្ធិករទូទៅ ឬមិនអាចប៉ះពាល់ទៅនឹងភ្នាក់ងារណាម្នាក់ដែលធ្វើកិច្ចការក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះឡើយ។[70]

## ផ្នែកទី១ មូលហេតុនៃការរំលាយក្រុមហ៊ុន

ចំពោះមូលហេតុដែលមានចែងក្នុងកិច្ចសន្យា និងដោយតុលាការស្របទៅតាមមូលហេតុច្បាប់។ សិទ្ធិរបស់សហកម្មសិទ្ធិករទូទៅដែលធ្វើសកម្មភាពក្នុងនាមក្រុមហ៊ុនត្រូវចប់នៅពេលដែលក្រុមហ៊ុននោះត្រូវបានរំលាយ លើកលែងតែចំពោះសកម្មភាពទាំងឡាយណាដែលជាផលវិបាកដ៏ចាំបាច់នៃពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន និងធ្វើពុំទាន់ចប់សព្វគ្រប់។ តែរាល់កិច្ចការដែលបានធ្វើជាប្រក្រតីក្នុងក្រុមហ៊ុនដោយសហកម្មសិទ្ធិករទូទៅដែលមិនបានដឹងអំពីការរំលាយក្រុមហ៊ុននោះ ហើយនៅតែធ្វើសកម្មភាពដោយស្មោះត្រង់សហកម្មសិទ្ធិករនោះត្រូវជាប់កាតព្វកិច្ចជាមួយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងសហកម្មសិទ្ធិករទូទៅដទៃទៀត ដូចដែលក្រុមហ៊ុននោះនៅជាធរមាននៅឡើយ។[71] ការរំលាយក្រុមហ៊ុនមានមូលហេតុដូចតទៅ៖

### ១.១ ការរំលាយដោយពេញច្បាប់

មានករណីខ្លះនាំឲ្យក្រុមហ៊ុនត្រូវរំលាយដោយស្វ័យប្រវត្តិ ប្រសិនកិច្ចសន្យាក្រុមហ៊ុនមិនបានចែងការពារបម្រុងទុកទៅលើករណីទាំងនោះទេ ។[72] ដោយករណីទាំងនោះមានដូចជា៖

- ផលប្រយោជន៍របស់សហកម្មសិទ្ធិករម្នាក់ត្រូវបានផ្ទេរ៖ សហកម្មសិទ្ធិករម្នាក់ចង់ដកខ្លួនពីក្រុមហ៊ុនដោយផ្ទេរផលប្រយោជន៍របស់ខ្លួនទៅឲ្យសហកម្មសិទ្ធិករគ្នាឯង ឬទៅឲ្យតតិយជន។ ការនេះកើតឡើងតាមរយៈការលក់ផលប្រយោជន៍របស់ខ្លួនទៅឲ្យសហកម្មសិទ្ធិករដែលនៅបន្តទៅឲ្យតតិយជន ឬធ្វើប្រទានកម្មផលប្រយោជន៍របស់ខ្លួនទៅឲ្យសាច់ញាតិរបស់ខ្លួនជាដើម។

[70] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសរកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៥៧។
[71] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសរកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៥៦។
[72] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសរកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៤៨-៤៩។

- មរណភាពនៃសហកម្មសិទ្ធិករណាម្នាក់៖ មរណភាពនៃសហកម្មសិទ្ធិករមិននាំឲ្យមានការបញ្ចប់នៃក្រុមហ៊ុននោះទេ លើកលែងតែកិច្ចសន្យាបង្កើតក្រុមហ៊ុនចែងផ្សេងពីមរណភាពនៃសហកម្មសិទ្ធិករណាម្នាក់ ដែលនាំឲ្យក្រុមហ៊ុនសហកម្មសិទ្ធិទូទៅរំលាយ ។
- សហកម្មសិទ្ធិករណាម្នាក់ត្រូវបានដាក់ឲ្យស្ថិតនៅក្នុងសភាពក្ស័យធន៖ សហកម្មសិទ្ធិករក្ស័យធនគឺជាសហកម្មសិទ្ធិករដែលគ្មានលទ្ធភាពសងបំណុលផ្ទាល់ខ្លួនដល់ ម្ចាស់បំណុលរបស់ខ្លួន។
- ការដកខ្លួននៃសហកម្មសិទ្ធិករណាម្នាក់៖ ការដកខ្លួននៃសហកម្មសិទ្ធិករជាបញ្ហាមួយទៀតដែលកិច្ចសន្យាក្រុមហ៊ុនត្រូវព្រាងទុកជាមុន។ សហកម្មសិទ្ធិករម្នាក់អាចដកខ្លួនពីក្រុមហ៊ុនដោយសារមូលហេតុណាមួយដូចជា៖ សុខភាព, ចង់ផ្លាស់ប្តូរកិច្ចការ, ធុញទ្រាន់នឹងសហកម្មសិទ្ធិករគ្នាឯង, មើលមិនឃើញអនាគតនៃអាជីវកម្ម។
- ការបណ្តេញចេញនូវសហកម្មសិទ្ធិករណាម្នាក់៖ សហកម្មសិទ្ធិករទូទៅ ដែលមានសម្លេងភាគច្រើនដោយធៀប អាចបណ្តេញសហកម្មសិទ្ធិករណាម្នាក់ដែលមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ឬធ្វើឲ្យរាំងស្ទះដល់ដំណើរការរបស់ក្រុមហ៊ុន។

### ១.២ ការរំលាយដោយអំណាចកិច្ចសន្យា

ការរំលាយអំណាចកិច្ចសន្យានេះ ជាព្រឹត្តិការណ៍ដែលអាចកំណត់នៅក្នុងកិច្ចសន្យាបង្កើតក្រុមហ៊ុនដើម្បីជាឆ្នួនធ្វើឲ្យរំលាយក្រុមហ៊ុនបាន។ ដោយព្រឹត្តការណ៍នោះមានដូចខាងក្រោម៖

- ការបញ្ចប់កិច្ចការនៃអាជីវកម្មស្របតាមគោលបំណងនៃកិច្ចសន្យាបង្កើតក្រុមហ៊ុន ដោយមានការលើកលែងតែសហកម្មសិទ្ធិករព្រមព្រៀងគ្នាជាឯកច្ឆន្ទដើម្បីបន្ត។
- អលទ្ធភាពក្នុងការបំពេញកិច្ចការអាជីវកម្មរបស់ក្រុមហ៊ុន៖ សហកម្មសិទ្ធិករដែលអស់សមត្ថភាពក្នុងការបន្តក្រុមហ៊ុន ឬក៏ការអស់នូវប្រាក់ ឬលែងមានសហកម្មសិទ្ធិករផ្សេងទៀតចូលរួម។
- សហកម្មសិទ្ធិករព្រមព្រៀងគ្នាជាឯកច្ឆន្ទដើម្បីបញ្ចប់ក្រុមហ៊ុន[73]៖ សហកម្មសិទ្ធិករមានការព្រមព្រៀងគ្នា ឬមានឆន្ទៈដូចគ្នាក្នុងការបញ្ចប់ក្រុមហ៊ុន។

[73] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ព្រះរាជក្រមលេខ នស/រកម/០១២២/០០៣, ៦ មករា ២០២២,មាត្រា៥៣។

## ១.៣ ការរំលាយដោយអំណាចតុលាការ

ក្នុងចំណុចនេះ គេអាចធ្វើការស្វែងរកតុលាការឲ្យធ្វើអន្តរាគមន៍ ដើម្បីរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ដោយសារមូលហេតុដូចខាងក្រោមនេះ៖

- សេចក្តីសម្រេចរបស់តុលាការឲ្យរំលាយក្រុមហ៊ុនដោយសារមូលហេតុផ្លូវច្បាប់។
- សាលក្រមតុលាការបង្គាប់ឲ្យសហកម្មសិទ្ធិករណាម្នាក់ដកខ្លួន ឬបញ្ជាឲ្យរឹបអូសផលប្រយោជន៍របស់សហកម្មសិទ្ធិករណាម្នាក់នៅក្នុងក្រុមហ៊ុន ដូចជាដើម្បីយកទៅសងបំណុលដោយឡែករបស់សហកម្មសិទ្ធិករ។[74]

សម្រាប់សេចក្តីសម្រេចរបស់តុលាកាផងដែរ ដោយមានការផ្អែកលើមូលដ្ឋាននានាដូចជា៖

- សហកម្មសិទ្ធិករណាមួយមានវិបត្តិសតិ សហកម្មសិទ្ធិករបានក្លាយជាជនវិប្លាស្មារតីដែលមិនមានសមត្ថភាពចុះកិច្ចសន្យានានា។
- សហកម្មសិទ្ធិករប្រព្រឹត្តអំពើទុច្ចរិត ដែលមានការប៉ះពាល់ដល់ក្រុមហ៊ុន ដូចជា បន្លំមូលនិធិ។
- សហកម្មសិទ្ធិករប្រព្រឹត្តផ្ទុយនឹងកិច្ចព្រមព្រៀង ដែលសហកម្មសិទ្ធិករបានល្មើសនឹងកិច្ចសន្យាដែលបានចែង។

រីឯក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតវិញ សហកម្មសិទ្ធិករទូទៅទាំងឡាយក៏អាចធ្វើការព្រមព្រៀងគ្នាដើម្បីរំលាយក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតបានមុនការមកដល់នៃថេរវេលាក្រុមហ៊ុន ដោយសេចក្តីសម្រេចរបស់សមាជិកស្តែងឡើងនូវឆន្ទៈជាឯកច្ឆ័ន ធ្វើការរំលាយក្រុមហ៊ុនចោលដែលបណ្តាលមកពីបាត់បង់គោលការណ៍ស្មើដៃស្មើជើងគ្នា ឬការបាក់បែកសាមគ្គីគ្នា ឬការរលត់នៃកម្មវត្ថុអាជីវកម្មដែលជាកំហុសធ្ងន់ធ្ងរធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ បរិស្ថាន ប្រពៃណីជាដើម។

ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតក៏ត្រូវបានរំលាយផងដែរ ដោយតាមមូលហេតុដូចជា៖

- ការផ្លាស់ប្តូរទំរង់ក្រុមហ៊ុន ឬអវត្តមានសមាជិកថ្មីជាសហកម្មសិទ្ធិករទូទៅ។ ក្នុងករណីនេះ ប្រសិនបើសហកម្មសិទ្ធិករទូទៅទាំងឡាយមិនត្រូវបានជំនួសក្នុងរយៈពេល ១២០ថ្ងៃទេ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតនោះនឹងត្រូវរំលាយ។
- ការបដិសេធនៃកិច្ចសន្យាក្រុមហ៊ុន ដោយមានវិការៈនៃកិច្ចសន្យាបង្កើតក្រុមហ៊ុន។
- ការហាមឃាត់ដល់ការធ្វើអាជីវកម្ម ឬអសមត្ថភាពត្រូវបានទទួលរងទៅលើសហកម្មសិទ្ធិករទូទៅណាម្នាក់។

[74] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសរកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៤៨។

- ការរំលាយដោយសេចក្ដីសម្រេចរបស់តុលាការ ក្នុងករណីបំពានទៅលើកម្មវត្ថុអាជីវកម្ម ដោយប្រព្រឹត្តនូវបទល្មើសផ្សេងៗ ឬបាត់បង់ផលប្រយោជន៍ដែលនាំឲ្យមានបណ្ដឹងពីក្រុមហ៊ុន សមាជិកហ៊ុន និងព្រះរាជអាជ្ញា។
- ការជម្រះបញ្ជីតាមផ្លូវតុលាការ ដោយក្ស័យធន ប្ដឹងសុំជម្រះបញ្ជីទ្រព្យសម្បត្តិក្រុមហ៊ុន។

### **១.៤ ការផ្លាស់ប្ដូរដោយការបាត់បង់សហកម្មសិទ្ធិករ**

ការផ្លាស់ប្ដូរសមាសភាពក្រុមហ៊ុនកើតឡើងនៅពេលដែលសហកម្មសិទ្ធិករម្នាក់លាលែងពីក្រុមហ៊ុន ឬបាត់បង់ជីវិត ឬនៅពេលដែលមានបុគ្គលណាម្នាក់ចូលមកជាសហកម្មសិទ្ធិករថ្មី។ មានពីរករណីដែលនៅក្នុងការផ្លាស់ប្ដូរដូចជា៖

#### **ក. ករណីនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនចុះបញ្ជីជានីតិបុគ្គល**

យោងតាមមាត្រា ៤៩ នៃច្បាប់សហគ្រាសពាណិជ្ជកម្មចែងថា៖ បុគ្គលណាមួយអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅ បង្កឲ្យមានការរំលាយជាស្វ័យប្រវត្តិនូវក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ លើកលែងតែកិច្ចសន្យាចែងផ្សេងពីនេះ។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលមិនចុះបញ្ជីជានីតិបុគ្គល កាលណាសហកម្មសិទ្ធិករម្នាក់លាលែង ឬបាត់បង់ជីវិត  ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅក៏ត្រូវបានចប់ដែរ ព្រោះទំនាក់ទំនងកិច្ចសន្យានៃការបង្កើតក្រុមហ៊ុនត្រូវបញ្ចប់ដោយសារភាគីណាមួយនៃកិច្ចសន្យាលែងជាភាគីនៃកិច្ចសន្យានោះ។ ប្រសិនបើបន្តអាជីវកម្មរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ នោះនៅក្នុងទម្រង់នៃកិច្ចសន្យាថ្មីរវាងសហកម្មសិទ្ធិករដែលនៅសល់ដើម្បីបន្តអាជីវកម្មដដែល តែសហកម្មសិទ្ធិករទូទៅមិនចាំបាច់រើរុះកិច្ចសន្យាក៏បាន បើពួកគេបានចែងនៅក្នុងកិច្ចសន្យាដើម្បីបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ថាគេនឹងនៅបន្តក្រុមហ៊ុនតទៅទៀត ក្នុងករណីដែលមានសហកម្មសិទ្ធិករណាម្នាក់លាលែង ឬស្លាប់ ដោយគ្រាន់តែចែងពីនីតិវិធីនៃការផ្ទេរផលប្រយោជន៍របស់សហកម្មសិទ្ធិករដែលលាលែង ឬស្លាប់។ ម្យ៉ាងទៀតបុគ្គលដែលអស់សិទ្ធិជាសហកម្មសិទ្ធិករទូទៅមានជាអាទិ៍ សហកម្មសិទ្ធិករដែលដកខ្លួនពីក្រុមហ៊ុន, សហកម្មសិទ្ធិករដែលទទួលមរណភាព សហកម្មសិទ្ធិករដែលត្រូវបានបណ្ដេញចេញពីក្រុមហ៊ុន ។[75]

#### **ខ. ករណីនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដែលចុះបញ្ជីជានីតិបុគ្គល**

ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្មបានចែងជាទូទៅ ការផ្លាស់ប្ដូរសមាសភាពក្រុមហ៊ុនសហកម្មសិទ្ធិនាំឲ្យក្រុមហ៊ុនរំលាយដោយស្វ័យប្រវត្តិ ដោយគ្មានការបែងចែករវាងប្រភេទនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅចុះបញ្ជី និងមិនចុះបញ្ជី។ តាមច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម និរន្តរភាពនៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិន

---

[75] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសរកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៤៨។

អាស្រ័យលើឋានៈគតិយុត្ត (ជានីតិបុគ្គល)នៃក្រុមហ៊ុនទេ។ មាត្រា ១២ នៃច្បាប់ដដែលចែងថា ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមាននីតិបុគ្គលិកដាច់ដោយឡែកពីសហកម្មសិទ្ធិករម្នាក់ៗ មានន័យថា ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅបន្តជីវិតរបស់ខ្លួនបន្ទាប់ពីមានការផ្លាស់ប្តូរសមាសភាពក្រុមហ៊ុន លុះត្រាតែកិច្ចសន្យាបង្កើតក្រុមហ៊ុនបានចែងថា ក្រុមហ៊ុននៅបន្តបុគ្គលភាពរបស់ខ្លួនទោះបីមានការផ្លាស់ប្តូរសមាសភាពក៏ដោយ។[76]

## ផ្នែកទី២ នីតិវិធីនៃការរំលាយក្រុមហ៊ុន

ជំហានដំបូងនៃការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិ គឺសហកម្មសិទ្ធិករត្រូវធ្វើសេចក្តីសម្រេចពីការរំលាយក្រុមហ៊ុន ដោយកំណត់ថ្ងៃចូលជាធរមាននៃការរំលាយក្រុមហ៊ុន។ ហើយនីតិវិធីនៃការរំលាយនេះផងដែរមានដូចតទៅ៖

### ២.១ កិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុន

ដើម្បីចៀសវាងឲ្យមានការជម្លោះក្នុងដំណើរការរំលាយក្រុមហ៊ុន សហកម្មសិទ្ធិករគួរធ្វើកិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុន។ កិច្ចព្រមព្រៀងនេះអាចចែងដូចជា៖

- ចេតនារំលាយក្រុមហ៊ុន
- កាលបរិច្ឆេទនៃការរំលាយជាធរមាន
- ការជូនដំណឹងពីការរំលាយក្រុមហ៊ុន
- ការតែងតាំងអ្នកជម្រះបញ្ជី និង ការសងទូទាត់សេវាជម្រះបញ្ជី
- អំណាចនៃអ្នកជម្រះបញ្ជី
- ករណីយកិច្ចនៃអ្នកជម្រះបញ្ជី
- ករណីយកិច្ចរបស់សហកម្មសិទ្ធិករម្នាក់ៗនៅក្នុងដំណើរការជម្រះបញ្ជី
- ការបែងចែកផលប្រយោជន៍របស់សហកម្មសិទ្ធិករ
- នីតិវិធីនៃការជម្រះបញ្ជី
- ខស្តីពីការដោះស្រាយជម្លោះ

### ២.២ ការជូនដំណឹងពីការរំលាយក្រុមហ៊ុន

ដោយយោងតាមមាត្រា ៥៩ ចែងថា៖ សហកម្មសិទ្ធិករទូទៅត្រូវធ្វើលិខិតជូនដំណឹងទៅមន្ត្រីចុះបញ្ជីអំពីការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅតាមទម្រង់បែបបទដែលបានកំណត់ និងត្រូវធ្វើការតែងតាំងអ្នក

[76] កុយនាម, *ច្បាប់ក្រុមហ៊ុន*, ការផ្សាយលើកទី១ (ឧត្តមការបោះពុម្ពពីលោកមេធាវី សួន វិសាល, ២០១៦), ទំព័រ១៦៨-១៦៩។

ជម្រះបញ្ជីផងដែរ។ សហកម្មសិទ្ធិករទូទៅត្រូវធ្វើការចុះផ្សាយជាបន្ទាន់អំពីការរំលាយក្រុមហ៊ុនក្នុងរយៈពេល ៤ (បួន) សប្តាហ៍បន្តបន្ទាប់នៅក្នុងទំព័រសារព័ត៌មានជាភាសាខ្មែរនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលបោះពុម្ព ឬផ្សព្វផ្សាយនៅនឹងកន្លែងដែលក្រុមហ៊ុននោះមានការិយាល័យរបស់ខ្លួននៅទីនោះ ឬនៅក្នុងការផ្សព្វផ្សាយផ្សេងទៀតដូចមានចែងនៅក្នុងបទបញ្ជារបស់ក្រសួងពាណិជ្ជកម្ម។ លិខិតជូនដំណឹងដែលបានចុះផ្សាយនៅក្នុងទំព័រសារព័ត៌មាន ត្រូវមានចែងក្នុងបទបញ្ជារបស់ក្រសួងពាណិជ្ជកម្ម។[77] តាមមាត្រានេះបានបង្ហាញថា សហកម្មសិទ្ធិករណាមួយត្រូវចាត់ការធ្វើសេចក្តីជូនដំណឹងអំពីការរំលាយដល់មន្ត្រីចុះបញ្ជី និងសាធារណជនពីការរំលាយ។ ការជូនដំណឹងនេះមានផលប្រយោជន៍ការពារការទាមទារពីតតិយជនដែលធ្វើពាណិជ្ជកិច្ចជាមួយក្រុមហ៊ុន ឬសហកម្មសិទ្ធិករណាម្នាក់ក្រោយពីក្រុមហ៊ុនត្រូវបញ្ចប់ប្រតិបត្តិការរបស់ខ្លួនហើយ។

ទោះការជូនដំណឹងដែលធ្វើតាមទម្រង់ខាងលើជាការគ្រប់គ្រាន់តាមផ្លូវច្បាប់ ដើម្បីតតាំងនឹងការទាមទាររបស់តតិយជនក្តី សហកម្មសិទ្ធិករគួរតែធ្វើលិខិតជូនដំណឹងមួយទៀតដល់តតិយជនដែលធ្លាប់ធ្វើពាណិជ្ជកិច្ចជាមួយខ្លួន ដើម្បីឲ្យពួកគេបានដឹងពីការរំលាយក្រុមហ៊ុន និងបញ្ឈប់ការធ្វើពាណិជ្ជកិច្ចក្រោយថ្ងៃរំលាយក្រុមហ៊ុន។[78] ចំពោះនីតិវិធីនៃការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតវិញ គឺវាមានការប្រដូចគ្នាទៅនឹងក្រុមហ៊ុនសហកម្មសិទ្ធិទូទៅផងដែល។

### ២.៣ ការជម្រះបញ្ជី

ការជម្រះបញ្ជី ជាដំណើរការចាត់ចែងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ដើម្បីយកទៅសងបំណុលរបស់ក្រុមហ៊ុន ហើយយកផលលក់ដែលនៅសល់ពីការសងបំណុលទៅបែងចែកឲ្យសហកម្មសិទ្ធិករម្នាក់ៗ ទៅតាមសមាមាត្រនៃចំណែកផលប្រយោជន៍របស់គេ ឬតាមរូបមន្តនៃការបែងចែកណាមួយដែលមានចែងនៅក្នុងកិច្ចសន្យាបង្កើតក្រុមហ៊ុន ហើយក្រោយពីនោះ ក្រុមហ៊ុនត្រូវបានរំលាយជាស្ថាពរ។ អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវសៀវភៅបញ្ជី និងកំណត់ហេតុផ្សេងៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ រហូតដល់រយៈពេល ៥(ប្រាំ)ឆ្នាំ ចាប់ពីពេលដែលបានជម្រះបញ្ជីរួច។ អ្នកជម្រះបញ្ជីត្រូវរក្សាទុកនូវបញ្ជីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងកំណត់ហេតុផ្សេងៗសម្រាប់រយៈពេលច្រើនជាងនេះ ប្រសិនបើឯកសារទាំងនេះ តម្រូវឱ្យទុកជាភស្តុតាង។[79] ការជម្រះបញ្ជីរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅត្រូវបញ្ចប់ដោយធ្វើការតម្កល់ទុកនូវសេចក្តីជូនដំណឹងអំពីការបិទ

---

[77] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ព្រះរាជក្រមលេខ នស/រកម/០១២២/០០៣, ៦ មករា ២០២២, មាត្រា ៥៩។

[78] កុយនាម, *ច្បាប់ក្រុមហ៊ុន*, ការផ្សាយលើកទី១ (ឧត្ដម្ភការបោះពុម្ពពីលោកមេធាវី សួន វិសាល, ២០១៦), ទំព័រ១៨៧។

[79] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម, នស/រកម/០១២២/០០២, ២៩ មករា ២០២២,មាត្រា៦២ ថ្មី។

បញ្ជីនោះនៅក្រសួងពាណិជ្ជកម្មតាមបែបបទដែលបានកំណត់ទុក។ ការតម្កល់ទុកឯកសារនេះគឺជាការលុបចោលនូវនីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ ។

សហកម្មសិទ្ធិករត្រូវតែងតាំងអ្នកជម្រះបញ្ជីម្នាក់ឲ្យបំពេញកិច្ចការជម្រះបញ្ជី។ សហកម្មសិទ្ធិករទូទៅអាចតែងតាំងសហកម្មសិទ្ធិករណាម្នាក់ជាអ្នកជម្រះបញ្ជីក៏បាន ឬតែងតាំងអ្នកក្រៅក៏បាន។ អ្នកជម្រះបញ្ជីនោះមានសិទ្ធិនិងអំណាចដូចខាងក្រោម៖

- ទាមទារយកឯកសារនានាដែលជួយដល់ការជម្រះបញ្ជី (ដូចជាកិច្ចសន្យាបង្កើតក្រុមហ៊ុន, បញ្ជីគណនេយ្យ, បញ្ជីទ្រព្យសម្បត្តិក្រុមហ៊ុន, កិច្ចសន្យានានាដែលក្រុមហ៊ុនបានធ្វើជាមួយតតិយជន, កិច្ចសន្យាការងារ។ល។)
- កាន់កាប់, ប្រើប្រាស់, និងចាត់ចែងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន
- យកទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនទៅលក់ និងសងម្ចាស់បំណុលរបស់ក្រុមហ៊ុនទៅតាមលំដាប់សិទ្ធិបុរិមានៃបំណុល, បង់ពន្ធដែលក្រុមហ៊ុននៅជំពាក់រដ្ឋ , បង់ការចំណាយផ្សេងៗទាក់ទងនឹងការជម្រះបញ្ជី
- បង្វិលទ្រព្យសម្បត្តិរបស់តតិយជនដែលក្រុមហ៊ុនយកមកប្រើ
- យកទ្រព្យដែលនៅសល់ទៅបែងចែកឲ្យសហកម្មសិទ្ធិករតាមសមាមាត្រនៃចំណែកផលប្រយោជន៍របស់គេក្នុងករណីដែលកិច្ចសន្យាបានចែងពីសមាមាត្រនោះ ឬបែងចែកស្មើគ្នា ប្រសិនបើកិច្ចសន្យាមិនបានចែងបញ្ជាក់ពីសមាមាត្រនៃចំណែកផលប្រយោជន៍នោះ
- បើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនមិនមានគ្រប់គ្រាន់ដើម្បីជម្រះបំណុលបានទេ អ្នកជម្រះបញ្ជីត្រូវតម្រូវឲ្យសហកម្មសិទ្ធិករម្នាក់ៗយកទ្រព្យសម្បត្តិផ្ទាល់ខ្លួនមកបន្ថែម ដើម្បីជម្រះបំណុលតទៅទៀត។

សម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតវិញ នៅពេលក្រុមហ៊ុនត្រូវបានរំលាយហើយមានការជម្រះបញ្ជីដូចតទៅ៖

- ម្ចាស់បំណុលត្រូវទទួលការសងបំណុលមុនគេ។ ម្ចាស់បំណុលនេះរួមទាំងសហកម្មសិទ្ធិករដែលបានឲ្យកម្ចីដល់ក្រុមហ៊ុន។ ពន្ធដែលមិនទាន់បង់ឲ្យរដ្ឋ ក៏ត្រូវបានចាត់ទុកជាបំណុលមួយដែរ។
- ទូទាត់ប្រាក់ចំណេញដែលមិនទាន់បានចែកទៅឲ្យសហកម្មសិទ្ធិករ ចែកជូនទៅឲ្យសហម្មសិទ្ធិករវិញ
- សងដើមទុនដែលសហកម្មសិទ្ធិករបានបង់ចូលក្រុមហ៊ុនត្រឡប់ទៅឲ្យសហកម្មសិទ្ធិករម្នាក់ៗ
- ចែកផលប្រយោជន៍ទៅឲ្យសហកម្មសិទ្ធិករម្នាក់ៗទៅតាមសមាមាត្រនៃផលចំណែករបស់គេ។

### ២.៤ ការទូទាត់នៃការជម្រះបញ្ជី

ការទូទាត់នៅក្នុងការជំរះបញ្ជីត្រូវធ្វើតាមលំដាប់ដូចខាងក្រោមនេះ៖

- អ្នកជម្រះបញ្ជីត្រូវយកទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនសហកម្មសិទ្ធិទៅសងទូទាត់ឲ្យបុគ្គលិករបស់ក្រុមហ៊ុន ថ្លៃសេវា និងការចំណាយក្នុងការជម្រះបញ្ជី
- អ្នកជម្រះបញ្ជីត្រូវយកទ្រព្យរបស់ក្រុមហ៊ុនទៅទូទាត់ពន្ធដារ
- អ្នកជម្រះបញ្ជីត្រូវយកទ្រព្យរបស់ក្រុមហ៊ុនទៅសងម្ចាស់បំណុល ទៅតាមសិទ្ធិបុរិមារបស់គេ។ ម្ចាស់បំណុលដែលបានធ្វើសុក្រឹតកម្មលើសិទ្ធិប្រាតិភោគ គឺជាម្ចាស់បំណុលដែលមានសិទ្ធិបុរិមាខ្ពស់ជាងគេ[80]
- បើទ្រព្យទាំងអស់របស់ក្រុមហ៊ុនមិនអាចយកទៅទូទាត់បំណុលបានទេ អ្នកជម្រះបញ្ជីត្រូវបង្គាប់ឲ្យសហកម្មសិទ្ធិករនីមួយៗដាក់ទ្រព្យផ្ទាល់ខ្លួនបន្ថែមតាមសមាមាត្រនៃការចំណេញ ឬខាតរបស់ខ្លួន។ បើសហកម្មសិទ្ធិករណាមួយក្នុងបណ្តាសហកម្មសិទ្ធិករទាំងអស់គ្មានទ្រព្យសម្បត្តិផ្ទាល់ខ្លួនសងទេ អ្នកជម្រះបញ្ជីត្រូវបង្គាប់ឲ្យសហកម្មសិទ្ធិករដទៃទៀតដែលមានទ្រព្យផ្ទាល់ខ្លួនសងម្ចាស់បំណុលបន្ថែម។
- បើទ្រព្យក្រុមហ៊ុនត្រូវបានយកទៅទូទាត់បំណុលរួចហើយនៅសល់ អ្នកជ្រះបញ្ជីត្រូវយកទ្រព្យដែលនៅសល់នោះចែកទៅតាមសមាមាត្រនៃផលប្រយោជន៍របស់សហកម្មសិទ្ធិករម្នាក់ៗនៅក្នុងក្រុមហ៊ុន
- ចុងបញ្ចប់ អ្នកជម្រះបញ្ជីត្រូវតម្កល់ទុករបាយការណ៍នៃការបិទការជម្រះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម
- ក្រុមហ៊ុនសហកម្មសិទ្ធិត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម។

## ផ្នែកទី៣ អានុភាពនៃការរំលាយក្រុមហ៊ុន

ទោះបីជានៅក្នុងហេតុណាមួយក៏ដោយ ការរំលាយក្រុមហ៊ុនបណ្តាលឱ្យមានការជម្រះបញ្ជីភ្លាមៗរវាងភាគីទាំងអស់និងចំពោះតតិយជន ក្រោយពីមានការប្រកាសជាសាធារណៈ។ នៅពេលដែលក្រុមហ៊ុនត្រូវបានប្រកាសថាត្រូវបានរំលាយ សហកម្មសិទ្ធិករទាំងអស់ត្រូវបញ្ឈប់សកម្មភាពអាជីវកម្មក្នុងនាមក្រុមហ៊ុនជាមួយតតិយជន បើពុំនោះទេ សហកម្មសិទ្ធិករត្រូវទទួលខុសត្រូវផ្ទាល់ខ្លួន។

### ៣.១. អានុភាពចំពោះសហកម្មសិទ្ធិករ

ក្រុមហ៊ុនសហកម្មសិទ្ធិដែលជានីតិបុគ្គលបន្តបុគ្គលភាពរបស់ខ្លួនរហូតដល់ការជម្រះបញ្ជី បានចប់

[80] ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា, លេខ នស/រកម/០៥០៧/០១២, ២៤ ឧសភា ២០០៧, មាត្រា១២។

សព្វគ្រប់។ សិទ្ធិរបស់សហកម្មសិទ្ធិករទូទៅដែលធ្វើសកម្មភាពក្នុងនាមក្រុមហ៊ុនត្រូវចប់ នៅពេលដែលក្រុមហ៊ុននោះត្រូវបានរំលាយ លើកលែងតែចំពោះសកម្មភាពទាំងឡាយណាដែលជាវិបាកដ៏ចាំបាច់នៃពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ដែលបានធ្វើពុំទាន់ចប់សព្វគ្រប់។ ប៉ុន្តែរាល់កិច្ចការដែលបានធ្វើជាប្រក្រតីក្នុងក្រុមហ៊ុនដោយសហកម្មសិទ្ធិករទូទៅ ដែលមិនបានដឹងអំពីការរំលាយក្រុមហ៊ុននោះ ហើយនៅតែធ្វើសកម្មភាពដោយស្មោះត្រង់ សហកម្មសិទ្ធិករនោះត្រូវជាប់កាតព្វកិច្ចជាមួយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងសហកម្មសិទ្ធិករទូទៅដទៃទៀតដូចដែលក្រុមហ៊ុននោះនៅជាធរមាននៅឡើយ។[81]

ម្យ៉ាងទៀត សហកម្មសិទ្ធិករទូទៅត្រូវធ្វើលិខិតជូនដំណឹងទៅមន្ត្រីចុះបញ្ជីអំពីការរំលាយក្រុមហ៊ុនតាមទម្រង់បែបបទដែលបានកំណត់ និងត្រូវតែងតាំងអ្នកជម្រះបញ្ជីផង។ សហកម្មសិទ្ធិករទូទៅត្រូវធ្វើការចុះផ្សាយជាបន្ទាន់អំពីការរំលាយក្រុមហ៊ុនក្នុងរយៈពេល ៤ សប្តាហ៍បន្តបន្ទាប់នៅក្នុងទំព័រសារព័ត៌មានជាភាសាខ្មែរនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលបោះពុម្ព ឬផ្សព្វផ្សាយនៅនឹងកន្លែងដែលក្រុមហ៊ុននោះមានការិយាល័យរបស់ខ្លួននៅទីនោះ ឬនៅក្នុងការផ្សព្វផ្សាយផ្សេងទៀតដូចមានចែងក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។[82]

### ៣.២. អនុភាពចំពោះតតិយជន

ការរំលាយក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនប៉ះពាល់សិទ្ធិតតិយជនដែលធ្វើពាណិជ្ជកម្មជាមួយដោយស្មោះត្រង់ និងមិនប៉ះពាល់ទៅនឹងបុគ្គលណាមួយដែលបានចុះកិច្ចសន្យាជាមួយសហកម្មសិទ្ធិករទូទៅ ឬមិនប៉ះពាល់ទៅនឹងភ្នាក់ងារណាម្នាក់ដែលធ្វើកិច្ចការក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ កិច្ចការដែលធ្វើជាមួយតតិយជននៅមិនទាន់ចប់ កិច្ចការនោះត្រូវធ្វើឲ្យចប់ ហើយសកម្មភាពបញ្ចប់កិច្ចការនោះនៅតែចងកាតព្វកិច្ចលើក្រុមហ៊ុនដដែល។[83]

តតិយជនត្រូវទទួលបាននូវការក្រើនរំលឹកយ៉ាងឆាប់រហ័ស និងជាក់ស្តែងអំពីការរំលាយក្រុមហ៊ុន។ ស្ថានភាពថ្មីនេះ មានផលសំខាន់ណាស់សម្រាប់ពួកគេ ព្រោះថា អ្នកដឹកនាំក្រុមហ៊ុនត្រូវជំនួសដោយអ្នកជម្រះបញ្ជីក្រុមហ៊ុន ហើយដែលក្រុមហ៊ុននៅរក្សាទុកបុគ្គលិកលក្ខណៈរបស់ខ្លួនសម្រាប់តែការជម្រះបញ្ជីប៉ុណ្ណោះ។ ការផ្សាយនេះមានប្រសិទ្ធភាពកាន់តែខ្លាំងកាលណាមាននាម  អ្នកជម្រះបញ្ជីផងដែរ។ ការចុះនិទ្ទេស «ក្រុមហ៊ុនកំពុងជម្រះបញ្ជី» ត្រូវធ្វើលើរាល់លិខិតដែលចេញពីក្រុមហ៊ុនចំពោះតតិយជនដូចជាលិខិតឆ្លើយឆ្លង វិក្កយបត្រ ប្រកាស។ល។ [84]

---

[81] ច្បាប់សហគ្រាសពាណិជ្ជកម្ម  ព្រះរាជក្រមលេខ នស/រកម/០១២២/០០៣, ៦ មករា ២០២២, មាត្រា៥៦។

[82] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម, នស/រកម/០១២២/០០២, ២៩ មករា ២០២២,មាត្រា៥៩ថ្មី។

[83] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសររកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥, មាត្រា៥៧។

[84] កៅ មុយថង, *ច្បាប់ពាណិជ្ជកម្ម*, បោះពុម្ពលើកទី៣ (ភ្នំពេញ៖ អង្គរ, ២០១៥), ទំព័រ១៤៨។

# សេចក្ដីសន្និដ្ឋាន

ក្រោយពីឆ្លងកាត់ការសិក្សាស្រាវជ្រាវលើប្រធានបទស្ដីពី "ក្រុមហ៊ុនសហកម្មសិទ្ធិនៅប្រទេសកម្ពុជា" រួចមក ទម្រង់នៃក្រុមហ៊ុនសហកម្មសិទ្ធិ ដែលក្រុមហ៊ុននេះបានចែកជាពីរគឺ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និង ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត រួមទាំងការបង្កើតនៃក្រុមហ៊ុន ក៏ដូចជាការប្រព្រឹត្តទៅនៃក្រុមហ៊ុន ជាពិសេស ការរំលាយផងដែរ។

គួរឲ្យកត់សម្គាល់ផងដែលថា តាមដែលបានសិក្សារកឃើញនូវមូលហេតុមួយចំនួនដែលធ្វើឲ្យ ពាណិជ្ជករខ្មែរជាច្រើន ដែលប្រកបពាណិជ្ជកម្មបង្កើតក្រុមហ៊ុនដោយមិនជ្រើសរើសយកក្រុមហ៊ុនប្រភេទនេះ។ ដោយមូលហេតុទាំងនោះមានដូចជា៖

**ការមរណៈភាពនៃសមាជិក៖** បើយោងតាមច្បាប់វិធានទូទៅនៃក្រមរដ្ឋប្បវេណីនៅចំណុចនៃការ រំលាយក្រុមហ៊ុនគឺមិនបានបញ្ញត្តិ ដោយមូលហេតុមរណៈភាពរបស់សហកម្មសិទ្ធិករណាម្នាក់ដែលនាំឲ្យមាន ការរំលាយក្រុមហ៊ុននោះទេ។ ប៉ុន្តែ នៅក្នុងច្បាប់សហគ្រាសពាណិជ្ជកម្មវិញគឺបានចែងថា មរណៈភាពនៃសហ កម្មសិទ្ធិករណាម្នាក់នោះក្រុមហ៊ុនគឺត្រូវបានរំលាយ លើកលែងតែមានការចែងនៅក្នុងកិច្ចសន្យាប៉ុណ្ណោះ។ ដោយសាការចែងបែបនេះវាមានលក្ខណៈចាស់កម្រិលពេក វាមិនបានឆ្លើយតបទៅនឹងតម្រូវការពាណិជ្ជករ បច្ចុប្បន្ននៃប្រទេសកម្ពុជាទេ ដោយសាវាមានមូលហេតុតឹងរឹងនេះ ដែលគ្រាន់តែហើយមានសមាជិកម្នាក់ស្លាប់ ធ្វើឲ្យរំលាយក្រុមហ៊ុន ប្រសិនបើមិនបានចែងនៅខទេ។ វានាំឲ្យមានការបាត់និរន្តភាពអាជីវកម្មរបស់ពាណិជ្ជករ បើក្រុមហ៊ុនកំពុងតែមានការរីកចម្រើន។

**ការធ្វើការងារគ្មានលុយ៖** មិនមែនឲ្យតែក្រុមហ៊ុនធ្វើពាណិជ្ជកម្មគឺសុទ្ធតែទទួលបានផលចំណេញ នោះទេ។ ដោយមានភាពខុសគ្នាផងដែល ដែលក្រុមហ៊ុនផ្សេងសមាជិកអាចទទួលបានប្រាក់ចំណេញ ក៏ប៉ុន្តែ នូវក្នុងក្រុមហ៊ុននេះវិញគឺមានផលវិបាកដ៏ធំមួយគឺវិបត្តិសេដ្ឋកិច្ច ដែលបានធ្វើឲ្យមានការបាត់បង់ដល់ភាគហ៊ុន សហកម្មសិទ្ធិករទូទៅដែលបានខិតខំធ្វើការហើយតែមិនទទួលបាននូវប្រាក់ចំណេញ នេះជាវិបត្តិដ៏ធំមួយដល់ ក្រុមហ៊ុននេះផងដែល។

**ការមិនមានសិទ្ធិគ្រប់គ្រង៖** នៅក្នុងច្បាប់បានចែងថាសហកម្មសិទ្ធិករមានកម្រិតមិនអាចមានសិទ្ធិ គ្រប់គ្រងចាត់ចែងក្នុងក្រុមហ៊ុន។ ដោយសហកម្មសិទ្ធិករមានកម្រិតបានបណ្ដាក់ទុនដែលទាំងចំណេះដឹង ចលនាវត្ថុ ឬអចលនាវត្ថុ សាច់ប្រាក់ដើម្បីបង្កើតក្រុមហ៊ុនតែមិនទទួលបាននូវសិទ្ធិសម្រេចចាត់ចែង គ្រប់គ្រងនូវ ក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិតទេ គឺមានតែសហកម្មសិទ្ធិករទូទៅទេទើបអាចមានសិទ្ធិទាំងនេះ។ នេះជា

បញ្ហាមួយដែលមានការមិនស្មើភាពគ្នាលើសិទ្ធិដែលទទួលបាន ដែលគេក៏បានចូលទុនដែល។

សរុបសេចក្ដីមក តាមដែលបកស្រាយខាងលើនេះគេអាចឃើញមានផលអវិជ្ជមានដូចជា ការដែលមានមរណៈភាពនៃសមាជិកណាម្នាក់បណ្ដាលឲ្យមានការរំលាយក្រុមហ៊ុន ការមិនទទួលបាននូវប្រាក់បៀវត្សដែលបានធ្វើការងារនៅក្នុងក្រុមហ៊ុន ការដែលមិនទទួលបាននូវសិទ្ធិគ្រប់គ្រងនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត។ មានកត្តាមួយចំនួនដែលមានភាពរឹតត្បិតខ្លាំងទៅលើពាណិជ្ជករ ដែលបណ្ដាលឲ្យក្រុមហ៊ុនប្រភេទនេះមិនមានការពេញនិយមនៅប្រទេសកម្ពុជា ដូចជា៖ បញ្ហាប្រឈមផ្នែកច្បាប់មានកម្រិតទៅលើសិទ្ធិគ្រប់គ្រងនៅក្នុងក្រុមហ៊ុន វិបត្តិខាងផ្នែកសេដ្ឋកិច្ច ការខ្វះខាត់ធនធានមនុស្សដែលមានជំនាញ អំពើពុករលួយក្នុងប្រទេស ភាពខុសគ្នានៃវប្បធម៌។ កត្តាទាំងនេះហើយដែលជាបញ្ហាប្រឈមដ៏ធំនៃក្រុមហ៊ុនសហកម្មសិទ្ធិ។

# អនុសាសន៍

ជាក់ស្តែងនៅប្រទេសកម្ពុជា គួរតែមានការធ្វើវិសោធនកម្មកំណែទម្រង់ទៅលើច្បាប់ផងដែរ ដើម្បីឲ្យក្រុមហ៊ុននេះមានការពេញនិយម និងមានការទទួលស្គាល់ពីពាណិជ្ជករនៅប្រទេសកម្ពុជា។ដើម្បីឲ្យមានការល្អប្រសើ គួរមានការកែលម្អនូវ៖

- ការទទួលបានប្រាក់បៀវត្ស សហកម្មសិទ្ធិករដែលបានធ្វើការឲ្យមានសិទ្ធិទទួលបានប្រាក់បៀវត្សដើម្បីឲ្យមានផលចំណេញសាកសមដល់សកម្មភាព ឬ មានភាពស្របទៅតាមគោលបំណងរបស់សហកម្មសិទ្ធិករ ដើម្បីរកប្រាក់ចំណេញ។
- និរាករណ៍ចោលនូវមាត្រាដែលបានលើកឡើងថា បុគ្គលដែលបានទទួលមរណៈភាពនោះក្រុមហ៊ុនក៏ត្រូវបានរំលាយ ព្រោះនេះមិនគួរជាមូលហេតុដែលមានការបណ្តាលឲ្យ រំលាយក្រុមហ៊ុននោះទេ។ វាមានការតឹងរឹងខ្លាំងចំពោះសហកម្មសិទ្ធិករ។
- ការផ្តល់ឲ្យមានសិទ្ធិក្នុងការគ្រប់គ្រងក្រុមហ៊ុនស្មើគ្នាទៅសហកម្មសិទ្ធិករគ្រប់រូប ព្រោះពួកគេក៏បានចូលទុនផងដែល។
- ពង្រឹងការបណ្តុះបណ្តាលជំនាញ ដើម្បីបង្កើនគុណភាព និងកម្រិតជំនាញរបស់កម្លាំងពលកម្ម។
- ប្រយុទ្ធប្រឆាំងអំពើពុករលួយ រដ្ឋាភិបាលកម្ពុជាបានចាត់វិធានការដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយ និងការិយាធិបតេយ្យ និងធ្វើឲ្យប្រសើរឡើងនូវតម្លាភាព និងប្រសិទ្ធភាពនៃនាយកដ្ឋានរដ្ឋាភិបាល។
- នៅសហរដ្ឋអាមេរិកបានបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទទួលខុសត្រូវមានកម្រិត ព្រោះពួកគេចង់ធ្វើពាណិជ្ជកម្មដោយមិនចង់មានសមាជិកច្រើនពេក។ ម្យ៉ាងទៀត ប្រទេសកម្ពុជាក៏គួរតែមានការបង្កើតក្រុមហ៊ុនប្រភេទនេះបន្ថែម វាអាចឲ្យមានជម្រើសកាន់តែច្រើនទៅពាណិជ្ជករប្រសិនបើគេចង់បានមានភាពទទួលខុសត្រូវទាំងអស់គ្នា និងមានការផ្តល់សិទ្ធិគ្រប់គ្រងដល់សហកម្មសិទ្ធិករគ្រប់រូប តែគាត់មិនចង់បានសមាជិកច្រើនពេកដូចទៅក្រុមហ៊ុនមូលធន។

ជារួមមក រដ្ឋាភិបាលកម្ពុជាកំពុងខិតខំប្រឹងប្រែងដើម្បីកែលម្អទៅលើពាណិជ្ជកម្ម និងជំរុញការអភិវឌ្ឍន៍សហគ្រាស និងកំណើនសេដ្ឋកិច្ច ជាពិសេសគួរបង្កើតក្រុមហ៊ុនសហកម្មសិទ្ធិទទួលខុសត្រូវមានកម្រិតបន្ថែម។ តាមរយៈការកែលម្អបរិបទវិស័យច្បាប់ និងបទប្បញ្ញត្តិដែលគួរតែបន្ធូរបន្ថយ ការលើកកម្ពស់ការវិនិយោគ និង

ភាពជាសហគ្រិន ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ ការពង្រឹងការបណ្តុះបណ្តាល និងការអប់រំ និងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ពួកគេសង្ឃឹមថានឹងបង្កើតលក្ខខណ្ឌអភិវឌ្ឍន៍ដ៏អំណោយផលបន្ថែមទៀតសម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិ។

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

### ១.១ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលចូលជាធរមាន

- ច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ព្រះរាជក្រមលេខ នសររកម/០១២២/០០២, ៦ មករា ២០២២។
- ច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម ព្រះរាជក្រមលេខ នស/រកម/០១២២/០០៣, ៦ មករា ២០២២។
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/១២០៧/០៣០, ០៨ ធ្នូ ឆ្នាំ២០០៧។
- ច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា, លេខ នស/រគម/០៥០៧/០១២, ២៤ ឧសភា ២០០៧ ។
- ប្រកាសស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម តាមប្រព័ន្ធស្វ័យប្រវត្តកម្ម, លេខ ២១៣ ព.ណ ចបព.ប្រក , ២៤ មិថុនា ២០១៦សេចក្ដីជូនដំណឹងរបស់ក្រសួងពាណិជ្ជកម្ម, លេខ ១៤១៥, ចុះថ្ងៃទី ២០ មិថុនា ២០០៦។
- ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម, លេខ នសររកម/០៦០៥/០១៩, ១៩ មិថុនា ២០០៥។
- សេចក្ដីជូនដំណឹងស្ដីពីឯកសារតំរូវការសំរាប់ការចុះបញ្ជីពាណិជ្ជកម្ម, លេខ ១៤១៤ MOC/SM, ចុះថ្ងៃទី ២០ មិថុនា ២០០៦

### ១.២ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលនិរាករណ៍

- ច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រម/០៣នស/០៥ សីហា ១៩៩៤ (ដែលបាននិរាករណ៍)

## ២. សៀវភៅ និងឯកសារផ្សេងៗ

- គង់ សាផន. ២០២១. *នីតិពាណិជ្ជកម្ម*, បោះពុម្ពលើកទី៣. ភ្នំពេញ៖ សុខ ចេង។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០២០, សៀវភៅដំណើការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។
- កុយ នាម. ២០១៦. *ច្បាប់ក្រុមហ៊ុន*, ការផ្សាយលើកទី១. ឧត្ដម្ភការបោះពុម្ពពីលោកមេធាវី សួន វិសាល។
- កៅ មុយថង. ២០១៥. *ច្បាប់ពាណិជ្ជកម្ម*, បោះពុម្ពលើកទី៣. ភ្នំពេញ៖ អង្គរ។
- អ៊ីវ ប៉ូលី. ២០០៨. *នីតិក្រុមហ៊ុន* ។
- ក្រុមការងារនៃអនាគតគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្ដីពន្យល់អំពីក្រមរដ្ឋប្បវេណី, ភាគ១, ភ្នំពេញ៖ គម្រោងអភិវឌ្ឍវិស័យច្បាប់ និងតុលាការរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន(JICA), ២០១៣
- គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី,សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភ្នំពេញ៖

ការិយាល័យកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌នៅក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា, ២០១០

- ក្រសួងពាណិជ្ជកម្ម, សៀវភៅណែនាំស្ដីពីការចុះបញ្ជីពាណិជ្ជកម្ម និងការប្រកបអាជីវកម្មអនុលោមតាមច្បាប់។

**៣. គេហទំព័រ**

- ក្រសួងមុខងារសាធារណៈ. *សេវាតាមក្រុម «អាជ្ញាប័ណ្ណ»*. http://www.service.gov.kh/category/174 (ចូលទស្សនាថ្ងៃទី២៧ មិថុនា ២០២៤ )
- Cambodia Data eXchange. https://camdx.gov.kh/ (ចូលទស្សនាថ្ងៃទី៣ កក្កដា ២០២៤ )
- ក្រសួងពាណិជ្ជកម្ម. *គេហទំព័រចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម.* www.businessregistration.moc.gov.kh (ចូលទស្សនាថ្ងៃទី ១០ កក្កដា ២០២៤)
- rfi. *គុណសម្បត្តិ និងគុណវិបត្តិនៃប្រភេទក្រុមហ៊ុនពាណិជ្ជកម្មក្នុងច្បាប់ខ្មែរ.* https://www.rfi.fr/km/different-types-of-companies-in-cambodian-law？ (ចូលទស្សនាថ្ងៃទី ៣១ មិថុនា ២០២៤)
- Fairbairn Brett. 2012. *The Rochdale Pioneers and the Co-operative Principles.* https://www.columbia.edu/~hauben/amalgamated/history/34/ ចូលទស្សនាថ្ងៃទី)២ មិថុនា ២០២៤(

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*****

## កិច្ចសន្យាក្រុមហ៊ុន

កិច្ចសន្យានេះត្រូវបានធ្វើឡើងនៅថ្ងៃទី....... ខែ........... ឆ្នាំ............

**រវាង**

- លោក................................ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ................................ ចុះថ្ងៃទី..........ខែ............ឆ្នាំ.......... ដែលមានអសយដ្ឋានបច្ចុប្បន្ន នៅផ្ទះលេខ.......... ផ្លូវលេខ............ ភូមិ.......... សង្កាត់ ............ខណ្ឌ ............. រាជធានីភ្នំពេញ ចាប់ពីពេលនេះតទៅហៅកាត់ថា <u>ភាគី ក</u>។

**និង**

- លោក................................ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ................................ ចុះថ្ងៃទី.......... ខែ............ ឆ្នាំ.......... ដែលមានអសយដ្ឋានបច្ចុប្បន្ន នៅផ្ទះលេខ.......... ផ្លូវលេខ............ ភូមិ.......... សង្កាត់............ ខណ្ឌ.............. រាជធានីភ្នំពេញ ចាប់ពីពេលនេះតទៅហៅកាត់ថា <u>ភាគី ខ</u>។

**<u>ដោយហេតុថា:</u>** ភាគី ក និងភាគី ខ ចាប់ពីពេលនេះទៅហៅកាត់ថាភាគីទាំងពីរ ឬសមាជិកភាគហ៊ុន មានបំណងសហការគ្នាបង្កើតកិច្ចសន្យាក្រុមហ៊ុន ដែលចាប់ពីពេលនេះតទៅហៅកាត់ថា (កិច្ចសន្យា) ក្នុងគោលបំណងធ្វើចិការដំណាំ......... ......... ......... ......... និង......... (ដំណាំលៃជុំ) ដែលចាប់ពីពេលនេះតទៅហៅកាត់ថា (កម្មវត្ថុអាជីវកម្ម) ដោយសុចរិត និងស្មោះត្រង់ ដោយភាគីទាំងពីរសន្យាជាឧឡោរិកថា នឹងនិងមិនកេងប្រវ័ញ្ចផលប្រយោជន៍គ្នា ដែលនាំឲ្យខូចផលប្រយោជន៍ ភាគីណាមួយឡើយ។ ភាគីទាំងពីរ យល់ព្រមទទួលខុសត្រូវចំពោះសកម្មភាពរបស់ក្រុមហ៊ុនដោយសាមគ្គីភាព។

**<u>ដោយហេតុថា:</u>** ភាគី ក ជាម្ចាស់កម្មសិទ្ធិលើទំហំដី ......... ហិចតា មានទីតាំងស្ថិតនៅ................ .................................................... សំគាល់តាមរយៈលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ............. ចុះថ្ងៃទី.......... ខែ......... ឆ្នាំ................ ដែលភាគីទាំងអស់យល់ព្រមយកដីនេះប្រើប្រាស់ជាទីតាំងដាំដំណាំខាងលើ។

**ដោយហេតុថា:** ភាគី ខ យល់ព្រមវិនិយោគនូវទឹកប្រាក់របស់ខ្លួនក្នុងចំនួន .......... (..........) ដុល្លារអាមេរិក សម្រាប់ទុនវិនិយោគដំបូង និងយល់ព្រមវិនិយោគនូវទឹកប្រាក់របស់ខ្លួនបន្ថែមទៀតចំនួន .......... (..........) ដុល្លារអាមេរិក សម្រាប់ទុន បម្រុងៗ

***ហេតុនេះភាគីទាំងពីរបានព្រមព្រៀងគ្នាតាមប្រការដូចខាងក្រោម:***

**ប្រការ ១ និយមន័យពាក្យគន្លឹះដែលមាននៅក្នុងកិច្ចសន្យា**

- **កិច្ចសន្យាក្រុមហ៊ុន:** *សំដៅលើកិច្ចសន្យាបង្កើតជាក្រុម ដែលគ្មានការរៀបចំលក្ខណៈជានីតិបុគ្គលដើម្បីប្រកបកិច្ចការ ដោយសហការគ្នា ដោយភាគីនីមួយៗធ្វើការវិនិយោគទ្រព្យធនរៀងៗខ្លួនៗ*
- **ក្រុមហ៊ុន:** *គឺជាក្រុមដែលបានបង្កើតដោយការសន្យាដែលភាគីនីមួយៗ វិនិយោគទ្រព្យធនរៀងៗខ្លួន ហើយប្រកបកិច្ចការដោយសហការគ្នាៗ*
- **កម្មសិទ្ធិរមចិនាគ:** *គឺជាស្ថានភាពបុគ្គលច្រើននាក់ មានកម្មសិទ្ធិស្របតាមភាគចំណែករបស់ខ្លួនដែលគិតទៅតាមចំនួននៅលើទ្រព្យតែមួយៗ*
- **ទ្រព្យធន:** *សំដៅទៅលើភាគទុនជាទ្រព្យសម្បត្តិ ឬជាទឹកប្រាក់ ដែលភាគីនីមួយៗបានវិនិយោគៗ*

**ប្រការ ២ កម្មវត្ថុនៃកិច្ចសន្យា**

*កម្មវត្ថុនៃកិច្ចសន្យានេះ គឺជាការសហការគ្នាបង្កើតក្រុមហ៊ុន ក្នុងគោលបំណងធ្វើចំការដំណាំ .......... .......... .......... និង.......... (ដំណាំវិលជុំ) ជាកម្មវត្ថុម្បងនៃអាជីវកម្ម លើទំហំដី .......... ហិចតា មានទីតាំងស្ថិតនៅ.......................................................................... ដើម្បីទទួលបានមកវិញនូវប្រាក់ចំណេញ ដែលជាតម្លៃតបស្នងសំរាប់ធ្វើការបែងចែកៗ*

**ប្រការ ៣ ការជ្រើសរើស និងសិទ្ធិរបស់សមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការ**

៣.១ *ភាគីទាំងពីរ បានយល់ព្រមជាឯកច្ឆន្ទប្រគល់សិទ្ធិភាគី ................ ជាសមាជិកក្រុមហ៊ុនដែលអុវត្តភាតព្វកិច្ចការក្នុងនាមក្រុមហ៊ុន និងតំណាងស្របច្បាប់របស់ក្រុមហ៊ុនៗ ភាគីដែលត្រូវបានជ្រើសរើស ជាសមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការនេះ អាចត្រូវបានផ្លាស់ប្តូរ និងដកហូតសិទ្ធិ ប្រសិនបើបានប្រព្រឹត្តិអំពើរំលោភលើទំនុកចិត្ត រឺការគេងប្រវ័ញ្ចន៍ៗ*

៣.២ *សមាជិក្រុមហ៊ុនដែលទទួលអាណត្តិអនុវត្តកិច្ចការ នៅក្នុងកិច្ចសន្យាក្រុមហ៊ុននេះ មិនអាចប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនដោយស្វ័យប្រវត្តិទេ រាល់ការសម្រេចកិច្ចការរបស់ក្រុមហ៊ុន*

ផ្សេងៗ ត្រូវមានការឯកភាពពីភាគី............ ជាមុនសិន។ ប្រសិនបើគ្មានមូលហេតុត្រឹមត្រូវទេ សមាជិកក្រុមហ៊ុន ដែលអនុវត្តកិច្ចការពុំអាចលាឈប់ ឬត្រូវបញ្ឈប់ឡើយ។

**ប្រការ ៤ <u>ការកំណត់លើទ្រព្យធនដែលត្រូវបានវិនិយោគ និងដំណើរការកម្មវត្ថុអាជីវកម្ម</u>**

៤.១ ទ្រព្យធនសរុប ដែលត្រូវយកមកធ្វើការវិនិយោគមានចំនួន............ (............) ដុល្លារអាមេរិក ដោយប្រើប្រាស់ទុនដំបូង ............ (............) ដុល្លារអាមេរិក និងទុនបម្រុង ............ (............) ដុល្លារអាមេរិក ដែលទ្រព្យធនទាំងអស់នេះត្រូវបានវិនិយោគដោយ ភាគី ខ តែម្នាក់គត់។

៤.២ ភាគី......... ត្រូវប្រគល់ទឹកប្រាក់ដូចមានចែងក្នុងចំណុច ៤.១ ខាងលើ នៅថ្ងៃផ្តិតមេដៃលើកិច្ចសន្យានេះ ដោយភាគី ......... ជាសមាជិកក្រុមហ៊ុនអនុវត្តកិច្ចការ។ ក្រោយពេលបានទទួលទ្រព្យធនជាទឹកប្រាក់នេះហើយ ភាគីទាំងអស់ឯកភាពយកទឹកប្រាក់នេះ ទៅតម្កល់ទុកនៅធនាគារណាមួយ ដោយត្រូវបង្កើតគណនីរួមគ្នា។ មានតែសមាជិកក្រុមហ៊ុនអនុវត្តកិច្ចការទើបមានសិទ្ធិដកប្រាក់ជាមូលធននេះ ដើម្បីយកមកដំណើរការកម្មវត្ថុអាជីវកម្ម តែត្រូវរាយការណ៍អំពីការដកប្រាក់ជូនដល់ភាគី ខ ដើម្បីអោយមានការឯកភាពគ្នាជាមុនសិន។

៤.៣ ភាគីទាំងពីរ បានយល់ព្រមបង្កើយគណនីរួមគ្នាពីរ នៅធនាគារណាមួយ ដោយបើគណនីប្រាក់រៀល និងគណនីប្រាក់ដុល្លារអាមេរិក សម្រាប់ដាក់ប្រាក់ចំណូល ដែលបានមកពីការលក់ទិន្នផលកសិកម្មខាងលើ។ រាល់ការដកប្រាក់ចេញពីគណនីទាំងពីរនេះ ត្រូវមានការយល់ព្រមភាគីទាំងពីរ។

**ប្រការ ៥ <u>សិទ្ធិ និងភារកិច្ចរបស់ភាគីនីមួយៗ</u>**

៥.១ សមាជិក្រុមហ៊ុនដែលអនុវត្តកិច្ចការ ត្រូវគណនាការចំណូល ចំណាយ នៅក្នុងអំឡុងពេលទៀតទាត់ រៀងរាល់ដំណាច់ខែនីមួយៗ និងធ្វើរបាយការណ៍ចំណូល ចំណាយប្រចាំខែនីយមួយៗ ជូនភាគី...... ហើយមានករណីដែលមានចំណេញ សមាជិកក្រុមហ៊ុនដែលអនុវត្តកិច្ចការត្រូវបែងចែកផលចំណេញដល់ភាគី........ ដោយអនុលោមតាមប្រការ ៦ ខាងក្រោម។

៥.២ សមាជិកនីមួយៗនៃក្រុមហ៊ុន មានបន្ទុកទទួលខុសត្រូវដោយសាមគ្គីភាព ជាមួយនិងក្រុមហ៊ុនអំពីភារកិច្ចចំពោះបំណុលដែលទាក់ទង និងដំណើការអាជីវកម្មរបស់ក្រុមហ៊ុន។

៥.៣ ក្នុងអំឡុងពេលនៃក្រុមហ៊ុន តាមរយៈកិច្ចសន្យាក្រុមហ៊ុននេះ ភាគីទាំងអស់ឯកភាពកំណត់អត្ថិភាពក្នុងរយៈពេលមួយជីវិតរបស់សមាជិកនីមួយៗ សមាជិកនីមួយៗអាចដកខ្លួនចេញពេលណាក៏បាន ដោយមានការយល់ព្រមពីភាគីម្ខាងទៀត។ ប៉ុន្តែ ការដកខ្លួនចេញនេះពុំអាចធ្វើបានឡើយ បើបណ្តាលឲ្យខូចផលប្រយោជន៍ដល់ក្រុមហ៊ុន។ ទោះបីជាបានកំណត់អំឡុងពេលនៃអត្ថិភាពរបស់ក្រុមហ៊ុនក៏ដោយ នៅក្នុងករណី ដែលពុំអាចជៀសវាងបាន សមាជិកនីមួយៗ អាចស្នើសុំឲ្យមានការបញ្ចប់អត្ថិភាពក្រុមហ៊ុនមុនកំណត់បាន ត្រូវមានការយល់ព្រមពីភាគីម្ខាងទៀត។

៥.៤ រាល់ការបន្ថយ ការបង្កើន និងការលក់ទ្រព្យធនវិនិយោគ ត្រូវមានការយល់ព្រមពីភាគីទាំងពីរទើបអាចបន្ថយ បង្កើន ការផ្ទេរ និងលក់ទ្រព្យវិនិយោគ។

៥.៥ ក្នុងករណីសមាជិកណាមួយទទួលមរណៈភាព ទ្រព្យធនដែលជាចំណែករបស់សមាជិកនោះ និងត្រូវប្រគល់ឲ្យដល់សន្តតិជនរបស់សមាជិកនោះ ជាអ្នកគ្រប់គ្រងបន្តនៅក្នុងក្រុមហ៊ុន ប៉ុន្តែ ប្រសិនបើសន្តតិជននោះមិនមានបំណងក្លាយជាសមាជិកថ្មីរបស់ក្រុមហ៊ុនទេ សន្តតិជននោះ អាចស្នើដកយកនូវចំណែកទ្រព្យធនរបស់មតកជនចេញពីក្រុមហ៊ុនបាន។

៥.៦ ក្នុងករណី មានការដកខ្លួន ឬមានការលុបឈ្មោះសមាជិកណាមួយ ការគណនារវាងសមាជិកក្រុមហ៊ុនដែលបានដកខ្លួន និងសមាជិកផ្សេងៗទៀតរបស់ក្រុមហ៊ុន ចាំបាច់ត្រូវអនុវត្តដោយឡែកតាមស្ថានភាព នៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន នៅពេលដែលដកខ្លួននោះ ដោយត្រូវធ្វើការជម្រះបញ្ជីត្រឹមត្រូវ។

**ប្រការ ៦ <u>អំពីការបែងចែកភាគលាភ</u>**

ប្រាក់ចំណេញ ដែលបានមកពីការលក់ទិន្នផលដូចជា.......... .......... និង..........និងត្រូវធ្វើការបែងចែកស្មើៗគ្នា។ ដោយឡែក ចំពោះប្រាក់ចំណេញ ដែលបានមកពីការលក់បន្លែជាដំណាំវែលជុំ ត្រូវបានទៅភាគី ១ ទាំងអស់ដោយមិនមានការបែងចែកគ្នាឡើយ។

**ប្រការ ៧ <u>ការរំលាយក្រុមហ៊ុន</u>**

ក្រុមហ៊ុន ត្រូវរំលាយតាមករណីណាមួយ ដូចកំណត់ខាងក្រោម:

-អសមត្ថភាពក្នុងការបំពេញកម្មវត្ថុអាជីវកម្ម

-បើមានការព្រមព្រៀងពីសមាជិកទាំងអស់របស់ក្រុមហ៊ុន

-បើអំឡុងពេលនៃអត្ថិភាពរបស់ក្រុមហ៊ុន ដែលកំណត់នៅក្នុងកិច្ចសន្យាក្រុមហ៊ុនត្រូវបានបញ្ចប់

-ក្នុងករណីដែល មានមូលហេតុមិនអាច ជៀសវាងបាន សមាជិក ទីមួយៗរបស់ក្រុមហ៊ុនអាច ទាមទាឲ្យរំលាយក្រុមហ៊ុនបាន។

**ប្រការ ៧ __អវសានបញ្ញត្តិ__**

៧.១ កិច្ចសន្យានេះត្រូវបានបង្កើតឡើងស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ភាគីទាំងពីរ បានយល់ព្រមដោះស្រាយវិវាទដែលកើតឡើងពីការបកស្រាយ និងការមិនអនុវត្តតាមកិច្ចសន្យានេះ ដោយការសម្រុះសម្រួលគ្នា។ ក្នុងករណីមិនអាចដោះស្រាយវិវាទតាមរយៈការសម្រុះសម្រួលទេ ភាគីទាំងពីរយល់ព្រមបញ្ជូនវិវាទទៅដោះស្រាយនៅតុលាការនៃព្រះរាជាណាចក្រកម្ពុជា។

៧.២ កិច្ចសន្យានេះត្រូវបានធ្វើឡើងជាភាសាខ្មែរចំនួន ០៣ ច្បាប់ដើម ដែលមានតម្លៃគតិយុត្តដូចគ្នា និងត្រូវបានទុកដោយភាគី ក ចំនួន ០១ ច្បាប់ ភាគី ខ ចំនួន ០១ ច្បាប់ដើម និងមេធាវី ចំនួន ០១ ច្បាប់ដើម។ ភាគីទាំងអស់បានអានរាល់ខ្លឹមសារនៃកិច្ចសន្យានេះ និងយល់ព្រមដោយឆន្ទៈសេរី។ កិច្ចសន្យាមានអនុភាពអនុវត្តចាប់ពីថ្ងៃផ្ដិតមេដៃស្ដាំនេះតទៅ។

**ស្នាមមេដៃស្ដាំ ភាគី ក** **ស្នាមមេដៃឆ្វេង ភាគី ខ**

.................................................. ..................................................

បានឃើញ និងបញ្ជាក់ថា

ភាគីទាំងពីរពិតជាបានផ្ដិតមេដៃស្ដាំ

នៅចំពោះមុខយើងមេធាវីពិតប្រាកដមែន

រាជធានីភ្នំពេញ ចុះថ្ងៃទី......... ខែ......... ឆ្នាំ ............

ហត្ថលេខា និងត្រា

# សៀវភៅមគ្គុទេសក៍



# ដំណើរការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

# ផ្នែកទី ២

# ចុះបញ្ជីអាជីវកម្មអ្នក តាមប្រព័ន្ធបច្ចេកវិទ្យា ព័ត៌មាន



## ដំណើរការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ដំណើរការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានចែកចេញជា ៦ជំហានធំៗ៖



**០១**
ការបង្កើតគណនីលើ CamDigiKey App



**០២**
ការ Log In ចូលទំព័រ Portal



**០៣**
ដំណើរការចុះបញ្ជី



០៤
ការទូទាត់ប្រាក់



០៥
ការពិនិត្យស្ថានភាព និង ទទួលបានសារជូនដំណឹងពីកំហុសផ្សេងៗក្នុងដំណាក់-កាលនីមួយៗ



០៦
ការទទួលបានអាជ្ញាបណ្ណ/វិញ្ញាបនបត្រឌីជីថល។




## ១. ការបង្កើតគណនីលើ CamDigiKey App[៣]

១.១. ដោនឡូត CamDigiKey App ពី App Store ឬ Play Store លើទូរស័ព្ទដៃរបស់អ្នក។

[៣] CamDigiKey គឺជាកម្មវិធីទូរស័ព្ទសម្រាប់ផ្ទៀងផ្ទាត់អត្តសញ្ញាណតាមរយៈ QR Code របស់រាជរដ្ឋាភិបាលកម្ពុជា ដែលភ្ជាប់អ្នកប្រើប្រាស់ទៅសេវាកម្មរដ្ឋាភិបាលឌីជីថលរបស់ប្រទេសកម្ពុជា។

## ២. ការ Log In ចូលទំព័រ Portal

២.១. ចូលទៅតំណ www.registrationservices.gov.kh លើកុំព្យូទ័ររបស់អ្នក, រួចចុចលើប៊ូតុង "ចុះបញ្ជីអាជីវកម្ម" នៅជ្រុងខាងស្ដាំផ្នែកខាងលើនៃគេហទំព័រ។




២.២. ចុចប៊ូតុង "ទាញយក QR Code" ។






២.៣. ស្កេន QR Code ដែលអ្នកឃើញជាមួយនឹង CamDigiKey App នៅលើទូរស័ព្ទដៃរបស់អ្នក។

២.៤. បញ្ចូលលេខកូដផ្ទាល់ខ្លួនចំនួន ៦ខ្ទង់ដែលអ្នកបានបង្កើតក្នុង CamDigiKey App ទៅក្នុង CamDigiKey App នោះ អ្នកនឹងចូលទៅកាន់ទំព័រ Portal ចុះបញ្ជីអាជីវកម្មក្នុងកុំព្យូទ័រដោយស្វ័យប្រវត្តិ។

## ៣. ដំណើរការចុះបញ្ជី

៣.១. ចុចប៊ូតុង "ចុះបញ្ជីអាជីវកម្ម"។



៣.២. ជ្រើសរើសទម្រង់សហគ្រាសដែលសមស្របទៅនឹងសហគ្រាសរបស់អ្នក រួចបំពេញព័ត៌មាន និងភ្ជាប់ឯកសារលើទម្រង់បែបបទ "ចុះបញ្ជីពាណិជ្ជកម្ម" រួចចុច "បន្ទាប់"។



៣.៣. បំពេញព័ត៌មាន និងភ្ជាប់ឯកសារលើទម្រង់បែបបទ "ចុះបញ្ជីពន្ធដារ" រួចចុច "បន្ទាប់"។



៣.៤. បំពេញព័ត៌មាន និងភ្ជាប់ឯកសារលើទម្រង់បែបបទ "សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស" រួចចុច "បន្ទាប់"។



៣.៥. ពិនិត្យព័ត៌មាន និងឯកសារឡើងវិញ រួចចុចប៊ូតុង "ដាក់ស្នើ"។



## ៤. ការទូទាត់សងប្រាក់

៤.១. ជ្រើសរើសជម្រើសទូទាត់សងប្រាក់មួយ ដែលក្នុងនោះមាន ABA Pay និងការទូទាត់តាមរយៈកាតឥណទាន ឬកាតឥណពន្ធ។

៤.២. ក្នុងករណីទូទាត់ប្រាក់តាម ABA Pay,

- ៤.២.១. អ្នកនឹងឃើញ QR Code នៅលើអេក្រង់កុំព្យូទ័រ។
- ៤.២.២. ចូលទៅកាន់ ABA Mobile App រួច log in គណនីធនាគារ ABA របស់អ្នកលើទូរស័ព្ទដៃ។
- ៤.២.៣. ចុចប៊ូតុង "ស្កេន QR" នៅលើ ABA Mobile App។
- ៤.២.៤. ស្កេន QR Code ដែលបង្ហាញនៅលើអេក្រង់កុំព្យូទ័រជាមួយទូរស័ព្ទដៃរបស់អ្នក។
- ៤.២.៥. ការទូទាត់សងប្រាក់ និងការចុះបញ្ជីអាជីវកម្មរបស់អ្នកត្រូវបានបញ្ចប់។

៤.៣. ក្នុងករណីទូទាត់សងប្រាក់តាមកាតឥណទាន ឬកាតឥណពន្ធ (Visa, Master Card ឬ Union Pay International)[៣],

- ៤.៣.១. បំពេញព័ត៌មានគណនីរបស់អ្នក រួចចុចប៊ូតុង "ដាក់ស្នើ"។
- ៤.៣.២. ការទូទាត់សងប្រាក់ និងការចុះបញ្ជីអាជីវកម្មរបស់អ្នកត្រូវបានបញ្ចប់។




៣ រាល់ការទូទាត់សងប្រាក់តាមកាតឥណទាន ឬកាតឥណពន្ធនឹងត្រូវមានការបង់ថ្លៃសេវាបន្ថែម (additional service charge) ទៅលើតម្លៃសរុប ២.៣%។

## ៥. ការពិនិត្យស្ថានភាព និងទទួលបានសារជូនដំណឹងពីកំហុសផ្សេងៗក្នុងដំណាក់កាលនីមួយៗ

៥.១. ពេល Log in ចូលទំព័រ Portal ចុច "ក្រុមហ៊ុនរបស់ខ្ញុំ"។



៥.២. ចុចលើក្រុមហ៊ុនណាមួយដែលអ្នកចង់តាមដានស្ថានភាពសំណើ នោះអ្នកនឹងឃើញមានការបញ្ជាក់ស្ថានភាពសំណើលម្អិត។



## ៦. ការទទួលបានអាជ្ញាបណ្ណ/វិញ្ញាបនបត្រឌីជីថល

៦.១. នៅពេលដែលអ្នកឃើញព័ត៌មានអំពីស្ថានភាពលម្អិតរបស់ក្រុមហ៊ុនអ្នក សូមចុច "ទាញយក" នៅក្នុងផ្នែកវិញ្ញាបនបត្រ។



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
NATION RELIGION KING

ក្រសួងពាណិជ្ជកម្ម
MINISTRY OF COMMERCE

លេខ(No) MOC-[illegible] ពណ.ចបព

# វិញ្ញាបនបត្រ

## បញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

## CERTIFICATE OF INCORPORATION

| | | |
|---|---|---|
| នាមករណ៍ | : | [illegible] |
| NAME | : | [illegible] |
| ចុះបញ្ជីក្រោមលេខ | : | [illegible] |
| REGISTRATION NUMBER | : | [illegible] |
| កាលបរិច្ឆេទចុះក្នុងបញ្ជីពាណិជ្ជកម្ម | : | ២៩ មីនា ២០២២ |
| INCORPORATION DATE | : | 29 March 2022 |
| ត្រូវបានទទួលស្គាល់ថាជា | : | ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត |
| IS INCORPORATED AS | : | Private Limited Company |

ស្ថិតក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិង
បញ្ជីពាណិជ្ជកម្ម ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្រមរដ្ឋប្បវេណី
និងក្រមព្រហ្មទណ្ឌ ដែលមានជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

UNDER THE REGULATIONS OF COMMERCIAL RULES AND REGISTER LAW, COMMERCIAL ENTERPRISES LAW, CIVIL CODE AND PENAL CODE OF THE KINGDOM OF CAMBODIA

ភ្នំពេញ, ២៩ មីនា ២០២២
PHNOM PENH, 29 March 2022
ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
F. MINISTER OF COMMERCE
អគ្គនាយក
Director General

ហូ-ស៊ីវយ៉ុង
HO SIVYONG

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

**បេឡាជាតិសន្តិសុខសង្គម**
NATIONAL SOCIAL SECURITY FUND
លេខ: [redacted].ប.ស.ស.-បក

# វិញ្ញាបនបត្រចុះបញ្ជីកាសហគ្រាស គ្រឹះស្ថាន
## ENTERPRISE REGISTRATION CERTIFICATE

ឈ្មោះសហគ្រាស គ្រឹះស្ថាន : [redacted]
*Name of Enterprise*

លេខអត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន : [redacted]
*Enterprise Identification Number*

ត្រូវបានចុះបញ្ជីកាក្នុងបេឡាជាតិសន្តិសុខសង្គម នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០២៣
*Registered with the National Social Security Fund on*

ថ្ងៃ សុក្រ ២កើត ខែ ស្រាពណ៍ ឆ្នាំ ថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២៣
Phnom Penh, Date

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**
**អគ្គនាយកបេឡាជាតិសន្តិសុខសង្គម**
DELEGATE OF THE ROYAL GOVERNMENT IN CHARGE AS
DIRECTOR GENERAL OF NATIONAL SOCIAL SECURITY FUND

**អ៊ុក សមវិទ្យា**

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

លេខ/ N° [redacted] អពជ

[redacted]



# វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ
## (អាករលើតម្លៃបន្ថែម-អតប)

**អគ្គនាយកដ្ឋានពន្ធដារ សូមបញ្ជាក់ថា៖**

សហគ្រាសឈ្មោះ៖ [redacted]
អាសយដ្ឋាន៖ [redacted]
លេខអត្តសញ្ញាណកម្មសារពើពន្ធ (អ.ត.ប)៖ [redacted] ស្ថិតក្រោមការគ្រប់គ្រង៖ សាខាពន្ធដារខេត្តកំពត
សកម្មភាពអាជីវកម្មចម្បង៖ អចលនទ្រព្យ (សេវាកម្រៃជើងសាលើការទិញ លក់ ជួល និងវាយតម្លៃ)
ទ្រង់ទ្រាយសហគ្រាស៖ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត
ម្ចាស់សហគ្រាស ឬអ្នកតំណាង៖ [redacted] សញ្ជាតិ៖ ខ្មែរ

បានចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារ ជាអ្នកជាប់ពន្ធមធ្យម ស្របតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន ការចុះបញ្ជីនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ០១ ខែមេសា ឆ្នាំ២០២២ តទៅ។

## CERTIFICATE OF TAX REGISTRATION (VALUE ADDED TAX-VAT)

GENERAL DEPARTMENT OF TAXATION certifies that

Company's name : [redacted]
Tax Identification Number (VAT TIN) : [redacted] Under : Kampot Tax Branch
Main business activity : Real estate (commission service on buying, selling, renting and appraisal)
Form of enterprise : Private limited company
Owner/Representative's name : [redacted] Nationality : Cambodian

is registered with General Department of Taxation as a Medium taxpayers in accordance with laws and regulations on taxation and this registration is valid from 01-April-2022 onward.

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២
Phnom Penh,01 April 2022

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**
Minister Attached to the Prime Minister
Delegate of Royal Government
In Charge as Director General of the General Department of Taxation

**គង់ វិបុល**

បញ្ជាក់៖ វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម-អតប) នេះ ត្រូវបានចេញជូនតាមទម្រង់អេឡិចត្រូនិក សម្រាប់ប្រើប្រាស់ជាផ្លូវការ។ លោក-លោកស្រីមានកាតព្វកិច្ចមកបង្ហាញខ្លួនចំពោះរដ្ឋបាលសារពើពន្ធតាមកាលបរិច្ឆេទដែលមានចុះនៅក្នុងលិខិតអញ្ជើញរបស់រដ្ឋបាលសារពើពន្ធ។ ក្នុងករណីលោក-លោកស្រី មិនបានបង្គ្រប់ឯកសារសម្រាប់ការចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងរយៈពេល ១៥ ថ្ងៃ វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម-អតប) នេះ នឹងត្រូវនិរាករណ៍ដោយស្វ័យប្រវត្តិ។

Note : This VAT Certificate is issued under an electronic form for official used. You have an obligation to present yourself at the tax administration according to the date and place specified in the invitation letter. If you do not complete the requirements in 15 days, this VAT Certificate shall be automatically abrogated